# រាជរដ្ឋាភិបាលកម្ពុជា

# គោលនយោបាយជាត
# ស្តីពីមនុស្សវ័យចាស់
# ២០១៧ - ២០៣០

**បន្តលើកកម្ពស់សុខុមាលភាពរបស់មនុស្សវ័យចាស់កម្ពុជា**

បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ
នាថ្ងៃទី២៥ ខែសីហា ឆ្នាំ២០១៧

# មាតិកា


មាតិកា ........ i

បញ្ជីតារាង ........ iii

បញ្ជីរូបភាព ........ iii

ឧបសម្ព័ន្ធ ........ iii

អារម្ភកថា ........ iv

១- សេចក្តីផ្តើម ........ ១

២- មូលហេតុនៃការធ្វើបច្ចុប្បន្នកម្មគោលនយោបាយមនុស្សចាស់ឆ្នាំ២០០៣ ........ ៣

៣- ស្ថានភាពប្រជាសាស្ត្រនៃការឈានទៅរកវ័យចាស់នៅកម្ពុជា ........ ៤

៣.១- កត្តាដែលបង្កឲ្យកើតមានករណីប្រជាជនវ័យចាស់ ........ ៤

៣.២- ការកើនឡើងនៃសមាមាត្រប្រជាជនវ័យចាស់ ........ ៧

៣.៣- ដំណើរឈានចូលភាពជរារបស់ប្រជាជនវ័យចាស់ ........ ៩

៣.៤- ស្ត្រីភាវូបនីយកម្មនៃដំណើរឈានចូលវ័យចាស់ ........ ១១

៣.៥- ទិដ្ឋភាពភូមិសាស្ត្រនៃប្រជាជនវ័យចាស់ ........ ១២

៣.៦- ផលធៀបគាំទ្រសក្តានុពល ........ ១៣

៤- បញ្ហាចម្បងៗពាក់ព័ន្ធនឹងដំណើរឈានចូលវ័យចាស់ជរា ........ ១៦

៤.១- សន្តិសុខហិរញ្ញវត្ថុ ........ ១៦

៤.២- សុខភាពនិងសុខុមាលភាព ........ ១៨

៤.៣- របៀបរបបការរស់នៅ ........ ១៩

៤.៤- បរិស្ថានអំណោយផល ........ ២១

៤.៥- វ័យចាស់សកម្មនិងសមាគមមនុស្សចាស់ ........ ២២

៤.៦- ទំនាក់ទំនងអន្តរជំនាន់ ........ ២២

៤.៧. ការរំលោភបំពាន ការមិនអើពើ និងអំពើហិង្សាលើមនុស្សចាស់ ........ ២៣

៤.៨- ស្ថានភាពមានអាសន្ន ........ ២៥

៤.៩- ការត្រៀមខ្លួនរបស់មនុស្សវ័យក្មេងសម្រាប់ការឈានចូលវ័យចាស់ ........ ២៥

៥- ក្របខ័ណ្ឌគោលនយោបាយនិងគោលការណ៍ណែនាំ ....................................................២៧
៥.១- បរិការណ៍ ....................................................................................................២៧
៥.២- គោលការណ៍ណែនាំ.........................................................................................២៩
៦- ចក្ខុវិស័យនិងគោលដៅ .......................................................................................៣១
៦.១- ចក្ខុវិស័យ .....................................................................................................៣១
៦.២- គោលដៅ.......................................................................................................៣១
៦.៣- ទិសដៅនិងយុទ្ធសាស្ត្រ........................................................................................៣១
៦.៣.១- អាទិភាពទី១ : ការធានាឲ្យបាននូវសន្តិសុខហិរញ្ញវត្ថុ ......................................៣១
៦.៣.២- អាទិភាពទី២ : សុខភាពនិងសុខុមាលភាព................................................... ៣៣
៦.៣.៣- អាទិភាពទី៣ : របៀបរបបការរស់នៅ.........................................................៣៥
៦.៣.៤- អាទិភាពទី៤ : បរិស្ថានអំណោយផល ........................................................៣៦
៦.៣.៥- អាទិភាពទី៥ : សមាគមមនុស្សចាស់និងវ័យចាស់សកម្ម ................................ ៣៧
៦.៣.៦- អាទិភាពទី៦ : ទំនាក់ទំនងអន្តរជំនាន់........................................................៣៨
៦.៣.៧- អាទិភាពទី៧ : ការរំលោភបំពាននិងអំពើហិង្សាលើមនុស្សចាស់ ........................៣៩
៦.៣.៨- អាទិភាពទី៨ : ស្ថានភាពមានអាសន្ន ....................................................... ៤០
៦.៣.៩- អាទិភាពទី៩ : ការត្រៀមខ្លួនរបស់ប្រជាជនវ័យក្មេង ....................................... ៤១
៧- ការរៀបចំស្ថាប័នដើម្បីអនុវត្តគោលនយោបាយ .....................................................៤៣
៧.១- គណៈកម្មាធិការជាតិកម្ពុជាដើម្បីមនុស្សចាស់.......................................................៤៣
៧.២- តួនាទីនិងភារកិច្ចទទួលខុសត្រូវរបស់ក្រសួងស្ថាប័នពាក់ព័ន្ធ និងភ្នាក់ងារដទៃទៀត ....... ៤៤
៧.៣- ការរៀបចំស្ថាប័ននៅថ្នាក់ក្រោមជាតិ................................................................. ៥១
៧.៤- ការតាមដានត្រួតពិនិត្យនិងការវាយតម្លៃ ............................................................៥២
៧.៥- ជំហានបន្ទាប់.................................................................................................៥២
សទ្ទានុក្រម.................................................................................................. ..៧៦

# បញ្ជីតារាង

តារាងទី១ : ស្ថានភាពបម្រែបម្រួលនៃប្រជាជនវ័យចាស់នៅកម្ពុជា ........................................ ៩
តារាងទី២ : ភាគរយនៃស្ត្រីក្នុងចំណោមប្រជាជនវ័យចាស់អាយុ៦០ឆ្នាំឡើងនៅក្នុងអាស៊ាន ...... ១២
តារាងទី៣ : ផលធៀបគាំទ្រសក្តានុពលនៅតំបន់ទីប្រជុំជននិងតំបន់ជនបទ .......................... ១៥
តារាងទី៤ : សកម្មភាពសេដ្ឋកិច្ចនិងស្ថានភាពការងាររបស់មនុស្សចាស់ ............................... ១៧

# បញ្ជីរូបភាព

រូបភាពទី១ : ការព្យាករអំពីលទ្ធភាពមានកូនសរុប(១៩៩០-២០៣០) ................................... ៥
រូបភាពទី២ : អាយុកាលសង្ឃឹមរស់របស់បុរសនិងស្ត្រីកម្ពុជា.................................................. ៦
រូបភាពទី៣ : ការព្យាករអត្រាកំណើនប្រចាំឆ្នាំនៃប្រជាជនសរុបនិងប្រជាជនវ័យចាស់................. ៧
រូបភាពទី៤ : សមាមាត្រប្រជាជនវ័យចាស់ធៀបនឹងប្រជាជនសរុប ......................................... ៨
រូបភាពទី៥ : ផលធៀបគាំទ្រឪពុកម្តាយ........................................................................ ១០
រូបភាពទី៦ : និន្នាការនៃការចូលរួមកម្លាំងពលកម្មតាមអាយុ ............................................. ១១
រូបភាពទី៧ : ការថយចុះនៃកិច្ចគាំពារពីសំណាក់ក្រុមគ្រួសារ................................................ ១៤
រូបភាពទី៨ : អាំងស៊ីដង់នៃពិការភាពបុរសនិងស្ត្រីវ័យចាស់.................................................. ១៨
រូបភាពទី៩ : ស្ថានភាពអាពាហ៍ពិពាហ៍របស់បុរសនិងស្ត្រីវ័យចាស់.......................................២០
រូបភាពទី១០ : ភាគរយនៃបុរសនិងស្ត្រីវ័យចាស់ដែលជួបការរំខានក្នុងចំណងអាពាហ៍ពិពាហ៍ ....២០

# ឧបសម្ព័ន្ធ

ឧបសម្ព័ន្ធ : ម៉ាទ្រីសនៃការទទួលខុសត្រូវតាមវិស័យរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ.................... ៥៦

# អារម្ភកថា

វប្បធម៌ប្រពៃណីខ្មែរ បានឲ្យតម្លៃខ្ពស់ទៅលើការគោរពនិងមើលថែទាំមនុស្សវ័យចាស់។ ក្នុងស្មារតីនេះ រាជរដ្ឋាភិបាល ជានិច្ចកាលតែងតែទទួលស្គាល់នូវភាពចាំបាច់ក្នុងការធានានូវគុណភាពជីវិតរបស់មនុស្សវ័យចាស់ ទោះបីជាប្រជាជនវ័យចាស់នៅកម្ពុជាមានសមាមាត្រទាបបើធៀបទៅនឹងបណ្ដាប្រទេសអាស៊ានដទៃទៀត។ បន្ទាប់ពីបានគាំទ្រសេចក្ដីប្រកាសនៃមហាសន្និបាតពិភពលោកលើកទីពីរស្ដីពីមនុស្សវ័យចាស់នៅទីក្រុងម៉ាឌ្រីដឆ្នាំ២០០២ រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់រៀបចំបង្កើតគោលនយោបាយមនុស្សចាស់ ដែលត្រូវបានអនុម័តនៅឆ្នាំ២០០៣។ ចាប់ពីពេលនោះមកស្ថានភាពប្រជាសាស្ត្រមានការផ្លាស់ប្ដូរយ៉ាងច្រើន ជាពិសេស គឺការប្រែប្រួលពាក់ព័ន្ធនឹងប្រជាជនវ័យចាស់ដែលសំដៅចំពោះប្រជាជនដែលមានអាយុ៦០ឆ្នាំឡើង។ ជាក់ស្ដែង មនុស្សវ័យចាស់កំពុងមានការកើនឡើង គិតជាបរិមាណនិងជាសមាមាត្រនៃប្រជាជនសរុប ហើយការធ្វើចំណោលបង្ហាញថាសមាមាត្រនៃប្រជាជនវ័យចាស់ធៀបនឹងចំនួនប្រជាជនសរុប នឹងបន្តកើនឡើងក្នុងល្បឿនមួយយ៉ាងលឿននៅក្នុងរយៈពេលពី១៥ទៅ២០ឆ្នាំខាងមុខទៀត។

ដោយទទួលស្គាល់ពីដំណើរប្រែប្រួល ដែលមិនអាចជៀសផុតនៃការវិវត្តផ្នែកប្រជាសាស្ត្រនេះ ជាពិសេស ការទទួលស្គាល់ថា ការកើនឡើងនៃសមាមាត្រមនុស្សវ័យចាស់ ដែលជាដំណើរឈានទៅរកប្រជាជនវ័យចាស់ មិនត្រឹមតែជះឥទ្ធិពលទៅលើមនុស្សវ័យចាស់ខ្លួនឯងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជះឥទ្ធិពលលើគ្រប់ផ្នែកទាំងអស់នៃសង្គមនិងសេដ្ឋកិច្ចជាតិទាំងមូល ហេតុនេះហើយរាជរដ្ឋាភិបាលបានពិនិត្យមើលនិងកែសម្រួលឡើងវិញនូវគោលនយោបាយសម្រាប់មនុស្សចាស់ឆ្នាំ២០០៣។ ក្នុងន័យនេះ គោលនយោបាយដែលត្រូវបានកែសម្រួលឡើងវិញនេះ ត្រូវបានប្ដូរឈ្មោះទៅជា **គោលនយោបាយជាតិស្ដីពីមនុស្សវ័យចាស់ ២០១៧-២០៣០**។ គោលនយោបាយជាតិស្ដីពីមនុស្សវ័យចាស់នេះ គឺជាផែនទីបង្ហាញផ្លូវដ៏សំខាន់មួយ ដែលត្រូវបានរៀបចំឡើងដើម្បីដោះស្រាយបញ្ហាជាច្រើនដែលកំពុងកើតមានពីដំណើរឈានទៅរកវ័យចាស់នៅក្នុងក្របខណ្ឌរួមនៃការអភិវឌ្ឍជាតិ រួមមាន **យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨និងគោលនយោបាយជាតិប្រជាជន ២០១៦-២០៣០**។

ក្នុងគោលបំណងធានាឲ្យមានគោលនយោបាយមនុស្សវ័យចាស់មួយ ដែលមានវិសាលភាពទូលំទូលាយ និងដោយគិតគូរពិចារណាអំពីការធ្វើចំណោលបម្រែបម្រួលប្រជាសាស្ត្រ និងភាពចាំបាច់ក្នុងការបញ្ចូលបញ្ហាមនុស្សវ័យចាស់ទៅក្នុងដំណើរការរៀបចំផែនការអភិវឌ្ឍន៍ គោលនយោបាយនេះត្រូវបានកែសម្រួល ដោយផ្អែកលើទស្សនាទានគន្លឹះបី៖ (ទី១) លុបបំបាត់ការរើសអើងដែលផ្អែកទៅលើអាយុដើម្បីឲ្យមនុស្សវ័យចាស់ទទួលបាននូវការធានាសិទ្ធិដូចគ្នានឹងមនុស្សវ័យក្មេង និងត្រូវបានគេប្រតិបត្តិស្មើគ្នាចំពោះពួកគាត់គ្រប់ករណីទាំងអស់ (ទី២) ធានានូវសមភាពយេនឌ័រដោយផ្ដោតបន្ថែមទៀតទៅលើស្ត្រី ដែលមានចំនួនភាគច្រើនក្នុងចំណោមប្រជាជនវ័យចាស់ ហើយមានភាព

ងាយរងគ្រោះជាងបុរស និង (ទី៣) លើកកម្ពស់ទំនាក់ទំនងអន្តរជំនាន់ដើម្បីរក្សាបាននូវភាពរឹងមាំនៃចំណងគ្រួសារ ដែលជានិមិត្តរូបនៃវប្បធម៌ខ្មែរ។

ចក្ខុវិស័យរួមនៃគោលនយោបាយនេះ គឺការធានាថា មនុស្សវ័យចាស់អាចចូលរួមដោយមានសេរីភាព និងកិត្តិយសពេញលេញ នៅក្នុងសកម្មភាពគ្រួសារ សហគមន៍ សេដ្ឋកិច្ច សង្គម សាសនា និងនយោបាយ ហើយធានាថាមនុស្សវ័យក្មេងទទួលបាននូវចំណេះដឹង ដែលអាចជួយឲ្យពួកគាត់អាចដឹកនាំជីវិតផ្ទាល់ខ្លួនប្រកបដោយផលិតភាព សុខភាពល្អ សកម្ម និងកិត្តិយស នៅក្នុងវ័យចាស់។

ក្នុងស្មារតីនេះ រាជរដ្ឋាភិបាល ប្តេជ្ញាចិត្តផ្តល់នូវការគាំទ្រចាំបាច់ និងបង្កលក្ខណៈឲ្យមានបរិយាកាសផ្នែកគោលនយោបាយនិងកម្មវិធីសម្រាប់ការអនុវត្តគោលនយោបាយនេះ។ ជាការពិតការដាក់ចេញនូវគោលនយោបាយនេះ គឺជាការងារសំខាន់ ប៉ុន្តែ ការប្រែក្លាយគោលនយោបាយឲ្យទៅជា សកម្មភាពជាក់ស្តែង តាមរយៈការរៀបចំផែនការសកម្មភាពនិងការអនុវត្តផែនការសកម្មភាពនេះ គឺជាកត្តាចាំបាច់មិនអាចខ្វះបានដើម្បីសម្រេចបាននូវគោលដៅចុងក្រោយ ក្នុងការជួយដល់មនុស្សវ័យចាស់ឲ្យមានការចូលរួមដោយសេរីនិងដោយកិត្តិយស ក្នុងសកម្មភាពអភិវឌ្ឍនានា ជាពិសេស សកម្មភាពពាក់ព័ន្ធនឹងការលើកកម្ពស់សុខុមាលភាពរបស់ប្រជាជនវ័យចាស់។

ក្នុងន័យនេះ ការអនុវត្តនូវគោលនយោបាយនេះ ទាមទារឲ្យមានកិច្ចខំប្រឹងប្រែងរួមគ្នាពីគ្រប់អ្នកមានចំណែកពាក់ព័ន្ធទាំងអស់ រួមមាន វិស័យសាធារណៈនិងវិស័យឯកជន ក៏ដូចជាអង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍ និងបណ្តាញសមាគមមនុស្សចាស់ដែលមាននៅទូទាំងប្រទេស។ ដូច្នេះ ខ្ញុំសូមជំរុញដល់គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធទាំងអស់ ត្រូវកំណត់អាទិភាពក្នុងការអនុវត្តគោលនយោបាយនេះ ដើម្បីជួយដល់មនុស្សវ័យចាស់ឲ្យទទួលបាននូវគុណភាពជីវិតដែលពួកគាត់សមនឹងទទួល សម្រាប់ការបានចូលរួមចំណែកពេញមួយជីវិតរបស់ពួកគាត់ក្នុងការកសាងប្រទេសជាតិ។ រាជរដ្ឋាភិបាល តាមរយៈ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នឹងធានាឲ្យមានការសម្របសម្រួលប្រកបដោយប្រសិទ្ធភាពក្នុងដំណើរការនៃការអនុវត្ត **គោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ ២០១៧-២០៣០** ជាមួយនឹងក្រសួងស្ថាប័នពាក់ព័ន្ធ និងអ្នកមានចំណែកពាក់ព័ន្ធទាំងអស់។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

## ១- សេចក្តីផ្តើម

**១-** ការកើនឡើងនៃចំនួនប្រជាជនវ័យចាស់បានកើតឡើងបន្តិចម្តងៗ ចាប់តាំងពីសតវត្សមុន នៅក្នុងបណ្តាប្រទេសអភិវឌ្ឍជាច្រើន។ នៅដើមទសវត្សរ៍ទី១០នៃសតវត្សរ៍ទី២០ ប្រជាជនវ័យចាស់បានចាប់ផ្តើមក្លាយជាកង្វល់នៅក្នុងប្រទេសអភិវឌ្ឍមួយចំនួន ហើយស្ថានភាពនេះបានក្លាយជាបញ្ហាប្រឈមចម្បងនៅក្នុងប្រទេសកំពុងអភិវឌ្ឍចាប់តាំងពីទស្សវត្សរ៍ទី១នៃសតវត្សរ៍ទី២១។ ជាទ្រឹស្តី ការកើនឡើងនៃប្រជាជនវ័យចាស់ គឺជាការកើនឡើងអាយុកណ្តាលនៃប្រជាជនសរុប ដែលបណ្តាលមកពីការធ្លាក់ចុះនៃអត្រាលទ្ធភាពមានកូនរបស់ស្ត្រីនិងការកើនឡើងនៃអាយុកាលសង្ឃឹមរស់។ ការកើនឡើងនៃប្រជាជនវ័យចាស់នៅកម្ពុជា បានចាប់ផ្តើមក្រោយគេបន្តិច បើធៀបនឹងបណ្តាប្រទេសកំពុងអភិវឌ្ឍដទៃទៀត ដោយសន្ទុះនៃការកើនឡើងរបស់ប្រជាជនវ័យចាស់បានចាប់ផ្តើមមាននៅក្នុងទសវត្សរ៍ទីមួយនៃសតវត្សរ៍នេះ។ ក្នុងបរិការណ៍នេះ បន្ទាប់ពីការចុះហត្ថលេខាលើ**សេចក្តីថ្លែងការណ៍នយោបាយស្តីពីមនុស្សវ័យចាស់** នៅឯសន្និបាតពិភពលោកលើកទី២ នៅទីក្រុងម៉ាឌ្រីតឆ្នាំ២០០២ និងក្រោយពីបានអនុម័តលើ **ផែនការសកម្មភាពអន្តរជាតិទីក្រុងម៉ាឌ្រីតស្តីពីមនុស្សវ័យចាស់ឆ្នាំ២០០២**មក រាជរដ្ឋាភិបាលកម្ពុជាបានចាត់វិធានការជាជំហានៗដើម្បីរៀបចំគោលនយោបាយសម្រាប់មនុស្សចាស់ ដែលត្រូវបានអនុម័តនៅឆ្នាំ២០០៣។

**២-** គោលបំណងនៃគោលនយោបាយសម្រាប់មនុស្សចាស់ឆ្នាំ២០០៣ គឺដើម្បីធានាឲ្យបានថាមនុស្សចាស់មានលទ្ធភាពទទួលបានឱកាសចូលរួមក្នុងការអភិវឌ្ឍ និងទទួលបានអត្ថប្រយោជន៍ពីការអភិវឌ្ឍប្រទេសរបស់ខ្លួន។ គោលបំណងនេះ គឺអនុលោមតាមគោលការណ៍ណែនាំដែលមានចែងនៅក្នុងផែនការសកម្មភាពអន្តរជាតិទីក្រុងម៉ាឌ្រីតស្តីពីមនុស្សវ័យចាស់ ដែលត្រូវបានអនុម័តនៅក្នុងសន្និបាតពិភពលោកលើកទី២ ស្តីពីមនុស្សវ័យចាស់នៅទីក្រុងម៉ាឌ្រីតឆ្នាំ២០០២។ ប៉ុន្តែ គោលនយោបាយសម្រាប់មនុស្សចាស់ឆ្នាំ២០០៣ ពុំបានកំណត់ក្រុមគោលដៅនិងនិយមន័យមនុស្សចាស់ទេ។ គោលនយោបាយនេះ មិនបានកំណត់និយមន័យមនុស្សចាស់គឺដោយឈរលើហេតុផលថានិយមន័យនេះ បានកំណត់រួចហើយនៅក្នុងផែនការសកម្មភាពអន្តរជាតិទីក្រុងម៉ាឌ្រីតស្តីពីមនុស្សវ័យចាស់ (MIPAA)។ សន្និបាតទីក្រុងម៉ាឌ្រីតបានសម្រេចជាឯកច្ឆ័ន្ទអំពីនិយមន័យមនុស្សចាស់ ដោយផ្អែកលើនិយមន័យអាយុពេញ។ តាមនិយមន័យនេះ មនុស្សចាស់ជាមនុស្សដែលមានអាយុពេញចាប់ពី៦០ឆ្នាំឡើងទៅ។ ទោះជាយ៉ាងនេះក្តី ប្រទេសកំពុងអភិវឌ្ឍមិនត្រូវបានតម្រូវឲ្យកំណត់យកនិយមន័យនេះជាផ្លូវការទេ ប៉ុន្តែភាគច្រើននៃបណ្តាប្រទេសដែលមានការអភិវឌ្ឍតិចតួច បានអនុម័ត យកអាយុនេះ ជា ″អាយុកំណត់″ ដើម្បីឲ្យនិយមន័យសម្រាប់ប្រជាជនវ័យចាស់។

**៣-** នៅដើមសតវត្សរ៍នេះ ប្រជាជនកម្ពុជាដែលមានអាយុ៦០ឆ្នាំឡើង មានចំនួនប្រមាណ ៦០០ ០០០នាក់ ស្មើនឹងប្រមាណ៦ភាគរយនៃប្រជាជនសរុប[១]។ ទោះបីជានៅក្នុងទសវត្សរ៍ទី១នៃសតវត្សរ៍ទី២១ កម្ពុជាជាប្រទេសមួយក្នុងចំណោមប្រទេសមួយចំនួនតូច ដែលមានសមាមាត្រប្រជាជនវ័យចាស់ទាបក៏ដោយ ក៏រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលនយោបាយសម្រាប់មនុស្សចាស់ ឆ្នាំ២០០៣ ដែលជាការឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តរបស់កម្ពុជាក្នុងការចូលរួមអនុវត្តស្មារតីទីក្រុងម៉ាឌ្រីត ដើម្បីធានាថា មនុស្សវ័យចាស់គ្រប់រូបរស់នៅក្នុងជីវិតមួយប្រកបដោយសេចក្តីថ្លៃថ្នូរ ដូចគ្នានឹងមនុស្សវ័យក្មេងដែរ។

**៤-** អាយុកំណត់សម្រាប់ឲ្យនិយមន័យទៅលើប្រជាជនវ័យចាស់ នៅមិនទាន់មានភាពច្បាស់លាស់នៅឡើយ។ ឯកសារមួយចំនួនដូចជា ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ២០១៤-២០១៨ និងគោលនយោបាយជាតិប្រជាជន ឆ្នាំ២០១៦-២០៣០កំណត់ថា មនុស្សមានអាយុ៦៥ឆ្នាំឡើងទៅជាមនុស្សវ័យចាស់។ របាយការណ៍ស្តីពីប្រជាជនវ័យចាស់នៃអង្កេតចន្លោះជំរឿននៃប្រជារាស្ត្រកម្ពុជា ឆ្នាំ២០១៣ និងគោលនយោបាយនិងយុទ្ធសាស្ត្រសុខាភិបាលជាតិសម្រាប់ថែទាំសុខភាពមនុស្សចាស់ ឆ្នាំ២០១៦ កំណត់ថា អ្នកមានអាយុ៦០ឆ្នាំឡើងទៅជាមនុស្សចាស់។ យោងច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា[២] អនុសាសន៍របស់ MIPAA សេចក្តីប្រកាសទីក្រុងកូឡាឡាំពួស្តីពីមនុស្សចាស់ឆ្នាំ២០១៥ គោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ ២០១៧-២០៣០ កំណត់យកអាយុ៦០ឆ្នាំ ជាមនុស្សចាស់។

---

[១] ប្រជាជនវ័យចាស់នៅក្នុងប្រទេសកម្ពុជា(របាយការណ៍លេខ១៣ វិភាគលទ្ធផលការស្ទង់មតិចន្លោះជំរឿននៃប្រជារាស្ត្រកម្ពុជាឆ្នាំ២០១៣ របស់វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ, រាជធានីភ្នំពេញឆ្នាំ២០១៤

[២] ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ជំពូកទី៧(ការចូលនិវត្តន៍) មាត្រា៥៤ចែងថា "អ្នករាជការទាំងពីរភេទត្រូវដាក់ឲ្យចូលនិវត្តន៍ជាកំហិតពេលដល់អាយុ៥៥ឆ្នាំ។ អាយុកំហិតនេះអាចរំកិលឡើងដល់៦០ឆ្នាំបើលក្ខន្តិកៈដោយឡែកបានកំណត់"

## ២- មូលហេតុនៃការធ្វើបច្ចុប្បន្នកម្មគោលនយោបាយមនុស្សចាស់ឆ្នាំ២០០៣

**៥-** ស្ថានភាពប្រជាសាស្ត្រដែលកត់សម្គាល់ដោយប្រជាជនវ័យចាស់ចំនួនតិចតួច ដែលកើនឡើងយឺតៗរហូតដល់ដើមសតវត្សរ៍ទី២១ បច្ចុប្បន្ននេះ មានការផ្លាស់ប្តូរ ដែលតម្រូវឲ្យធ្វើការកែសម្រួលគោលនយោបាយសម្រាប់មនុស្សចាស់ឆ្នាំ២០០៣ ដើម្បីគិតគូរឆ្លើយតបនឹងបញ្ហាជាច្រើនពាក់ព័ន្ធនឹងភាពចាស់ជរា។ រាជរដ្ឋាភិបាលទទួលស្គាល់ភាពចាំបាច់ក្នុងការកែសម្រួលឡើងវិញនូវគោលនយោបាយសម្រាប់មនុស្សចាស់។ ទន្ទឹមនឹងនេះ ដោយហេតុថា ដំណើរការនៃការឈានទៅរកភាពចាស់ជរា ត្រូវបានកត់សម្គាល់ឃើញថា បានជះឥទ្ធិពលលើគ្រប់ក្រុមអាយុទាំងអស់នៃប្រជាជននិងគ្រប់វិស័យទាំងអស់នៃសេដ្ឋកិច្ចនោះ គោលនយោបាយត្រូវតែមានវិសាលភាពធំទូលាយ លើសពីការផ្តោតការយកចិត្តទុកដាក់តែទៅលើជនចាស់ជរាឬមនុស្សចាស់។ ទោះបីជា មនុស្សចាស់នៅតែជាគោលដៅចម្បងដែលត្រូវទទួលផលប្រយោជន៍ពីគោលនយោបាយនេះក៏ដោយ ក៏ការគិតគូរដោះស្រាយផលប៉ះពាល់នៃប្រជាជនវ័យចាស់ដែលមានលក្ខណៈទូលំទូលាយជាងមុន គឺជាការងារដ៏មានសារៈសំខាន់ផងដែរ។ បញ្ហានេះ រួមមាន ការពាក់ព័ន្ធជាមួយនឹងសមាជិកគ្រួសារវ័យក្មេង ក្នុងរូបភាពជាការគាំទ្រនិងការថែទាំ ដែលសមាជិកគ្រួសារវ័យក្មេងត្រូវផ្តល់ទៅឲ្យមនុស្សចាស់។ ដូចនេះ គោលនយោបាយដែលត្រូវបានកែសម្រួលថ្មី ត្រូវបានប្តូរឈ្មោះទៅជា "គោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ ២០១៧-២០៣០"។

**៦-** រាជរដ្ឋាភិបាលកម្ពុជា ប្តេជ្ញាចិត្តបន្តអនុវត្តគោលនយោបាយសម្រាប់មនុស្សចាស់។ ការប្តេជ្ញាចិត្តនេះត្រូវបានគូសបញ្ជាក់ឡើងវិញនៅក្នុងឯកសារនានា ដូចជា យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ និង គោលនយោបាយជាតិប្រជាជន២០១៦-២០៣០។ មូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន(UNFPA) និង អង្គការមនុស្សចាស់អន្តរជាតិ (HelpAge International) ប្តេជ្ញាចិត្តជួយដល់រាជរដ្ឋាភិបាល ក្នុងការរៀបចំគោលនយោបាយ ដើម្បីឆ្លើយតបទៅនឹងបញ្ហាពាក់ព័ន្ធជាមួយមនុស្សវ័យចាស់ ដោយផ្អែកលើការវិភាគពីបម្រែបម្រួលស្ថានភាពប្រជាសាស្ត្រ។ ចំណុចដៅមួយក្នុងចំណោមចំណុចដៅនានា ដែលត្រូវបានដាក់បញ្ចូលទៅក្នុងកម្មវិធីប្រចាំប្រទេសរបស់មូលនិធិសហប្រជាជាតិសម្រាប់ប្រជាជន(២០១៦-២០១៨) គឺ "គោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ ដែលនឹងត្រូវអនុម័តដោយរាជរដ្ឋាភិបាលក្នុងឆ្នាំ២០១៧"[៣]។

[៣] ផែនការសកម្មភាពកម្មវិធីប្រចាំប្រទេស : ២០១៦-២០១៨(រាជរដ្ឋាភិបាលកម្ពុជា និង UNFPA រាជធានីភ្នំពេញ)

## ៣- ស្ថានភាពប្រជាសាស្ត្រនៃការឈាននៅរកវ័យចាស់នៅកម្ពុជា

**៧-** ចំហាកប្រជាសាស្ត្រនៅកម្ពុជានាពេលបច្ចុប្បន្ន មានភាពខុសប្លែកគ្នាយ៉ាងខ្លាំងពីចំហាកប្រជាសាស្ត្រកាលពីដើមសតវត្សរ៍នេះ ដែលស្តែងឡើងតាមរូបភាពនៃការថយចុះនៃចំនួនប្រជាជនអាយុក្រោម១៥ឆ្នាំ។ នៅឆ្នាំ១៩៩៨ ប្រជាជនកម្ពុជាអាយុក្រោម១៥ឆ្នាំមានសមាមាត្រ៤៣ភាគរយ នៃប្រជាជនសរុប ឯប្រជាជនក្នុងវ័យធ្វើការមានសមាមាត្រ៥២ភាគរយ ហើយប្រជាជនវ័យចាស់អាយុ៦០ឆ្នាំឡើងមានសមាមាត្រត្រឹមតែ៥ភាគរយនៃប្រជាជនសរុប។ នៅឆ្នាំ២០១៣ សមាមាត្រប្រជាជនកម្ពុជាអាយុក្រោម១៥ឆ្នាំ បានបន្តថយចុះដល់២៩ភាគរយនៃប្រជាជនសរុប ឯសមាមាត្រប្រជាជនក្នុងវ័យធ្វើការបានកើនដល់៦៣ភាគរយ ហើយប្រជាជនវ័យចាស់បានកើនដល់៨ភាគរយ នៃប្រជាជនសរុប។ ភាពខុសគ្នានេះមានលក្ខណៈគួរឲ្យកត់សម្គាល់ ជាពិសេស នៅក្នុងករណីនៃការឈានចូលទៅវ័យចាស់របស់ប្រជាជនដែលកំពុងស្ថិតក្នុងវ័យធ្វើការសព្វថ្ងៃ។ សមាមាត្រនៃមនុស្សចាស់ធៀបនឹងប្រជាជនសរុប មានការកើនឡើងក្នុងអត្រាខ្ពស់ជាងមុន(ពីឆ្នាំ១៩៩៨ដល់២០០៨ ប្រជាជនវ័យចាស់បានកើនឡើងក្នុងអត្រា៣ភាគរយប្រចាំឆ្នាំ ហើយពីឆ្នាំ២០០៨ដល់២០១៣ អត្រាកំណើនប្រចាំឆ្នាំរបស់ប្រជាជនវ័យចាស់ស្មើរនឹង៥ភាគរយ) ហើយនិន្នាការនៃការកើនឡើងនេះត្រូវបានព្យាករថានឹងមានជាបន្តទៀត។ ពីឆ្នាំ២០២០ដល់២០៣០ ប្រជាជនវ័យចាស់នឹងមានកំណើនប្រចាំឆ្នាំជិត៤ភាគរយ ក្នុងខណៈដែលប្រជាជនក្នុងវ័យធ្វើការនឹងមានកំណើនប្រហែល១ភាគរយប្រចាំឆ្នាំ ហើយប្រជាជនអាយុក្រោម១៥ឆ្នាំនឹងមានកំណើនអវិជ្ជមាន។ បញ្ហាពាក់ព័ន្ធជាមួយនឹងមនុស្សវ័យចាស់ដែលមិនធ្លាប់មានឬដែលមិនសូវមានសារៈសំខាន់កាលពីពេលមុន ឥឡូវនេះចាប់ផ្តើមក្លាយជាបញ្ហាប្រឈមដែលត្រូវដោះស្រាយ។

### ៣.១- កត្តាដែលបង្កឲ្យកើតមានករណីប្រជាជនវ័យចាស់

**៨-** កត្តាពីរដែលជួយពន្យល់អំពីការលេចឡើងនូវបាតុភូតប្រជាជនវ័យចាស់ គឺការថយចុះអត្រាមានកូននិងភាពប្រសើរឡើងនៃអាយុកាលសង្ឃឹមរស់។ ការថយចុះអត្រាលទ្ធភាពមានកូន ធ្វើឲ្យមានការថយចុះចំនួនកុមារដែលបានកើត ហើយជាលទ្ធផល ក៏ធ្វើឲ្យអត្រាកំណើនប្រជាជនជាកុមារមានការថយចុះផងដែរ។ អាយុកាលសង្ឃឹមរស់មានភាពប្រសើរឡើង មានន័យថា មនុស្សអាចរស់បានអាយុកាន់តែវែង ហើយការកើនឡើងនៃសមាមាត្រប្រជាជនដែលអាចរស់នៅរហូតដល់វ័យចាស់ និងបន្តរស់នៅក្នុងរយៈពេលកាន់តែវែងជាងមុនក្រោយពីបានឈានដល់អាយុ៦០ឆ្នាំហើយ។ ហេតុនេះ ប្រជាជនវ័យចាស់នឹងកើនឡើងក្នុងអត្រាលឿនជាងប្រជាជនវ័យក្មេង។

**៩-** លទ្ធភាពកាន់តែច្រើនក្នុងការទទួលបានសេវាសុខភាពបន្តពូជប្រកបដោយគុណភាព បានធ្វើឲ្យលទ្ធភាពមានកូន មានការថយចុះគួរឲ្យកត់សម្គាល់និងជាបន្តបន្ទាប់ ក្នុងរយៈពេលបីទសវត្សរ៍ចុងក្រោយនេះ។ ដូចបានបង្ហាញនៅក្នុងរូបភាពទី១ អត្រាលទ្ធភាពមានកូនសរុប ដែលត្រូវបានឲ្យនិយមន័យថា

ជាចំនួនមធ្យមនៃកូនដែលបានកើតជាមួយស្ត្រីម្នាក់ក្នុងអំឡុងអាយុអាចមានកូន(១៥-៤៩ឆ្នាំ) បានថយចុះពី៥,៧នៅឆ្នាំ១៩៩០ មកនៅត្រឹម២,៧នៅឆ្នាំ២០១៤ ហើយតួលេខនេះត្រូវបានព្យាករថានឹងថយមកនៅត្រឹមកម្រិតជំនួសក្នុងឆ្នាំ២០២៥ រួចហើយចំនួននេះនឹងបន្តថយចុះតិចតួចជាបណ្តើរៗ ថែមទៀត។

**រូបភាពទី១ : ការព្យាករអំពីលទ្ធភាពមានកូនសរុប(១៩៩០-២០៣០)**




**ប្រភព** : ការព្យាករចំនួនប្រជាជនកម្ពុជា : របាយការណ៍លេខ១២នៃជំរឿនទូទៅនូវប្រជាពលរដ្ឋកម្ពុជាឆ្នាំ២០០៨

**១០-** ស្របពេលជាមួយគ្នានេះដែរ អាយុកាលសង្ឃឹមរស់មានការកើនឡើង ហើយនិន្នាការនេះនឹងបន្តកើនឡើង។ អាយុកាលសង្ឃឹមរស់បានកើនឡើងពី៥៤ឆ្នាំសម្រាប់បុរសនិង៥៨ឆ្នាំសម្រាប់ស្ត្រីនៅឆ្នាំ១៩៩៨ ដល់៦៧ឆ្នាំសម្រាប់បុរសនិង៧១ឆ្នាំសម្រាប់ស្ត្រីនៅឆ្នាំ២០១៣។ អាយុកាលសង្ឃឹមរស់ នេះត្រូវបានព្យាករថានឹងកើនឡើងជាបន្តបន្ទាប់ ដោយអាយុកាលសង្ឃឹមរស់របស់ស្ត្រី គឺលើសពីអាយុកាលសង្ឃឹមរស់របស់បុរសនៅក្នុងកំលុងពេលទាំងមូលនៃការព្យាករ។ តួលេខព្យាករសម្រាប់បណ្តាឆ្នាំក្រោយៗ មានបង្ហាញក្នុងរូបភាពទី២។

### រូបភាពទី២ : អាយុកាលសង្ឃឹមរស់របស់បុរសនិងស្ត្រីកម្ពុជា




**ប្រភព :** ជំរឿនទូទៅនូវប្រជាពរស្ត្រកម្ពុជាឆ្នាំ១៩៩៨និង២០០៨ និងអង្កេតចន្លោះជំរឿននៃប្រជាពរស្ត្រកម្ពុជាឆ្នាំ២០០៣និង២០១៣

**១១-** ការធ្លាក់ចុះជាបន្តបន្ទាប់នៃលទ្ធភាពមានកូន រួមជាមួយនឹងការកើនឡើងជាបន្តបន្ទាប់នៃអាយុកាលសង្ឃឹមរស់ បានបណ្តាលឲ្យប្រជាជនវ័យចាស់កើនឡើង ក្នុងអត្រាមួយខ្ពស់ជាងអត្រាកំណើនប្រជាជនសរុប ដូចមានបង្ហាញក្នុងរូបភាពទី៣។

រូបភាពទី៣ : ការព្យាករអត្រាកំណើនប្រចាំឆ្នាំនៃប្រជាជនសរុបនិងប្រជាជនវ័យចាស់




**ប្រភព :** ការព្យាករចំនួនប្រជាជនកម្ពុជា : របាយការណ៍លេខ១២នៃជំរឿនទូទៅនូវប្រជារាស្ត្រកម្ពុជាឆ្នាំ២០០៨

**១២-** និន្នាការនេះត្រូវបានបង្ហាញឲ្យឃើញកាន់តែច្បាស់តាមការប្រៀបធៀបទិន្នន័យព្យាករពីឆ្នាំ ២០១៥ដល់ឆ្នាំ២០៣០។ តាមរយៈការព្យាករ ដែលផ្អែកលើជំរឿនទូទៅនូវប្រជារាស្ត្រកម្ពុជាឆ្នាំ ២០០៨ ចំនួនប្រជាជនសរុបនឹងកើនពី១៥,៣លាននាក់នៅឆ្នាំ២០១៥ដល់១៨,១លាននាក់នៅឆ្នាំ ២០៣០ ដោយមានកំណើនសរុបស្មើនឹង១៨,២ភាគរយ ខណៈដែលចំនួនប្រជាជនវ័យចាស់នឹង កើនពី១,១១លាននាក់នៅឆ្នាំ២០១៥ដល់១,៩៩លាននាក់ នៅឆ្នាំ២០៣០ ដែលអត្រាកំណើនសរុប ស្មើនឹង៨០,១ភាគរយ[៦]។

## ៣.២- ការកើនឡើងនៃសមាមាត្រប្រជាជនវ័យចាស់

**១៣-** ដោយប្រជាជនវ័យចាស់បានកើនឡើងក្នុងអត្រាមួយខ្ពស់ជាងអត្រាកំណើនប្រជាជនសរុប នោះ សមាមាត្រប្រជាជនវ័យចាស់នឹងមានការកើនឡើង ហើយនិន្នាការនេះនឹងបន្តមានទៅពេល ខាងមុខ។ នៅឆ្នាំ១៩៩៨ សមាមាត្រប្រជាជនវ័យចាស់ មានត្រឹមតែ៥,២ភាគរយប៉ុណ្ណោះក្នុងចំណោម ប្រជាជនសរុប។ តួលេខនេះមានការកើនឡើងដល់៧,២ភាគរយក្នុងឆ្នាំ២០១៥ ហើយនឹងកើនឡើង ដល់១១ភាគរយនៅឆ្នាំ២០៣០(រូបភាពទី៤)។ បើគិតជាកំណើនពិន្ទុភាគរយ ចាប់ពីឆ្នាំ១៩៩៨ ដល់ ឆ្នាំ២០១៥ ចំនួនមនុស្សចាស់បានកើនឡើងចំនួន២ពិន្ទុភាគរយ(ពី៥,២ភាគរយដល់៧,២ភាគរយ)

[៦] ការព្យាករចំនួនប្រជាជនកម្ពុជា : របាយការណ៍លេខ១២នៃជំរឿនទូទៅនូវប្រជារាស្ត្រកម្ពុជាឆ្នាំ២០០៨

ហើយចាប់ពីឆ្នាំ២០១៥ ដល់ឆ្នាំ២០៣០ ចំនួននេះនឹងកើនឡើងរហូតដល់ជិត៤ពិន្ទុភាគរយ(ពី៧,២ ភាគរយដល់១១ភាគរយ)។ និន្នាការនេះនឹងបន្តកើនឡើង៦,៩ពិន្ទុភាគរយទៀត គឺកើនដល់១៧,៩ ភាគរយនៃប្រជាជនសរុបនៅឆ្នាំ២០៥០។ ក្នុងបរិការណ៍នេះ គោលនយោបាយ ផែនការ យុទ្ធសាស្ត្រ និងកម្មវិធីអភិវឌ្ឍន៍នានា ត្រូវផ្តោតលើការគិតគូរដោះស្រាយបញ្ហាទាក់ទងនឹងប្រជាជន វ័យចាស់។

**រូបភាពទី៤ : សមាមាត្រប្រជាជនវ័យចាស់ធៀបនឹងប្រជាជនសរុប**




**ប្រភព : ការព្យាករចំនួនប្រជាជនកម្ពុជា** របាយការណ៍ជំរឿនទូទៅនូវប្រជារាស្ត្រឆ្នាំ២០០៨ លេខ១២

**១៤-** ដំណើរឈានចូលវ័យចាស់របស់ប្រជាជននៅកម្ពុជាបានចាប់ផ្តើមក្រោយបណ្តាប្រទេសជាសមាជិកអាស៊ានភាគច្រើន ដោយសារកត្តាពីរយ៉ាង៖ ទី១ អត្រាលទ្ធភាពមានកូនធ្លាក់ចុះក្រោយគេ និងទី២ ផលប៉ះពាល់អវិជ្ជមាននៃអត្រាមរណភាពខ្ពស់ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩) មកលើរចនាសម្ព័ន្ធអាយុរបស់ប្រជាជន។ ការសម្លាប់រង្គាល ភាពចលាចល ជំងឺរាតត្បាត និងការស្លាប់ដោយសារគ្រោះទុរភិក្សដែលកើតមានក្នុងរបបកម្ពុជាប្រជាធិបតេយ្យ បានធ្វើឲ្យអត្រាមរណភាពខ្ពស់ ដែលជាហេតុនាំឲ្យមានមនុស្សចំនួនតិចតួចប៉ុណ្ណោះដែលនៅរស់រានមានជីវិត ហើយដែលបច្ចុប្បន្នពួកគាត់កំពុងឈានដល់វ័យចាស់។ ក្រោយរបបកម្ពុជាប្រជាធិបតេយ្យ ចំនួនទារកមានសន្ទុះកើនឡើងខ្លាំងនៅក្នុងទសវត្សរ៍ទី៨នៃសតវត្សរ៍ទី២០ និង ដើមទសវត្សរ៍ទី១០នៃសតវត្សរ៍ទី២០ ដែលបណ្តាលឲ្យមនុស្ស វ័យកណ្តាលមានចំនួនច្រើនលើសលប់នាពេលបច្ចុប្បន្ននេះ។ ក្រុមមនុស្សវ័យកណ្តាលទាំងនេះ នឹងចាប់ផ្តើមឈានចូលវ័យចាស់ចាប់ពីឆ្នាំ២០៣០តទៅ ។

**១៥-** បម្រែបម្រួលនៃកំណើនប្រជាជនវ័យចាស់និងសមាមាត្រប្រជាជនវ័យចាស់ក្នុងកំណើនប្រជាជនសរុប ត្រូវបានបង្ហាញក្នុងតារាងទី១ខាងក្រោម ដែលព្យាករពីប្រជាជនវ័យចាស់ ក្នុងរយៈពេល៥ឆ្នាំម្តង គិតដល់ឆ្នាំ២០៣០។ ពីឆ្នាំ២០០៨ដល់ឆ្នាំ២០១០ មនុស្សចាស់កើនជិត២៨ពាន់នាក់ជាមធ្យមប្រចាំ

ឆ្នាំ ដែលកំណើននេះស្មើនឹង១២,៨ភាគរយនៃកំណើនប្រជាជនសរុបក្នុងមួយឆ្នាំ។ ពីឆ្នាំ២០២៥ដល់ឆ្នាំ២០៣០ មនុស្សចាស់កើនប្រហែល៧០ពាន់នាក់ជាមធ្យមប្រចាំឆ្នាំ ដែលស្មើនឹង៤០,២ភាគរយនៃកំណើនប្រជាជនសរុបក្នុងមួយឆ្នាំ។

**តារាងទី១ : ស្ថានភាពបម្រែបម្រួលនៃប្រជាជនវ័យចាស់នៅកម្ពុជា**

| រយៈពេល | កំណើនមធ្យមប្រចាំឆ្នាំនៃមនុស្សចាស់ | ភាគរយនៃមនុស្សចាស់នៅក្នុងកំណើនប្រជាជនសរុប |
|---|---|---|
| ២០០៨-២០១០ | ២៧ ៧០៨ | ១២,៨ |
| ២០១០-២០១៥ | ៣៥ ២៩១ | ១៦,០ |
| ២០១៥-២០២០ | ៤៩ ៧៣៥ | ២២,៦ |
| ២០២០-២០២៥ | ៦៣ ២៥៨ | ៣១,២ |
| ២០២៥-២០៣០ | ៧០ ០០៨ | ៤០,២ |

ប្រភព : ការព្យាករចំនួនប្រជាជនកម្ពុជា របាយការណ៍ជំរឿនទូទៅនូវប្រជារាស្ត្រឆ្នាំ២០០៨ លេខ១២

## ៣.៣- ដំណើរឈានចូលភាពជរារបស់ប្រជាជនវ័យចាស់

**១៦-** ដំណើរឈានចូលភាពជរារបស់ប្រជាជនវ័យចាស់ ត្រូវបានឲ្យនិយមន័យថាជាកំណើនសមាមាត្រប្រជាជនដែលមានអាយុ៨០ឆ្នាំឡើង ក្នុងចំណោមប្រជាជនវ័យចាស់ ដែលត្រូវបានហៅថាប្រជាជនចាស់ជរា។ ទិដ្ឋភាពសំខាន់ពីរនៃប្រជាជនវ័យចាស់ គឺការឈានចូលភាពជរារបស់ប្រជាជនវ័យចាស់ និងភាពជរារបស់ស្ត្រី។ មនុស្សវ័យចាស់ប្រឈមនឹងបញ្ហាជាច្រើនផ្សេងៗគ្នា ហើយកាន់តែធ្ងន់ធ្ងរ នៅពេលដែលពួកគាត់ឈានចូលវ័យកាន់តែចាស់ ជាពិសេស ស្ត្រីវ័យចាស់ច្រើនតែងាយរងគ្រោះជាងបុរសវ័យចាស់។

**១៧-** នៅដើមសតវត្សរ៍នេះ មនុស្សវ័យចាស់ជរាមាន៦ភាគរយនៃចំនួនប្រជាជនវ័យចាស់សរុប។ ដោយមានភាពប្រសើរឡើងនូវអាយុកាលសង្ឃឹមរស់ បច្ចុប្បន្ននេះ មនុស្សដែលមានអាយុ៨០ឆ្នាំឡើងមាន៧,៥ភាគរយ ក្នុងចំណោមប្រជាជនវ័យចាស់សរុប ហើយសមាមាត្រនេះត្រូវបានព្យាករថានឹងបន្តកើនឡើងដល់១៤,៥ភាគរយ នៅឆ្នាំ២០៥០។ ដំណើរឈានចូលភាពជរារបស់ប្រជាជនវ័យចាស់ បានស្តែងឡើងនៅក្នុងកំណើននៃផលធៀបគាំទ្រឪពុកម្តាយដែលផលធៀបនេះ គឺជាចំនួនប្រជាជនវ័យចាស់ជរាអាយុ៨០ឆ្នាំឡើង ក្នុងចំណោមប្រជាជនអាយុពី៥០ដល់៥៩ឆ្នាំ ចំនួន១០០នាក់ ហើយ នេះគឺជាសូចនាករអំពីការគាំទ្ររបស់គ្រួសារដែលមានសម្រាប់ឪពុកម្តាយមានវ័យចាស់ជរា។ រូបភាពទី៥បង្ហាញថា ផលធៀបការគាំទ្រឪពុកម្តាយមាននិន្នាការប្រែប្រួល គិតត្រឹមឆ្នាំ២០១៨ តែនិន្នាការនេះ ត្រូវបានព្យាករថានឹងបន្តឡើងរហូតក្រោយឆ្នាំ២០១៨។

### រូបភាពទី៥ : ផលធៀបគាំទ្រឪពុកម្តាយ




**ប្រភព : ប្រជាជនវ័យចាស់នៅកម្ពុជា**( CIPS ឆ្នាំ២០១៣ របាយការណ៍លេខ១៣ )

**១៨-** នៅពេលដែលមនុស្សចាស់មានអាយុកាន់តែច្រើន បញ្ហាដែលពួកគាត់កំពុងប្រឈមមានទំហំកាន់តែធំ។ អាំងស៊ីដង់ជំងឺ ក៏ដូចជាពិការភាពក្នុងចំណោមប្រជាជនវ័យចាស់ កើនឡើងទៅតាមអាយុ ដែលទាមទារនូវការយកចិត្តទុកដាក់ដល់អ្នករងផលប៉ះពាល់ឲ្យបានច្រើនជាងមុន រួមទាំងការផ្តល់ការថែទាំរយៈពេលវែងផងដែរ។ ការចំណាយលើផ្នែកសុខភាពមានការកើនឡើង ពេលដែលប្រជាជនវ័យចាស់កាន់តែចាស់ទៅ ដោយថ្លៃចំណាយជាមធ្យមសម្រាប់អ្នកជំងឺម្នាក់នឹងត្រូវកើនឡើងទៅតាមអាយុ។ អសន្តិសុខផ្នែកហិរញ្ញវត្ថុក្នុងចំណោមមនុស្សចាស់មានការកើនឡើងទៅតាមអាយុ។ បញ្ហានេះ មួយផ្នែកបណ្តាលមកពីការធ្លាក់ចុះនៃសមត្ថភាពចូលរួមក្នុងការងាររបស់ពួកគាត់ ដូចមានបង្ហាញក្នុងរូបភាពទី៦ ដែលរំលេចពីការថយចុះនៃការចូលរួមក្នុងកម្លាំងពលកម្មរបស់ប្រជាជនវ័យចាស់នៅពេលពួកគាត់មានអាយុកាន់តែច្រើន។

រូបភាពទី៦ : និន្នាការនៃការចូលរួមកម្លាំងពលកម្មតាមអាយុ




ប្រភព : សកម្មភាពសេដ្ឋកិច្ចនិងមុខរបរ (CIPS ឆ្នាំ២០១៣ របាយការណ៍លេខ៨)

**១៩-** លើសពីនេះទៀត តម្លៃពិតនៃប្រាក់សោធនក៏នឹងថយចុះទៅតាមពេលវេលាផងដែរ។ តាមធម្មតា ការកែតម្រូវប្រាក់សោធនមិនបានឆ្លើយតបទាំងស្រុងទៅនឹងកំណើននៃចំណាយសម្រាប់ជីវភាពប្រចាំថ្ងៃទេ។ ជាលទ្ធផល ហានិភ័យដែលមនុស្សចាស់នឹងប្រឈម គឺការធ្លាក់ចូលទៅក្នុងភាពក្រីក្រ នៅពេលដែលពួកគាត់មានអាយុកាន់តែច្រើន។

## ៣.៤- ស្ត្រីភាវូបនីយកម្មនៃដំណើរឈានចូលវ័យចាស់

**២០-** ស្ត្រីភាវូបនីយកម្មនៃដំណើរឈានចូលវ័យចាស់ មានន័យថា ស្ត្រីវ័យចាស់មានចំនួនភាគច្រើនក្នុងចំណោមប្រជាជនវ័យចាស់សរុប ហើយទាមទារឲ្យមានការដាក់ចេញនូវគោលនយោបាយដើម្បីដោះស្រាយ។ នៅកម្ពុជា ភាគច្រើននៃមនុស្សចាស់ជាស្ត្រី។ ស្ត្រីមានចំនួនជាង៥៥ភាគរយក្នុងចំណោមប្រជាជនវ័យចាស់សរុប។ ដោយសារអាយុកាលសង្ឃឹមរស់ស្ត្រីវែងជាងបុរស ភាពខុសគ្នារវាងភេទក៏កាន់តែធំផងដែរក្នុងចំណោមមនុស្សវ័យចាស់ជរា។ ទិន្នន័យបង្ហាញថា ស្ត្រីមានចំនួនច្រើនជាង៦០ភាគរយ ក្នុងចំណោមប្រជាជនវ័យចាស់ជរា។ ស្ត្រីភាវូបនីយកម្មនៃដំណើរឈានចូលវ័យចាស់ ទាមទារឲ្យមានវិធានការពិសេសដើម្បីដោះស្រាយនូវរាល់បញ្ហាប្រឈមទាំងឡាយដែលកើតមានចំពោះពួកគាត់ ដោយសារតែភាពងាយរងគ្រោះកាន់តែច្រើនជាងមុនរបស់ពួកគាត់។ ស្ត្រីវ័យចាស់មានភាពងាយរងគ្រោះច្រើនជាង ដោយសារការរើសអើងខ្ពស់ក្នុងការងារ អសន្តិសុខហិរញ្ញវត្ថុ កម្រិតទាបនៃការអប់រំនិងអក្ខរភាព និងអាំងស៊ីដង់ខ្ពស់នៃជំងឺ។ លើសពីនេះទៀត ស្ត្រីវ័យចាស់ដែលជាស្ត្រីមេម៉ាយមានភាគរយច្រើនជាងបុរសវ័យចាស់ដែលជាពោះម៉ាយ ហើយការរស់នៅឯកោក្នុងវ័យចាស់ ធ្វើឲ្យពួកគាត់កាន់តែងាយរងគ្រោះ។

**២១-** នៅកម្ពុជា ស្ត្រីភាវូបនីយកម្មនៃដំណើរឈានចូលវ័យចាស់ បានក្លាយជាបញ្ហាដែលត្រូវទទួលបានការយកចិត្តទុកដាក់ច្រើនជាងមុន ដែលជាលទ្ធផលនៃការកាប់សម្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩)។ ក្នុងកំលុងពេលនោះ ប្រជាជនកម្ពុជាវ័យក្មេងនិងវ័យកណ្តាល ត្រូវបានសម្លាប់ ក្នុងនោះ បុរសស្លាប់ច្រើនជាងស្ត្រី។ ទន្ទឹមនឹងនេះ ប្រជាជនជាច្រើនបានចាកចេញពីកម្ពុជា ក្នុងចំណោមនោះ ភាគច្រើនជាបុរសក្នុងវ័យពលកម្ម ។ ស្ថានភាពនេះបានធ្វើឲ្យសមាមាត្រនៃស្ត្រីវ័យចាស់ក្នុងប្រជាជនវ័យចាស់សរុបរបស់កម្ពុជាមានកម្រិតខ្ពស់ជាងគេ នៅក្នុងបណ្តាប្រទេសអាស៊ាន ដូចមានបង្ហាញក្នុងតារាងទី២។ លើសពីនេះ ស្ត្រីវ័យចាស់ជាច្រើនមិនទទួលបានការជួយជ្រោមជ្រែងក្នុងជីវភាពរស់នៅរបស់ខ្លួន ដោយសារតែការបាត់បង់ប្តី ហើយជាពិសេស ស្ត្រីវ័យចាស់ជរាមិនត្រឹមតែបាត់បង់ប្តីប៉ុណ្ណោះទេ ប៉ុន្តែបានបាត់បង់កូនប្រុសថែមទៀត នៅក្នុងសម័យរបបកម្ពុជាប្រជាធិបតេយ្យ។

**តារាងទី២ : ភាគរយនៃស្ត្រីក្នុងចំណោមប្រជាជនវ័យចាស់អាយុ៦០ឆ្នាំឡើងនៅក្នុងអាស៊ាន**

| ប្រទេស | ២០១៥ | ប្រទេស | ២០៣០ | ប្រទេស | ២០៥០ |
|---|---|---|---|---|---|
| **កម្ពុជា** | **៥៩,៦** | **កម្ពុជា** | **៥៨,៧** | **ហ្វីលីពីន** | **៥៧,១** |
| វៀតណាម | ៥៧,៦ | វៀតណាម | ៥៦,៩ | កម្ពុជា | ៥៦,០ |
| មីយ៉ាន់ម៉ា | ៥៦,១ | មីយ៉ាន់ម៉ា | ៥៦,០ | វៀតណាម | ៥៥,៨ |
| ហ្វីលីពីន | ៥៥,៥ | ហ្វីលីពីន | ៥៥,៩ | មីយ៉ាន់ម៉ា | ៥៥,៥ |
| ឡាវ | ៥៥,០ | ឡាវ | ៥៥,៣ | ឥណ្ឌូណេស៊ី | ៥៥,២ |
| ថៃ | ៥៤,១ | ថៃ | ៥៤,៣ | សិង្ហបុរី | ៥៥,០ |
| សិង្ហបុរី | ៥៣,២ | ម៉ាឡេស៊ី | ៥៤,២ | ឡាវ | ៥៤,៣ |
| ព្រុយណេ | ៥៣,២ | ឥណ្ឌូណេស៊ី | ៥៣,៥ | ថៃ | ៥៤,២ |
| ឥណ្ឌូណេស៊ី | ៥២,៩ | សិង្ហបុរី | ៥៣,១ | ម៉ាឡេស៊ី | ៥៣,៤ |
| ម៉ាឡេស៊ី | ៥១,១ | ព្រុយណេ | ៥០,៥ | ព្រុយណេ | ៤៩,៦ |
| **អាស៊ាន** | **៥៥,០** | **អាស៊ាន** | **៥៥,១** | **អាស៊ាន** | **៥៥,៦** |

ប្រភព : ទិដ្ឋភាពប្រជាជនពិភពលោកឆ្នាំ២០១៥(UNDESA, New York, ២០១៥)

## ៣.៥- ទិដ្ឋភាពភូមិសាស្ត្រនៃប្រជាជនវ័យចាស់

**២២-** ការគិតគូរដល់ភាពខុសគ្នានៃទំហំប្រជាជនវ័យចាស់តាមខេត្តនានា គឺជាប្រការចាំបាច់។ កម្មវិធីដើម្បីដោះស្រាយនូវរាល់បញ្ហាពាក់ព័ន្ធនឹងដំណើរឈានចូលវ័យចាស់ ត្រូវរៀបចំឡើងដោយផ្តោតលើខេត្តទាំងឡាយដែលមានសមាមាត្រមនុស្សចាស់ក្នុងចំណោមប្រជាជនសរុបខ្ពស់ជាង។ ក្នុងឆ្នាំ

២០១៣ សមាមាត្រមនុស្សចាស់ក្នុងចំណោមប្រជាជនសរុប មានចាប់ពី៣,១ភាគរយ នៅខេត្តមណ្ឌលគិរី ដល់៩,៨ភាគរយ នៅខេត្តកំពង់ចាម។ ចំនួនពាក់កណ្ដាលនៃប្រជាជនវ័យចាស់នៅកម្ពុជារស់នៅតែក្នុងខេត្តចំនួន៦ក្នុងបណ្ដារាជធានីខេត្តទាំង២៥ ក្នុងនោះគឺ ខេត្តកំពង់ចាម រាជធានីភ្នំពេញ ខេត្ត កណ្ដាល ខេត្តព្រៃវែង ខេត្តបាត់ដំបង និងខេត្តតាកែវ ។

**២៣-** ទិដ្ឋភាពភូមិសាស្ត្រនៃដំណើរឈានចូលវ័យចាស់សំខាន់មួយទៀតគឺ ភាពខុសគ្នារវាងតំបន់ជនបទនិងតំបន់ទីប្រជុំជន។ ជាទូទៅ សមាមាត្រនៃមនុស្សចាស់នៅតំបន់ជនបទមានកម្រិតខ្ពស់ជាងតំបន់ទីប្រជុំជន ដែលជាលទ្ធផលនៃការធ្វើទេសន្តរប្រវេសន៍កាន់តែច្រើនឡើងរបស់ប្រជាជនវ័យក្មេងពីតំបន់ជនបទមកកាន់តំបន់ទីប្រជុំជន។ ស្ថានភាពនេះក៏កើតមានផងដែរនៅកម្ពុជា ពោលគឺ សមាមាត្រនៃមនុស្សចាស់នៅតំបន់ជនបទខ្ពស់ជាងនៅតំបន់ទីប្រជុំជនបន្តិច(៧,៧ភាគរយនៅតំបន់ជនបទ និង៧,៣ភាគរយនៅតំបន់ទីប្រជុំជន)។ ទោះបីជានៅតំបន់ជនបទ អត្រាលទ្ធភាពមានកូនមានកម្រិតខ្ពស់ជាង ហើយអាយុកាលសង្ឃឹមរស់មានកម្រិតទាបជាងក៏ដោយ ក៏សមាមាត្រខ្ពស់ជាងនៃប្រជាជនវ័យចាស់នៅតំបន់ជនបទ គឺជាលទ្ធផលនៃការរធ្វើទេសន្តរប្រវេសន៍ចេញពីតំបន់ជនបទមកទីប្រជុំជនរបស់ប្រជាជនក្នុងវ័យពលកម្ម។

## ៣.៦- ផលធៀបគាំទ្រសក្ដានុពល

**២៤-** សមាមាត្រនៃប្រជាជនវ័យចាស់ដែលបន្តកើនឡើងជាលំដាប់ ធៀបជាមួយនឹងប្រជាជនពេញវ័យនាំឲ្យមានការថមថយនូវមូលដ្ឋានហិរញ្ញវត្ថុនិងមូលដ្ឋាននៃការគាំទ្រក្នុងការថែទាំសម្រាប់មនុស្សចាស់។ ស្ថានភាពនេះ ត្រូវបានឆ្លុះបញ្ចាំងឲ្យឃើញតាមរយៈការធ្លាក់ចុះនៃផលធៀបគាំទ្រសក្ដានុពល ដែលត្រូវបានកំណត់ថា ជាចំនួនមនុស្សក្នុងវ័យធ្វើការ(១៥-៦៤ឆ្នាំ) ក្នុងមនុស្សចាស់អាយុ៦៥ឆ្នាំឡើងម្នាក់[៥]។ ផលធៀបគាំទ្រសក្ដានុពល ផ្ដល់នូវការវាស់វែងមួយអំពីទំនាក់ទំនងរវាងអ្នកដែលមានលទ្ធភាពផ្នែកសេដ្ឋកិច្ចនិងដែលអាចផ្ដល់ការគាំទ្រ និងការថែទាំដល់មនុស្សចាស់ដែលជាអ្នកនៅក្នុងបន្ទុក និងជាអ្នកត្រូវការការគាំទ្រនិងការថែទាំនេះ។ រូបភាពទី៧ បង្ហាញពីកម្រិតប៉ាន់ស្មាននិងព្យាករនៃផលធៀបគាំទ្រសក្ដានុពល។

[៥] ដោយសារតែចំនួនមនុស្សចាស់(អាយុ៦០ឆ្នាំឡើង) នៅធ្វើការនៅឡើយ ដូច្នេះសមាមាត្រសក្ដានុពលនៃកិច្ចគាំពារ ត្រូវយកពីអាយុ៦៥ឆ្នាំ ជា "មនុស្សចាស់ដែលមិនអាចធ្វើការងារបាន" (NWOP)។

### រូបភាពទី៧ : ការថយចុះនៃកិច្ចគាំពារពីសំណាក់ក្រុមគ្រួសារ




**ប្រភព** : **ប្រជាជនវ័យចាស់នៅកម្ពុជា**(CIPS ២០១៣, លេខ ១៣)

**២៥-** បន្ទាប់ពីការធ្លាក់ចុះ២ពិន្ទុភាគរយ នៅចន្លោះឆ្នាំ១៩៩៨និងឆ្នាំ២០១៨ ការធ្លាក់ចុះនេះត្រូវបានព្យាករថាកាន់តែលឿនជាងមុន ដោយផលធៀបគាំទ្រសក្តានុពល នឹងធ្លាក់ចុះដល់៩,៣ភាគរយ ឬធ្លាក់ចុះ៤ពិន្ទុភាគរយ នៅឆ្នាំ២០៣០។ តារាងទី៣ បង្ហាញពីភាពខុសគ្នានៃផលធៀបគាំទ្រសក្តានុពលរវាងតំបន់ជនបទនិងតំបន់ទីប្រជុំជន។ កម្រិតទាបជាងនៃផលធៀបគាំទ្រសក្តានុពលនៅតំបន់ជនបទបង្ហាញពីការធ្វើទេសន្តរប្រវេសន៍ចេញពីតំបន់ជនបទរបស់ប្រជាជនក្នុងវ័យពលកម្ម និងសមាមាត្រខ្ពស់ជាងនៃប្រជាជនវ័យចាស់នៅតំបន់ជនបទ។

### តារាងទី៣ : ផលធៀបគាំទ្រសក្តានុពលនៅតំបន់ទីប្រជុំជននិងតំបន់ជនបទ

| ឆ្នាំ | កម្ពុជា | ទីប្រជុំជន | ជនបទ |
|---|---|---|---|
| | ប្រជាជនអាយុពី១៥ដល់៦៤ឆ្នាំ/ប្រជាជនអាយុ៦៥ឡើង | | |
| ១៩៩៨ | ១៥,៥ | ២០,៥ | ១៤,៥ |
| ២០០៤ | ១៤,៧ | ១៨,៦ | ១៤,១ |
| ២០០៨ | ១៤,៥ | ២០,០ | ១៣,៥ |
| ២០១៣ | ១៣,៣ | ២០,៣ | ១៥,៩ |
| ២០១៨ | ១៣,៤ | ១៦,២ | ១២,៦ |
| ២០២៣ | ១១,៧ | ១៣,០ | ១០,៧ |
| ២០២៨ | ៩,៨ | ១១,៥ | ៩,២ |
| ២០៣០ | ៩,៣ | ១១,១ | ៨,៦ |

**ប្រភព** : ប្រជាជនវ័យចាស់នៅកម្ពុជា(អង្កេតចន្លោះជំរឿននៃប្រជាពលរដ្ឋកម្ពុជាឆ្នាំ២០១៣ របាយការណ៍លេខ១៣)

## ៤- បញ្ហាចម្បងៗពាក់ព័ន្ធនឹងដំណើរឈានចូលវ័យចាស់ជរា

**២៦-** ផលធៀបគាំទ្រសក្តានុពលដែលកំពុងធ្លាក់ចុះ គឺជាការថមថយនៃការគាំទ្ររបស់គ្រួសារចំពោះមនុស្សវ័យចាស់ ដែលកាន់តែមានសារៈសំខាន់ថែមទៀត ដោយហេតុថា គ្រួសារគឺជាអ្នកផ្តល់ជំនួយដ៏សំខាន់សម្រាប់មនុស្សវ័យចាស់។ ក្នុងបរិការណ៍នេះ ការធ្លាក់ចុះនៃការគាំទ្រសក្តានុពលមានផលប៉ះពាល់ជាច្រើនលើមនុស្សចាស់ ក្នុងនោះរួមមានបញ្ហាមួយចំនួនដែលពាក់ព័ន្ធនឹងសន្តិសុខហិរញ្ញវត្ថុ ការថែទាំសុខភាព ការថែទាំរយៈពេលវែង របៀបរបបការរស់នៅ ការផ្លាស់ទី សន្តិសុខ ជាដើម។ ការធ្លាក់ចុះនេះក៏មានផលប៉ះពាល់ផងដែរលើប្រជាជនវ័យក្មេង ដែលប្រឈមនឹងតម្រូវការកាន់តែច្រើនក្នុងការជួយឧបត្ថម្ភគាំទ្រនិងការថែទាំ។

### ៤.១- សន្តិសុខហិរញ្ញវត្ថុ

**២៧-** ប្រពៃណីនៃការជួយផ្តល់ប្រាក់កាសដល់ឪពុកម្តាយនិងសាច់ញាតិវ័យចាស់របស់កូនៗ និងសាច់ញាតិវ័យក្មេងបានចាក់ឫសគល់រឹងមាំនៅក្នុងសង្គមកម្ពុជា។ ប៉ុន្តែ ការប្រតិបត្តិប្រពៃណីបែបនេះអាចនឹងធ្លាក់ចុះនៅថ្ងៃខាងមុខ នៅពេលណាដែលចំនួនអ្នកផ្តល់ការគាំទ្រមនុស្សចាស់(មនុស្សវ័យក្មេងជាង) មានកាន់តែតិចទៅៗ។ ក្នុងន័យនេះ ការជួយឧបត្ថម្ភផ្នែកហិរញ្ញវត្ថុដែលនឹងត្រូវផ្តល់ដោយប្រជាជនវ័យក្មេងដែលកាន់តែមានចំនួនតិចទៅៗ នឹងមានការធ្លាក់ចុះជាបណ្តើរៗ។ ដើម្បីរក្សាបាននូវគុណភាពជីវិតរបស់មនុស្សចាស់ ការធានាបាននូវស្ថិរភាពនៃប្រាក់ចំណូលរបស់ពួកគាត់គឺជាប្រការចាំបាច់។ ប្រភពសំខាន់បីដែលអាចជ្រើសរើសយកមកធ្វើជាការបំពេញបន្ថែមឲ្យការឧបត្ថម្ភគាំទ្ររបស់គ្រួសារ រួមមាន៖ (ក) ការងារមានប្រាក់ចំណូលខ្ពស់ (ខ) របបសន្តិសុខសង្គម និង(គ) អត្ថប្រយោជន៍សម្រាប់សុខុមាលភាព។

**២៨-** តារាងទី៤បង្ហាញពីស្ថានភាពសកម្មភាពសេដ្ឋកិច្ចរបស់មនុស្សចាស់។ អត្រាចូលរួមក្នុងកម្លាំងពលកម្ម រួមបញ្ចូលនូវអ្នកមានការងារធ្វើឬអ្នកមានបំណងធ្វើការងារតែរកមិនទាន់បាន។ ពួកគាត់អាចធ្លាប់មានការងារធ្វើពីមុនឬមានបំណងរកការងារធ្វើជាលើកដំបូង។ តួលេខខាងក្រោមបង្ហាញអំពីសមាមាត្រដ៏គួរឲ្យកត់សម្គាល់នៃមនុស្សចាស់ដែលកំពុងធ្វើការងារ។ សមាមាត្រមនុស្សចាស់ ទាំងប្រុស ទាំងស្រី នៅតំបន់ជនបទ ដែលនៅសកម្មក្នុងសកម្មភាពសេដ្ឋកិច្ច មានកម្រិតខ្ពស់ជាង សមាមាត្រដូចគ្នានេះ នៅតំបន់ទីប្រជុំជន។ ប្រការនេះអាចពន្យល់បានដោយឈរលើហេតុផលថា ប្រជាជនតំបន់ជនបទអាចនៅចូលរួមក្នុងរយៈយូរជាងក្នុងវិស័យកសិកម្ម។ ទាំងនៅតំបន់ជនបទ ទាំងនៅតំបន់ទីប្រជុំជន សមាមាត្របុរសដែលនៅសកម្មក្នុងសកម្មភាពសេដ្ឋកិច្ច មានកម្រិតខ្ពស់ជាង សមាមាត្រស្ត្រីដែលមានស្ថានភាពដូចគ្នា។

**តារាងទី៤ : សកម្មភាពសេដ្ឋកិច្ចនិងស្ថានភាពការងាររបស់មនុស្សចាស់**

| | ប្រុស | | ស្រី | |
|---|---|---|---|---|
| | ជនបទ | ទីប្រជុំជន | ជនបទ | ទីប្រជុំជន |
| អត្រាចូលរួមជាកម្លាំងពលកម្ម (%) | ៧៣,៨ | ៦១,៦ | ៥៤,៨ | ៣៤,២ |
| **ភាគរយនៃអ្នករកប្រាក់ចំណូលសកម្ម** | | | | |
| មានការងារធ្វើ | ៩៧,៦ | ៩៦,៣ | ៩៥,៩ | ៩២,៨ |
| គ្មានការងារធ្វើ | ២,៤ | ៣,៧ | ៤,១ | ៧,២ |
| **ភាគរយនៃអ្នកមានការងារធ្វើ** | | | | |
| និយោជក | ០,២ | ០,៨ | ០,២ | ០,០ |
| និយោជិតមានប្រាក់ខែ | ៧,៣ | ៣៤,០ | ២,៨ | ១២,០ |
| ធ្វើការងារផ្ទាល់ខ្លួន | ៨៤,៦ | ៦១,៥ | ៤៩,៥ | ៦០,៥ |
| ការងារគ្រួសារដែលគ្មានប្រាក់ចំណូល | ៧,៩ | ៣,៨ | ៤៧,៤ | ២៧,៥ |
| ផ្សេងៗ | ០,០ | ០,០ | ០,១ | ០,០ |

**ប្រភព : សកម្មភាពសេដ្ឋកិច្ចនិងការងារ**( CIPS ២០១៣, លេខ៨ )

**២៩-** របាយបុរសនិងស្ត្រីដែលមានការងារធ្វើតាមស្ថានភាពការងារ បង្ហាញថា សមាមាត្រស្ត្រីដែលជាអ្នកធ្វើការមានប្រាក់ឈ្នួល មានកម្រិតខ្ពស់ជាងសមាមាត្របុរសដែលនៅក្នុងស្ថានភាពដូចគ្នា។ លើសពីនេះទៀត ទាំងនៅតំបន់ជនបទ ទាំងនៅតំបន់ទីប្រជុំជន សមាមាត្រអ្នកធ្វើការជាស្ត្រីដែលជាអ្នកធ្វើការងារផ្ទះគ្មានប្រាក់ឈ្នួល មានកម្រិតខ្ពស់ជាងច្រើន ធៀបនឹងសមាមាត្របុរសដែលមានស្ថានភាពដូចគ្នា។ អត្រាគ្មានការងារធ្វើរបស់ស្ត្រី ទាំងនៅតំបន់ជនបទ ទាំងនៅតំបន់ទីប្រជុំជន មានកម្រិតខ្ពស់ជាងបុរស ដែលបង្ហាញឲ្យឃើញថា ស្ត្រីវ័យចាស់អាចត្រូវប្រឈមនឹងការលំបាកកាន់តែខ្លាំងក្នុងការទទួលបានការងារធ្វើ ដោយសារកង្វះជំនាញឬការរើសអើងផ្នែកយេនឌ័រ។ ការធានាឲ្យមានការងារដែលមានលក្ខណៈផលិតសម្រាប់ ទាំងបុរសវ័យចាស់ ទាំងស្ត្រីវ័យចាស់ ដែលអាចមានលទ្ធភាពនិងមានបំណងធ្វើការ គួរត្រូវចាត់ទុកជាការងារអាទិភាព។ ទោះជាយ៉ាងណាក៏ដោយ ក៏ការងារចាំបាច់ដែលត្រូវគិតគូរដោះស្រាយនោះ គឺការធ្វើឲ្យមានតុល្យភាពរវាងការផ្តល់ការងារដល់មនុស្សចាស់និងការឆ្លើយតបនឹងតម្រូវការការងាររបស់អ្នកធ្វើការងារវ័យក្មេង ជាពិសេស អ្នកទើបចូលប្រឡូកក្នុងការងារ។

**៣០-** មនុស្សចាស់ដែលជួបប្រទះអសន្តិសុខហិរញ្ញវត្ថុនិងមិនមានសមត្ថភាពអាចធ្វើការបានចាំបាច់ត្រូវស្ថិតក្រោមគម្រោងគាំពារសង្គមនិងសុខុមាលភាព។ នាពេលបច្ចុប្បន្ននេះ វិសាលភាពនៃគម្រោងគាំពារសង្គមនិងសុខុមាលភាព នៅមានកម្រិតនៅឡើយ ហើយចាំបាច់ត្រូវពង្រីកបន្ថែមទៀត ដើម្បីការពារមនុស្សចាស់ដែលងាយរងគ្រោះឲ្យគេចផុតពីភាពក្រីក្រ។

## ៤.២- សុខភាពនិងសុខុមាលភាព

**៣១-** មនុស្សវ័យចាស់កម្ពុជាមានអាយុកាន់តែវែង ហើយរស់នៅក្នុងជីវិតដែលមានសុខភាពល្អជាងមុន។ ទោះជាយ៉ាងណាក៏ដោយ ក៏ពេលដែលមនុស្សកាន់តែចាស់ ភាពងាយរងគ្រោះរបស់ពួកគាត់ក៏កាន់តែកើនឡើងផងដែរ។ ពួកគាត់មានហានិភ័យ អាចជួបនឹងបញ្ហាប្រឈមកាន់តែច្រើនឡើង រួមទាំងមានស្ថានភាពសុខភាពទន់ខ្សោយផងដែរ។ ពួកគាត់អាចជួបនឹងហានិភ័យក្នុងការកើតមានជំងឺកាន់តែច្រើនឡើង ដែលរួមមាន ការចុះខ្សោយនៃប្រព័ន្ធការពាររាងកាយពីជំងឺឆ្លងផ្សេងៗ ដូចជា ផ្តាសាយជាដើម និងមានហានិភ័យកាន់តែខ្ពស់ចំពោះជំងឺមិនឆ្លងដូចជា ជំងឺទឹកនោមផ្អែម សម្ពាធឈាមខ្ពស់ជាដើម។ ទន្ទឹមនឹងនេះ មនុស្សចាស់ក៏ច្រើនតែមានជំងឺធ្ងន់ធ្ងរដល់អាយុជីវិត ដូចជា ជំងឺមហារីកនិងការវិលេងដំណើរការនៃសរីរាង្គ ដែលទាមទារឲ្យមានការថែទាំរយៈពេលវែង។

**៣២-** លើសពីនេះទៀត មនុស្សចាស់ដែលជួបហានិភ័យ ក្នុងការរស់នៅក្នុងពិការភាព ទាមទារនូវជំនួយសម្រាប់ការរស់នៅប្រចាំថ្ងៃ កាន់តែច្រើនឡើង។ អាំងស៊ីដង់នៃពិការភាពកាន់តែកើនឡើង នៅពេលឈានចូលវ័យកាន់តែចាស់ ទាំងបុរស ទាំងស្ត្រី។

**រូបភាពទី៨ : អាំងស៊ីដង់នៃពិការភាពបុរសនិងស្ត្រីវ័យចាស់**
(ភាគរយនៃមនុស្សចាស់ដែលបានរាយការណ៍ថាមានពិការភាព)




ប្រភព : **ពិការភាព**(CIPS ២០១៣, របាយការណ៍លេខ៥)

**៣៣-** រាជរដ្ឋាភិបាលផ្តល់សារៈសំខាន់ដល់មនុស្សចាស់នូវសេវា បង្ការ ព្យាបាល ស្តារឡើងវិញនូវសមត្ថភាពកាយសម្បទា និងបន្ថយការឈឺចាប់ ដើម្បីការពារទេពកោសល្យពីកំណើត និងសមត្ថភាព

បំពេញមុខងាររបស់ពួកគាត់។ ការផ្តល់សារៈសំខាន់ដល់ការងារខាងលើនេះ ជាលក្ខខណ្ឌចាំបាច់ខ្វះមិនបាន ដើម្បីធានាឲ្យបាននូវភាពម្ចាស់ការនិងសេចក្តីថ្លៃថ្នូររបស់មនុស្សចាស់។

## ៤.៣- របៀបរបបការរស់នៅ

**៣៤-** នៅប្រទេសកម្ពុជា ប្រព័ន្ធគ្រួសារដែលមានការរស់នៅជុំគ្នានៃមនុស្សច្រើនជំនាន់ គឺជាប្រពៃណី។ មនុស្សចាស់រស់នៅជាមួយកូនចៅពេញវ័យរបស់ខ្លួនឬសាច់ញាតិដទៃទៀត។ ទោះបីជាសណ្ឋាននៃការរស់នៅជុំគ្នារបៀបនេះ មិនទាន់សាបរលាបក្នុងរយៈពេលខ្លីចំពោះមុខនេះក៏ដោយ ក៏ការចុះខ្សោយនៃទម្លាប់រស់នៅបែបនេះ គឺជាករណីមួយដែលមិនត្រូវមើលរំលង នៅពេលដែលដំណើរការវិវឌ្ឍនៃការឈានចូលវ័យចាស់របស់ប្រជាជនបន្តកើនឡើង។ លើសពីនេះ ការធ្វើទេសន្តរប្រវេសន៍ទៅរកការងារធ្វើរបស់មនុស្សជំនាន់វ័យក្មេងជាង បន្សល់ទុកនូវមនុស្សចាស់ក្នុងចំនួនកាន់តែច្រើនឡើងឲ្យស្ថិតនៅក្រៅសំណាញ់សុវត្ថិភាពបែបប្រពៃណីនេះ ដែលក្នុងនោះពួកគាត់ទទួលការមើលថែទាំពីកូនៗ ហើយថែមទាំងបង្កើនបន្ទុកដល់ពួកគាត់ក្នុងការមើលថែទាំចៅៗ។ ការគាំទ្រគ្នាទៅវិញទៅមករវាងប្តីប្រពន្ធ កាន់តែមានសារៈសំខាន់ខ្លាំងឡើង នៅក្នុងវ័យចាស់ ព្រោះថាការរស់នៅម្នាក់ឯងក្នុងវ័យចាស់អាចក្លាយជាបន្ទុកដ៏ធ្ងន់ធ្ងរ។ ក្នុងស្ថានភាពនេះ ស្ត្រីវ័យចាស់មានភាពងាយរងគ្រោះជាងបុរសវ័យចាស់ អាស្រ័យដោយស្ត្រីវ័យចាស់មានសមាមាត្រច្រើនជាងបុរសវ័យចាស់ ត្រូវរស់នៅដោយគ្មានការគាំទ្រពីប្តី។ រូបភាពទី៩បង្ហាញថា ស្ត្រីវ័យចាស់៤០,៧ភាគរយពុំធ្លាប់បានរៀបការឬជាស្ត្រីមេម៉ាយលែងលះឬបែកបាក់គ្នាពីប្តី បើធៀបនឹងបុរសវ័យចាស់ដែលមានត្រឹមតែ៩,៨ភាគរយ។ មូលហេតុនៃភាពខុសគ្នានេះអាចស្វែងយល់ដោយហេតុផលថា មនុស្សស្រីមានអាយុកាលសង្ឃឹមរស់វែងជាងបុរស ហើយជាទូទៅ ប្រពន្ធមានវ័យក្មេងជាងប្តី។ លើសពីនេះទៀត អត្រារៀបការម្តងទៀតរបស់បុរសមានកម្រិតខ្ពស់ជាងច្រើនធៀបនឹងស្ត្រី។ ក្នុងន័យនេះ សមាមាត្រស្ត្រីវ័យចាស់នៅលីវ មានកម្រិតខ្ពស់ជាងច្រើនដោយធៀបនឹងសមាមាត្ររបស់បុរសដែលមានស្ថានភាពដូចគ្នា ហើយអន្តរាគមន៍ផ្នែកគោលនយោបាយ ត្រូវផ្តោតការយកចិត្តទុកដាក់ឲ្យបានច្រើនបន្ថែមទៀតលើក្រុមស្ត្រីទាំងនោះ ដើម្បីធានាបានថា ពួកគាត់បានទទួលរបៀបរបបរស់នៅសមរម្យ។

### រូបភាពទី៩ : ស្ថានភាពអាពាហ៍ពិពាហ៍របស់បុរសនិងស្ត្រីវ័យចាស់




ប្រភព : Nuptiality, (CIPS ២០១៣របាយការណ៍លេខ៤)

**៣៥-** លទ្ធភាពនៃការបាត់បង់ការគាំទ្រពីប្ដីប្រពន្ធ កើនឡើងកាន់តែខ្ពស់ពេលអាយុកាន់តែច្រើន។ រូបភាពទី១០បង្ហាញថា សមាមាត្រនៃប្រជាជនដែលស្ថិតក្នុងស្ថានភាពមេម៉ាយឬពោះម៉ាយ លែងលះគ្នាឬបែកបាក់គ្នា បានកើនឡើងពេលអាយុកាន់តែច្រើន។

### រូបភាពទី១០ : ភាគរយនៃបុរសនិងស្ត្រីវ័យចាស់ដែលជួបការរំខានក្នុងចំណងអាពាហ៍ពិពាហ៍




ប្រភព : Nuptiality, (CIPS ២០១៣របាយការណ៍លេខ៤)

**៣៦-** នៅក្នុងក្រុមអាយុនីមួយៗ សមាមាត្រស្ត្រីដែលឆ្លងកាត់ដំណើររអាក់រអួលនៅក្នុងជីវិតអាពាហ៍ពិពាហ៍មានកម្រិតខ្ពស់ជាងសមាមាត្របុរសដែលមានស្ថានភាពដូចគ្នា។ បន្ថែមពីលើ ការបាត់បង់ការគាំទ្រពីប្ដីឬពីប្រពន្ធរបស់ខ្លួន ដំណើររអាក់រអួលនៅក្នុងជីវិតអាពាហ៍ពិពាហ៍ ក៏ធ្វើឲ្យមានភាពតានតឹងផ្នែកផ្លូវចិត្តផងដែរ។

**៣៧-** របៀបរបបរស់នៅដែលជាជម្រើសដ៏ប្រសើរបំផុតសម្រាប់មនុស្សចាស់ គឺជាជម្រើសដែលអនុញ្ញាតឲ្យមាន "ដំណើរឈានចូលវ័យចាស់នៅនឹងកន្លែងដើម"។ ប្រព័ន្ធគ្រួសារដែលមានការរស់នៅជុំគ្នានៃមនុស្សច្រើនជំនាន់ ផ្តល់ដោយស្វ័យប្រវត្តិនូវការធានាឲ្យមានដំណើរឈានចូលវ័យចាស់នៅនឹងកន្លែងដើម ព្រោះថាមនុស្សចាស់បន្តរស់នៅជាមួយនឹងក្រុមគ្រួសារក្នុងលំនៅឋានដដែល។ ការប្រែប្រួលតែមួយគត់ដែលកើតមានគឺថា កូនប្រុសឬសមាជិកគ្រួសារជាមនុស្សពេញវ័យណាម្នាក់ផ្សេងទៀតចូលមកកាន់តួនាទីជាអ្នករកចំណូលចម្បងចិញ្ចឹមគ្រួសារ។ ប្រសិនបើមនុស្សចាស់ចង់ផ្លាស់កន្លែងរស់នៅ ហើយមានអារម្មណ៍ថាពួកគាត់អាចរស់នៅម្នាក់ឯងបាន ពួកគាត់គួរទទួលបានការជ្រោមជ្រែងឲ្យអាចធ្វើតាមបំណងរបស់ពួកគាត់។ ក្នុងករណីដែលមនុស្សចាស់ពុំមានគ្រួសារ ហើយពួកគាត់ត្រូវការការគាំទ្រនោះ ការថែទាំពីសហគមន៍គួរត្រូវបានជំរុញលើកទឹកចិត្តនិងរៀបចំឲ្យដំណើរការជាលក្ខណៈស្ថាប័ន។ ការផ្លាស់ទៅនៅក្នុងជម្រកស្នាក់នៅឬស្ថាប័នដែលផ្តល់ការស្នាក់នៅ គួរតែជាជម្រើសចុងក្រោយសម្រាប់មនុស្សចាស់ដែលពុំមានគ្រួសារ និងដែលពុំអាចរស់នៅម្នាក់ឯងបាន។

## ៤.៤- បរិស្ថានអំណោយផល

**៣៨-** "បរិស្ថានអំណោយផល" រួមបញ្ចូលនូវលក្ខខណ្ឌទាំងឡាយដែលត្រូវបង្កើតឡើង ដើម្បីសម្រួលឲ្យមានការចូលរួមយ៉ាងសកម្មពីមនុស្សចាស់ នៅក្នុងសកម្មភាពគ្រួសារ សហគមន៍ សង្គមសេដ្ឋកិច្ច និងនយោបាយ ប្រកបដោយសេរីភាពនិងសេចក្តីថ្លៃថ្នូរ។ ការផ្តល់បរិស្ថានអំណោយផលគឺដើម្បីធានាថា មនុស្សចាស់ពុំមានអារម្មណ៍ថាខ្លួនត្រូវបានរារាំងមិនឲ្យចូលរួមពេញលេញតាមរូបភាពណាមួយនៅក្នុងសកម្មភាពទាំងឡាយណាដែលពួកគាត់អាចចូលរួមនិងចង់ចូលរួម។ ធាតុផ្សំចម្បងៗនៃបរិស្ថានអំណោយផល រួមមាន មធ្យោបាយនិងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនសមស្របសន្តិសុខនិងការធានាឲ្យបាននូវការគោរពនិងសេចក្តីថ្លៃថ្នូរ។

**៣៩-** ការលុបបំបាត់ការរើសអើងលើអាយុ គឺជាលក្ខខណ្ឌចាំបាច់នៃបរិស្ថានអំណោយផល ព្រោះថាការរើសអើង នាំឲ្យមនុស្សចាស់បាត់បង់ការទុកចិត្តលើខ្លួនឯងនិងធ្វើឲ្យពួកគាត់បាក់ទឹកចិត្តមិនហ៊ានមកចូលរួមក្នុងសកម្មភាពនានា។ ប្រសិនបើមនុស្សចាស់បារម្ភខ្លាចគេមិនយកចិត្តទុកដាក់ជាមួយ គេមិនគោរព និងគេចំអកដាក់ ដោយសារតែពួកគាត់ចង់ចូលរួមក្នុងសកម្មភាពផ្សេងៗដែលមនុស្សវ័យក្មេងគិតថា ជាសកម្មភាពសម្រាប់តែមនុស្សក្មេងៗ នោះមនុស្សចាស់នឹងរារែកមិនចង់ចូលរួម។

**៤០-** ទន្ទឹមនឹងនេះ ប្រការដែលសំខាន់ផងដែរនោះគឺការបង្កើតឲ្យមានហេដ្ឋារចនាសម្ព័ន្ធសមស្របដែលមនុស្សចាស់(បង្គន់ ផ្លូវដើរ មធ្យោបាយធ្វើដំណើរសាធារណៈ ប្រព័ន្ធគមនាគមន៍) អាចប្រើប្រាស់បានដោយងាយស្រួលសម្រាប់ការចូលរួមរបស់ពួកគាត់នៅក្នុងសកម្មភាពនានា និងសម្រាប់ការស្វែងរកជំនួយនៅ ពេលដែលពួកគាត់ត្រូវការ។ ពេលបច្ចុប្បន្ននេះ ហេដ្ឋារចនាសម្ព័ន្ធទាំងនោះ

សម្រាប់មនុស្សចាស់ មានចំនួនតិចនៅក្នុងទីសាធារណៈ ដែលអាចបង្កការលំបាកដល់ការចូលរួមរបស់មនុស្សចាស់។

## ៤.៥- វ័យចាស់សកម្មនិងសមាគមមនុស្សចាស់

**៤១-** វ័យចាស់សកម្មគឺជាដំណើរការមួយដែលអនុញ្ញាតឲ្យមនុស្សចាស់អាចប្រើប្រាស់បាន នូវសក្ដានុពលរបស់ពួកគាត់សម្រាប់សុខុមាលភាពផ្នែករូបកាយ សង្គម និងស្មារតី និងអាចចូលរួមក្នុងសង្គមបាន រួមជាមួយនឹងការផ្ដល់ឲ្យពួកគាត់នូវការការពារសន្តិសុខនិងការថែទាំសមស្រប នៅពេលពួកគាត់ត្រូវការ។ ពេលពួកគាត់នៅតែ "សកម្ម" ក្នុងវ័យចាស់ មានន័យថាពួកគាត់នៅតែបន្តចូលរួមក្នុងការងារផ្នែកសង្គម សេដ្ឋកិច្ច វប្បធម៌ សាសនា និងការងារជាពលរដ្ឋ តទៅទៀត។ វ័យចាស់សកម្ម ពុំមែនមានន័យត្រឹមតែជាសមត្ថភាពផ្នែករូបកាយឬសមត្ថភាពចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចតែប៉ុណ្ណោះទេ។ មនុស្សចាស់ដែលលែងធ្វើការតទៅទៀត ដោយសារតែពួកគាត់បានចូលនិវត្តន៍ មានជំងឺឬពិការភាព ក៏នៅតែអាចសកម្មបានដូចមនុស្សចាស់ដទៃទៀតដែរ។ ការរក្សាបាននូវសេចក្ដីថ្លៃថ្នូរនិងឯករាជ្យភាពសម្រាប់មនុស្សចាស់គឺមានសារៈសំខាន់ណាស់សម្រាប់វ័យចាស់សកម្ម។

**៤២-** នៅកម្ពុជា សមាគមមនុស្សចាស់ផ្ដល់ឲ្យមនុស្សចាស់នូវឱកាសអាចរស់នៅក្នុងស្ថានភាពវ័យចាស់សកម្ម។ សមាគមមនុស្សចាស់គឺជាអង្គការថ្នាក់សហគមន៍មួយដែលមានគោលដៅជួយធ្វើឲ្យប្រសើរឡើងនូវសុខុមាលភាពរបស់មនុស្សចាស់ តាមរយៈសកម្មភាពជាសមូហភាព ដែលរៀបចំឡើងដោយមនុស្សចាស់ខ្លួនឯងផ្ទាល់។ ប្រទេសកម្ពុជា មានបណ្ដាញសមាគមមនុស្សចាស់យ៉ាងទូលំទូលាយ ដែលនៅរាយតាមគ្រប់ខេត្តទាំងអស់នៅទូទាំងប្រទេស។ សមាគមមនុស្សចាស់ផ្ដល់ឲ្យមនុស្សចាស់នូវកន្លែងសម្រាប់ជួបជុំគ្នា ឱកាសដើម្បីរៀបចំសកម្មភាពផ្សេងៗ និងវេទិកាសម្រាប់ការពិភាក្សាលើបញ្ហាដែលពាក់ព័ន្ធ។ ជាក់ស្ដែង សមាគមមនុស្សចាស់អាចដើរតួជាបណ្ដាញការប្រាស្រ័យទាក់ទងរវាងមនុស្សចាស់ជាមួយនឹងរដ្ឋាភិបាល ក្នុងគោលបំណងសម្ដែងនូវយោបល់របស់មនុស្សចាស់។ ក្នុងន័យនេះ សមាគមមនុស្សចាស់ គឺជាធាតុដ៏សំខាន់មួយនៅក្នុងដំណើរការវ័យចាស់សកម្ម ហើយការពង្រីកបណ្ដាញរបស់សមាគមមនុស្សចាស់ ការជួយរៀបចំកិច្ចដំណើរការរបស់សមាគមមនុស្សចាស់ ការគាំទ្រដល់សកម្មភាពរបស់សមាគមមនុស្សចាស់ និងការលើកទឹកចិត្តដល់មនុស្សចាស់ឲ្យចូលរួមនៅក្នុងសកម្មភាពរបស់សមាគម គឺជាការងារអាទិភាព។

## ៤.៦- ទំនាក់ទំនងអន្តរជំនាន់

**៤៣-** ការលើកកម្ពស់ទំនាក់ទំនងអន្តរជំនាន់ មានសារៈសំខាន់ណាស់ ក្នុងការធានាឲ្យមាននូវទំនាក់ទំនងប្រកបដោយភាពសុខដុមរវាងមនុស្សក្នុងវ័យខុសគ្នា។ ការរក្សានូវប្រព័ន្ធគ្រួសារដែលមានការរស់នៅជុំគ្នានៃមនុស្សច្រើនជំនាន់ដែលនៅតែជាសំណាញ់សុវត្ថិភាពដ៏មានប្រសិទ្ធភាពសម្រាប់

មនុស្សចាស់ គឺជាប្រការសំខាន់។ កិច្ចខិតខំប្រឹងប្រែងដើម្បីរក្សានូវភាពសុខដុមអន្តរជំនាន់ កាន់តែជួបការលំបាកខ្លាំងឡើងៗ ដោយសារមានការកើនឡើងនៃការជឿលើ "គម្លាតរវាងជំនាន់" ដែលត្រូវបានកំណត់ថា ជាភាពខុសគ្នាផ្នែកការយល់ឃើញនិងឥរិយាបថចំពោះស្ទើរតែគ្រប់ទិដ្ឋភាពទាំងអស់នៃជីវិតរវាងមនុស្សជំនាន់មួយនិងមនុស្សជំនាន់មួយទៀត ដែលទាំងនេះអាចខណ្ឌចែកមនុស្សវ័យក្មេងពីឪពុកម្ដាយនិងជីដូនជីតារបស់ពួកគេ។

**៤៤-** គ្រួសារដែលមានមនុស្សបីជំនាន់រស់នៅជាមួយគ្នា ពុំមែនសុទ្ធតែមានន័យថាជាគ្រួសារដែលមានទំនាក់ទំនងអន្តរជំនាន់ប្រកបដោយភាពសុខដុមនោះទេ។ ករណីដែលមនុស្សជំនាន់ខុសៗគ្នារស់នៅក្នុង "ដែនការងារ" របស់ខ្លួនរៀងៗខ្លួន សូម្បីតែរស់នៅក្នុងផ្ទះតែមួយជាមួយគ្នាក៏ដោយ មិនមែនជាប្រការមិនធម្មតានោះទេ។ ជីដូនជីតាដែលត្រូវបានគេទុកចោលឲ្យនៅតែឯងពេញមួយថ្ងៃ អាចមានអារម្មណ៍ឯកានៅក្នុងគ្រួសារដែលមានការរស់ជុំគ្នានៃមនុស្សច្រើនជំនាន់ ហើយសូម្បីតែពេលដែលកូននិងចៅរបស់ពួកគាត់ត្រឡប់មកពីធ្វើការនិងពីសាលារៀននៅពេលល្ងាចវិញហើយក៏ដោយ ក៏ពួកគាត់ប្រហែលជាអាចសម្ងំនៅតែក្នុងបន្ទប់ពួកគាត់ដដែល។ ជីដូនជីតា កូន និងចៅ ប្រហែលជាមិនទទួលទានអាហារជុំគ្នា និងធ្វើកិច្ចការរៀងៗខ្លួនដាច់ដោយឡែកពីគ្នា។

**៤៥-** វិធានការនានាដែលលើកទឹកចិត្តដល់អន្តរទំនាក់ទំនងរវាងមនុស្សមានវ័យផ្សេងគ្នា ដើម្បីលើកទឹកចិត្តដល់ទំនាក់ទំនងអន្តរជំនាន់ ត្រូវចាត់ទុកជាការងារអាទិភាព។ ផ្អែកតាមប្រពៃណីជាតិដ៏រឹងមាំ ប្រព័ន្ធគ្រួសារដែលមានការរស់ជុំគ្នានៃមនុស្សច្រើនជំនាន់ដែលចាក់ឫសគល់ក្នុងទូទាំងសង្គម ផ្ដល់នូវមូលដ្ឋានដ៏រឹងមាំមួយសម្រាប់ការពង្រឹងការប្រាស្រ័យទាក់ទងគ្នានិងភាពសុខដុមអន្តរជំនាន់។ ការពង្រឹងទំនាក់ទំនងអន្តរជំនាន់នឹងចូលរួមចំណែកក្នុងការធានាឲ្យមានវ័យចាស់សកម្ម និងក្នុងការជួយប្រជាជនវ័យក្មេងឲ្យត្រៀមខ្លួនសម្រាប់ការរស់នៅក្នុងវ័យចាស់។

## ៤.៧. ការរំលោភបំពាន ការមិនអើពើ និងអំពើហិង្សាលើមនុស្សចាស់

**៤៦-** ការរំលោភបំពានលើមនុស្សចាស់គឺជាការរំលោភបំពានផ្នែកពាក្យសំដីឬផ្នែករាងកាយ ការមិនអើពើ ការមិនស្ដាប់ដំបូន្មាន ការប្រព្រឹត្តដោយបន្ទាបបន្ថោក និងការដណ្ដើមទ្រព្យសម្បត្តិនិងកម្មសិទ្ធិពីសំណាក់អ្នកដែលត្រូវជាអ្នកផ្ដល់ការថែទាំដល់មនុស្សចាស់ទាំងនោះ មិនចំពោះថាតើពួកគេជាសមាជិកគ្រួសារឬជាអ្នកផ្ដល់ការថែទាំមិនជាប់សាច់ឈាមគ្នានោះទេ។ ដោយហេតុថា នៅកម្ពុជា វប្បធម៌នៃការគោរពមនុស្សចាស់មានកម្រិតខ្ពស់ នោះការរំលោភបំពានលើពួកគាត់ អាចមិនមានលក្ខណៈខ្លាំងក្លាទេ។ ទោះជាយ៉ាងណាក៏ដោយ ក៏ជាមួយនឹងការកើនឡើងនៃប្រជាជនវ័យចាស់និងការថយចុះនៃសមាមាត្រគាំទ្រសក្ដានុពល បន្ទុកកាន់តែច្រើនឡើងក្នុងការផ្ដល់ការគាំទ្រ និងការថែទាំសាច់ញាតិវ័យចាស់ អាចរុញច្រានគ្រួសារឬអ្នកថែទាំពីខាងក្រៅ ឲ្យងាកទៅរកអាកប្បកិរិយាដែលមានលក្ខណៈរំលោភបំពាន។ ភស្តុតាងក្នុងបណ្ដាប្រទេសផ្សេងទៀត នៅតំបន់អាស៊ីប៉ាស៊ីហ្វិកដែលនៅទីនោះ

ប្រពៃណីនៃការគោរពមនុស្សចាស់ក៏មានកម្រិតខ្ពស់ផងដែរ នោះបានបង្ហាញថាការមិនអើពើចំពោះមនុស្សចាស់កំពុងតែមានការកើនឡើង។

**៤៧-** ទោះបីជាប្រព័ន្ធគ្រួសារដែលមានការរស់នៅជុំគ្នានៃមនុស្សច្រើនជំនាន់ផ្តល់ឱកាសឲ្យមនុស្សចាស់រស់នៅប្រកបដោយផាសុខភាពនិងសេចក្តីថ្លៃថ្នូរ និងបំពេញបាននូវតម្រូវការទាំងឡាយនៃ "ដំណើរឈានចូលវ័យចាស់នៅនឹងកន្លែងដើម" ក៏ដោយ ក៏ស្ថានភាពនេះមិនគួរត្រូវបានចាត់ទុកថាល្អឥតខ្ចោះគ្មានចំណុចខ្វះខាតនោះដែរ។ ប្រការសំខាន់ដែលត្រូវកត់សម្គាល់នោះគឺថា ការរស់នៅក្នុងផ្ទះជាមួយគ្នា មិនប្រាកដជាអាចធានាបានដោយស្វ័យប្រវត្តិនូវការគាំពារសង្គមសម្រាប់មនុស្សចាស់ពីសំណាក់សមាជិកដទៃទៀតក្នុងគ្រួសារនោះទេ។ ជាមួយនឹងបន្ទុកនៃការផ្តល់ការថែទាំដែលនឹងមានកាន់តែច្រើនឡើងៗលើសមាជិកគ្រួសារវ័យក្មេង ពួកគេអាចមានអារម្មណ៍ថាខ្លួនត្រូវជាប់គាំងនៅក្នុងតួនាទីផ្តល់ការថែទាំនេះ ហើយអាចឈានទៅមិនសូវអើពើឬថែមទាំងអាចរំលោភបំពានលើមនុស្សចាស់ផងដែរ។ បញ្ហានេះពុំមែនជាបញ្ហាដែលងាយស្រួលដោះស្រាយនោះទេ ព្រោះថាការរំលោភបំពានប្រភេទនេះគឺពិបាកនឹងកត់សម្គាល់ឃើញណាស់ ដោយហេតុថា បញ្ហានេះកើតមានឡើងជាលក្ខណៈឯកជនក្នុងលំនៅឋានរបស់គ្រួសារ។ ជាមួយនឹងការកើនឡើងនៃភាពមិនអត់ធ្មត់របស់មនុស្សវ័យក្មេង ក្នុងតួនាទីខ្លួនជាអ្នកផ្តល់ការថែទាំ មនុស្សចាស់ច្រើនតែក្លាយជាជនរងគ្រោះនៃអំពើកំពេលតាមរូបភាពជាក់ស្តែងជាច្រើន ក៏ដូចជាការមិនទទួលបានការយកចិត្តទុកដាក់ រួមជាមួយនឹងការបំភ្លេចចោលនូវសេចក្តីត្រូវការជាមូលដ្ឋានរបស់ពួកគាត់ ការបដិសេធចោលនូវសេចក្តីថ្លៃថ្នូររបស់ពួកគាត់ និងការកាត់ផ្តាច់នូវការធ្វើទំនាក់ទំនងសង្គមទាំងឡាយរបស់ពួកគាត់។ ការរំលោភបំពានលើមនុស្សចាស់ នៅតែជាស្ថានភាពមួយដែលជាទូទៅមិនត្រូវបានរាយការណ៍ ក្នុងគោលបំណងការពារកិត្តិយសគ្រួសារ។ ឧបសគ្គមួយទៀតដែលរារាំងចំពោះការដាក់ពាក្យបណ្តឹងអំពីការរំលោភបំពាន គឺការភ័យខ្លាចត្រូវរងការរំលោភបំពានកាន់តែខ្លាំងឡើងថែមទៀត ទម្រាំនឹងអាចរកយុត្តិធម៌ឃើញ។

**៤៨-** បើប្រៀបធៀបនឹងការរំលោភបំពានលើមនុស្សចាស់ អំពើហិង្សាត្រូវបានកំណត់និយមន័យថាជាបទឧក្រិដ្ឋលើមនុស្សចាស់។ អំពើដែលអាចមានលក្ខណៈហិង្សារួមមាន ការធ្វើបាបផ្នែករាងកាយ និងការរំលោភសេពសន្ថវៈ ឬការឆក់ប្លន់ ឬសូម្បីតែការកេងបន្លំក៏អាចចាត់ចូលជាអំពើហិង្សាបានដែរ។ ជាមួយនឹងការកើនឡើងដែលប៉ាន់ស្មានដឹងជាមុនបាននៃចំនួនមនុស្សចាស់ ជាពិសេស ស្ត្រីគ្មានស្វាមីដែលត្រូវរស់នៅតែម្នាក់ឯងនោះ ករណីបទឧក្រិដ្ឋលើពួកគាត់អាចនឹងកើនឡើង។

**៤៩-** ក្នុងបរិការណ៍នេះ ការធ្វើផែនការរយៈពេលវែងដែលអាចយកទៅអនុវត្តបានជាក់ស្តែង ពិតជាមានសារៈសំខាន់ ក្នុងការដោះស្រាយបញ្ហានេះ ដើម្បីធានាឲ្យមានការទប់ស្កាត់ការរំលោភបំពានលើមនុស្សចាស់ និងការពារមនុស្សចាស់ពីជនឧក្រិដ្ឋ។

## ៤.៨- ស្ថានភាពមានអាសន្ន

**៥០-** ក្នុងស្ថានភាពមានអាសន្នដូចជា គ្រោះមហន្តរាយធម្មជាតិនិងជម្លោះស៊ីវិល ជាដើម មនុស្សចាស់ប្រឈមនឹងហានិភ័យនៃការមិនទទួលបានគ្រប់គ្រាន់នូវការសង្គ្រោះនិងការស្តារសមត្ថភាពកាយសម្បទា។ ពួកគាត់អាចរងការបដិសេធមិនឲ្យទទួលបាននូវជំនួយនិងសម្ភារៈចាំបាច់នានា។ សេចក្តីត្រូវការពិសេសរបស់ពួកគាត់ដែលទាក់ទងនឹងការផ្លាស់ទីនិងសេវាថែទាំផ្នែកវេជ្ជសាស្ត្រ ជាញឹកញាប់មិនត្រូវបានឆ្លើយតប។ ក្នុងករណីដែលពួកគាត់ត្រូវផ្លាស់ទីលំនៅ ការមិនមានបំណងផ្លាស់ទីកន្លែងគួបផ្សំជាមួយនឹងការលំបាកផ្នែករាងកាយ ដែលពួកគាត់ត្រូវជួបប្រទះក្នុងការផ្លាស់កន្លែងផងនោះ ធ្វើឲ្យពួកគាត់ត្រូវប្រឈមនឹងហានិភ័យកាន់តែខ្ពស់ ក្នុងការទុកចោលឲ្យនៅតែម្នាក់ឯង។ ការធ្វើបែបនេះនឹងធ្វើឲ្យពួកគាត់មានភាពងាយរងគ្រោះចំពោះការកេងប្រវ័ញ្ច ការរំលោភបំពាន និងអំពើហិង្សា។ ភស្តុតាងដែលត្រូវបានកត់សម្គាល់ឃើញនៅប្រទេសផ្សេងៗជាច្រើនបង្ហាញថា បុគ្គលិកសង្គ្រោះនិងបុគ្គលិកផ្តល់ជំនួយ ជាញឹកញាប់ មិនបានផ្តល់ការចាប់អារម្មណ៍ឲ្យបានគ្រប់គ្រាន់ចំពោះមនុស្សចាស់។ ជាលទ្ធផល មនុស្សចាស់បានទទួលរងការស្លាប់និងការមានរបួសនៅក្នុងពេលមានគ្រោះធម្មជាតិ ក្នុងសមាមាត្រមួយច្រើនជាង ក្នុងពេលមានស្ថានភាពមានអាសន្នផ្សេងទៀត។

**៥១-** រាជរដ្ឋាភិបាលកម្ពុជាបានយកចិត្តទុកដាក់ខ្ពស់ចំពោះការការពារជីវិតនិងទ្រព្យសម្បត្តិរបស់ប្រជាជននៅក្នុងពេលមានគ្រោះធម្មជាតិកើតឡើង ហើយបានបង្កើតយន្តការស្ថាប័នដ៏ទូលំទូលាយទាំងនៅថ្នាក់ជាតិ ទាំងនៅថ្នាក់ក្រោមជាតិ សម្រាប់ការគ្រប់គ្រងគ្រោះមហន្តរាយពោលគឺ គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយដែលត្រូវបានបង្កើតឡើងតាមព្រះរាជក្រឹត្យលេខនស/រកត/១២១៥/១១៤១ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ២០១៥ ដោយមានសម្តេចនាយករដ្ឋមន្ត្រីជាប្រធាន។

**៥២-** ក្នុងស្ថានភាពបែបនេះ ការយល់ដឹងពីភាពចាំបាច់ក្នុងការផ្តោតការយកចិត្តទុកដាក់លើសេចក្តីត្រូវការពិសេសរបស់មនុស្សចាស់ក្នុងកំលុងពេលប្រតិបត្តិការ សង្គ្រោះ ផ្តល់ជំនួយ និងស្តារសមត្ថភាពកាយសម្បទា។ ក្នុងន័យនេះ ប្រការសំខាន់ដែលត្រូវផ្តោតការយកចិត្តទុកដាក់លើនោះ គឺការបង្កើនការយល់ដឹងរបស់អ្នកធ្វើគោលនយោបាយ អ្នកធ្វើផែនការ និងអ្នកឆ្លើយតបសម្រាប់គ្រាមានអាសន្ន ដើម្បីកំណត់និងដាក់បញ្ចូលសកម្មភាព "ឆ្លើយតបនឹងបញ្ហាមនុស្សវ័យចាស់" នៅក្នុងការធ្វើផែនការសម្រាប់ ការឆ្លើយតបទៅនឹង និងការជួយស្តារឡើងវិញពីស្ថានភាពមានអាសន្ន។

## ៤.៩- ការត្រៀមខ្លួនរបស់មនុស្សវ័យក្មេងសម្រាប់ការឈានចូលវ័យចាស់

**៥៣-** ការបន្តកើនឡើងថែមទៀតនៃចំនួនប្រជាជនវ័យចាស់ គឺជាករណីដែលមិនអាចជៀសបាន។ ចំណុចវិជ្ជមាននៅក្នុងទិដ្ឋភាពនេះគឺថា អ្នកដែលនឹងឈានចូលវ័យចាស់នាពេលអនាគតទាំងនោះ គឺកំពុងរស់នៅក្នុងពេលបច្ចុប្បន្នរួចហើយ។ ដោយហេតុថាមនុស្សគ្រប់រូបនឹងឈានទៅដល់វ័យចាស់នោះម្នាក់ៗត្រូវតែខ្វល់ខ្វាយចំពោះជីវិតរបស់ខ្លួន នៅក្នុងពេលខាងមុខដែលនឹងត្រូវមកដល់។ តាមរយៈ

ការសង្កេតទៅលើមនុស្សចាស់ មនុស្សវ័យក្មេងគួរតែស្វែងយល់ដឹងពីសណ្ឋាននៃដំណើរជីវិតរស់នៅក្នុងពេលខាងមុខ នៅពេលដែលពួកគេឆ្លងផុតអាយុ៦០ឆ្នាំ។ មនុស្សវ័យក្មេង កំពុងស្ថិតក្នុងស្ថានភាពមួយដែលសំណាង ព្រោះថាពួកគេនៅអាចចាប់ផ្តើមត្រៀមរៀបចំខ្លួនចាប់ពីពេលឥឡូវនេះទៅសម្រាប់ដំណើរជីវិតរស់នៅមួយល្អប្រសើរនៅក្នុងវ័យចាស់។

**៩៤-** ប្រជាជនវ័យក្មេងអាចមានចំណេះដឹងល្អប្រសើរជាង ដែលអាចជួយឲ្យពួកគេរស់នៅក្នុងជីវិតមួយដែលបង្កើតផលបានច្រើនជាង មានសុខភាពល្អជាង សកម្មជាង និងមានសេចក្តីថ្លៃថ្នូរជាង នៅក្នុងវ័យចាស់។ ពិនិត្យជារួម មនុស្សចាស់ជួបប្រទះបញ្ហាសំខាន់ៗមួយចំនួនដែលអាចងាយកត់សម្គាល់បានក្នុងនោះរួមមាន អសន្តិសុខផ្នែកហិរញ្ញវត្ថុ សុខភាពកាន់តែដុនដាប កង្វះទីជម្រកសមរម្យ ភាពមានកម្រិតនៃការផ្លាស់ទី និងការកើនឡើងនៃការពឹងផ្អែកលើអ្នកដទៃ។ មនុស្សម្នាក់អាចធ្វើផែនការឲ្យហើយ នៅពេលខ្លួនស្ថិតក្នុងវ័យធ្វើការងារ ដើម្បីកាត់បន្ថយឬលុបបំបាត់ហានិភ័យទាំងនោះនៅពេលដែលគាត់មានវ័យចាស់ទៅ។ ការវិនិយោគលើប្រាក់សន្សំរបស់ខ្លួនឯង និងការចុះឈ្មោះ ទិញគម្រោងធានារ៉ាប់រងនិងសោធននិវត្តន៍ អាចជួយបានយ៉ាងច្រើនក្នុងការកាត់បន្ថយការលំបាកផ្នែកហិរញ្ញវត្ថុនៅក្នុងវ័យចាស់។ ការរក្សាបាននូវទម្លាប់ក្នុងការរស់នៅមួយដែលនាំឲ្យមានសុខភាពល្អ និងការទៅត្រួតពិនិត្យសុខភាពតាមពេលកំណត់ជាប្រចាំ អាចជួយឲ្យជីវិតក្នុងវ័យចាស់ឲ្យមានសុខភាពល្អប្រសើរជាងការមិនប្រកាន់ខ្ជាប់នូវការធ្វើបែបនេះ។ ការបង្រៀនកូនចៅអំពីសារៈសំខាន់នៃការគោរពនិងការថែទាំមនុស្សចាស់ អាចជួយបង្កើនលទ្ធភាពនៃការទទួលបានការគាំទ្រពីគ្រួសារនៅក្នុងវ័យចាស់។ វិធីដែលមានប្រសិទ្ធភាពបំផុតក្នុងការបង្រៀន គឺការត្រូវធ្វើជាគំរូ ដោយតាមរយៈនេះឪពុកម្តាយគួរតែគោរពនិងថែទាំសាច់ញាតិវ័យចាស់របស់ខ្លួន ដើម្បីឲ្យកូនៗរបស់ខ្លួនមើលយកជាគំរូ។

**៩៥-** ប្រសិនបើមនុស្សវ័យក្មេងមានការត្រៀមខ្លួនបានកាន់តែប្រសើរសម្រាប់ពេលដែលពួកគាត់ឈានដល់វ័យចាស់នោះ បញ្ហានានាដែលពួកគាត់អាចជួបប្រទះក្នុងវ័យចាស់ នឹងអាចត្រូវបានដោះស្រាយដោយងាយស្រួលជាងការមិនបានត្រៀមខ្លួន។ ដោយមានការព្យាករថា ប្រជាជនវ័យចាស់នឹងកើនឡើងយ៉ាងឆាប់រហ័ស នោះបញ្ហាទាក់ទងនឹងវ័យចាស់កាន់តែអាចត្រូវបានដោះស្រាយ ដោយភាពងាយស្រួល បើសមាមាត្រមនុស្សចាស់ដែលបានត្រៀមខ្លួនរួចជាស្រេច សម្រាប់វ័យចាស់មានទំហំកាន់តែធំ។ ក្នុងន័យនេះ វិធានការនានាដើម្បីជួយដល់ប្រជាជនក្នុងវ័យកំពុងធ្វើការងារឲ្យអាចត្រៀមខ្លួនដើម្បីទទួលបានជីវិតមួយដែលសកម្មនិងមានសុខភាពល្អក្នុងវ័យចាស់។

## ៥- ក្របខ័ណ្ឌគោលនយោបាយនិងគោលការណ៍ណែនាំ

### ៥.១- បរិការណ៍

**៥៦-** គោលនយោបាយមនុស្សចាស់ឆ្នាំ២០០៣ ត្រូវបានកែសម្រួលឡើងវិញ ដោយផ្អែកលើឯកសារនិងគោលនយោបាយជាតិពាក់ព័ន្ធជាច្រើននិងការផ្តួចផ្តើមគំនិតថ្នាក់អន្តរជាតិនិងថ្នាក់តំបន់ដែលកម្ពុជាបានអនុម័តទទួលយក។

**៥៧-** ជាពិសេស ការកែសម្រួលនេះត្រូវបានធ្វើឡើងដោយផ្អែកជាសំខាន់លើតម្លៃគ្រួសារនិងសិទ្ធិរបស់ឪពុកម្តាយមានវ័យចាស់ ក្នុងការទទួលបាននូវការថែទាំពីកូនចៅពេញវ័យរបស់ពួកគាត់ទៅតាមវប្បធម៌ខ្មែរ ដូចដែលបានគូសបញ្ជាក់យ៉ាងច្បាស់នៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

**៥៨-** *មាត្រា៤៧.- មាតាបិតា មានកាតព្វកិច្ចចិញ្ចឹមថែរក្សានិងអប់រំកូនឲ្យទៅជាពលរដ្ឋល្អ។ កូនៗមានករណីកិច្ចចិញ្ចឹមនិងបីបាច់ថែរក្សាមាតាបិតា ដែលចាស់ជរាតាមទំនៀមទម្លាប់ខ្មែរ។*

**៥៩-** ប្រការនេះ ដាក់ឲ្យទៅជាច្បាប់នូវ "កិច្ចសន្យាអន្តរជំនាន់ដោយគ្មានលក្ខខណ្ឌ" ស្តីពីការថែទាំគ្នាទៅវិញទៅមក ដោយធ្វើឲ្យកូនចៅជាមនុស្សពេញវ័យត្រូវមានករណីយកិច្ចគោរព និងថែទាំឪពុកម្តាយ វ័យចាស់របស់ខ្លួន។ ក្នុងបរិការណ៍នៃទំនៀមទម្លាប់ខ្មែរ កាតព្វកិច្ចនេះរួមបញ្ចូលផងដែរនូវការថែទាំសាច់ញាតិជាមនុស្សចាស់ដទៃទៀតដែលពុំមានមធ្យោបាយគាំទ្រ។ ការពាក់ព័ន្ធដ៏សំខាន់នៃបទបញ្ញត្តិ នៃរដ្ឋធម្មនុញ្ញនេះ គឺត្រូវដាក់គោលនយោបាយនេះឲ្យនៅក្នុងបរិការណ៍វប្បធម៌ និងផ្តល់អាទិភាពដល់ការលើកកម្ពស់ "ដំណើរឈានចូលវ័យចាស់នៅនឹងកន្លែងដើម" និងការចាត់ទុកគ្រួសារថាជាបណ្តាញសុវត្ថិភាពចម្បងសម្រាប់មនុស្សចាស់។

**៦០-** យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ បង្ហាញច្បាស់ពីទិសដៅគោលនយោបាយរួមរបស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់មនុស្សចាស់ ។ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨ ក៏កំណត់ច្បាស់ពីភាពចាំបាច់ក្នុងការជំរុញការអនុវត្ត គោលនយោបាយជាតិមនុស្សចាស់ និងដាក់បញ្ចូលនូវសកម្មភាពជាក់លាក់មួយចំនួនដូចជា ការបង្កើតគណៈកម្មាធិការជាតិដើម្បីមនុស្សចាស់និងយន្តការថ្នាក់ក្រោមជាតិសម្រាប់ការអនុវត្តគោលនយោបាយមនុស្សវ័យចាស់ផងដែរ។ ការអភិវឌ្ឍនាពេលថ្មីៗនេះមួយទៀត (ខែកញ្ញា ឆ្នាំ២០១៦) គឺការអនុម័តលើគោលនយោបាយនិងយុទ្ធសាស្ត្រសុខាភិបាលជាតិសម្រាប់ថែទាំសុខភាពមនុស្សចាស់របស់ក្រសួងសុខាភិបាល។ ជាមួយគ្នានេះដែរ គោលនយោបាយជាតិប្រជាជន ២០១៦-២០៣០ ក៏រំលេចឡើងយ៉ាងច្បាស់ពីការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលក្នុងការលើកកម្ពស់សុខុមាលភាពរបស់មនុស្សវ័យចាស់ ហើយក៏បានកំណត់នូវចង្កោមសកម្មភាពមួយចំនួនដែលត្រូវសម្រេចឲ្យបានផងដែរ។

**៦១-** "រាជរដ្ឋាភិបាល ប្តេជ្ញាចិត្តបន្តជំរុញគោលនយោបាយជាតិមនុស្សចាស់បន្ថែមទៀត បន្តពង្រឹងសមាគមមនុស្សចាស់ លើកកម្ពស់កម្មវិធីសុខុមាលភាពសម្រាប់មនុស្សចាស់នៅថ្នាក់មូលដ្ឋាន និងលើកកម្ពស់កម្មវិធីការថែទាំមនុស្សចាស់នៅកម្រិតគ្រួសារ និងជាពិសេស គឺពង្រឹងការរៀបចំនិងដំណើរការក្នុងការផ្តល់សេវាដល់ជនចាស់ជរា រួមទាំងការផ្តល់ការបណ្តុះបណ្តាលដល់អ្នកមើលថែរបស់ពួកគាត់ផងដែរ" ។

**៦២-** ជាមួយនឹងការផ្តួចផ្តើមគំនិតកម្រិតសកលលោក រាជរដ្ឋាភិបាលកម្ពុជាគឺជាភាគីហត្ថលេខីមួយនៃកម្មវិធីសកម្មភាពរបស់សន្និសីទអន្តរជាតិស្តីពីប្រជាជននិងការអភិវឌ្ឍ(ទីក្រុងគែរ ឆ្នាំ១៩៩៤) និងការពិនិត្យឡើងវិញរយៈពេលប្រាំឆ្នាំដែលត្រូវបានធ្វើឡើងជាបន្តបន្ទាប់។ លើសពីនេះ រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តគាំទ្រដល់សេចក្តីថ្លែងការណ៍នយោបាយរបស់សន្និបាតពិភពលោកលើកទីពីរស្តីពីមនុស្សចាស់(ក្រុងម៉ាឌ្រីត ឆ្នាំ២០០២) ហើយបានប្តេជ្ញាចិត្តអនុវត្តផែនការសកម្មភាពអន្តរជាតិទីក្រុងម៉ាឌ្រីតស្តីពីមនុស្សចាស់(MIPAA)។ ផែនការសកម្មភាពអន្តរជាតិទីក្រុងម៉ាឌ្រីតស្តីពីមនុស្សចាស់ព្យាយាមពង្រីកចក្ខុវិស័យស្តីពីជនចាស់ជរាបន្ថែមទៀត តាមរយៈការផ្តោតលើភាពចាំបាច់ក្នុងការទទួលស្គាល់សក្តានុពលនិងការចូលរួមវិភាគទានរបស់មនុស្សចាស់ បន្ថែមពីលើការយកចិត្តទុកដាក់ចំពោះមនុស្សចាស់។ ផែនការសកម្មភាពនេះ អំពាវនាវឲ្យមានការដាក់បញ្ចូលបញ្ហាជនចាស់ជរាទៅក្នុងផែនការអភិវឌ្ឍន៍ជាតិនិងផែនការអភិវឌ្ឍន៍តាមវិស័យ។ ការសម្រេចបានប្រកបដោយជោគជ័យនូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព ក៏នឹងទាមទារឲ្យមានការគិតគូរដល់ប្រជាជនវ័យចាស់ដែលមានចំនួនកាន់តែកើនឡើងផងដែរ។ គោលដៅសំខាន់ៗក្នុង ការលុបបំបាត់ភាពក្រីក្រ ការលុបបំបាត់ភាពស្រេកឃ្លាន និងការធានាបាននូវសមភាពយេនឌ័ររបស់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព គឺពិតជាមិនអាចសម្រេចបានទេ ប្រសិនបើគ្មានការដាក់បញ្ចូលប្រជាជនវ័យចាស់ដែលកំពុងមានការកើនឡើងទៅក្នុងចំណោមអ្នកទទួលផលប្រយោជន៍ពីកម្មវិធីពាក់ព័ន្ធទាំងឡាយនោះ។

**៦៣-** កម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងចំពោះស្ត្រី (CEDAW) ក្នុងឆ្នាំ១៩៩២។ នៅឆ្នាំ២០១២ កម្ពុជាបានក្លាយជាប្រទេសអាស៊ានទី៧ ដែលបានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិជនពិការ ដែលត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិនៅឆ្នាំ២០០៦។ ទោះបីជាវ័យចាស់និងពិការភាពជាបញ្ហាពីរខុសគ្នាក៏ដោយ ក៏ករណីពិការភាពត្រូវបានកត់សម្គាល់ឃើញថាមានការកើនឡើងនៅពេលអាយុកាន់តែច្រើន ហើយប៉ះពាល់ដល់ស្ត្រីវ័យចាស់ច្រើនជាងបុរសវ័យចាស់។ ការផ្តល់សច្ចាប័នលើអនុសញ្ញានេះបង្ហាញថា រាជរដ្ឋាភិបាលកម្ពុជាមានការប្តេជ្ញាចិត្តខ្ពស់ ក្នុងការដោះស្រាយបញ្ហាទាំងឡាយពាក់ព័ន្ធនឹងប្រជាជនដែលរស់នៅជាមួយនឹងពិការភាព។

**៦៤-** នៅថ្នាក់តំបន់ កម្ពុជាបានប្តេជ្ញាចិត្តចំពោះផែនការសកម្មភាពទីក្រុងម៉ាកាវស្តីពីមនុស្សវ័យចាស់ សម្រាប់តំបន់អាស៊ីនិងប៉ាស៊ីហ្វិក(ឆ្នាំ១៩៩៩) យុទ្ធសាស្ត្រសម្រាប់ការអនុវត្តថ្នាក់តំបន់ក្រុង

សៀងហៃស្តីពីមនុស្សចាស់(ឆ្នាំ២០០២) និងយុទ្ធសាស្ត្រថ្នាក់តំបន់នៃអង្គការសុខភាពពិភពលោកសម្រាប់មនុស្សវ័យចាស់ប្រកបដោយសុខភាពល្អ (២០១៣-២០១៨)។ លើសពីនេះ ក្នុងឋានៈជាសមាជិកអាស៊ាន កម្ពុជាប្តេជ្ញាចិត្តចំពោះសេចក្តីថ្លែងការណ៍ក្រុងគូឡាឡាំពួស្តីពីមនុស្សវ័យចាស់ដែលត្រូវបានអនុម័តនៅក្នុងកិច្ចប្រជុំកំពូលលើកទី២៧របស់អាស៊ានក្នុងឆ្នាំ២០១៥។ សេចក្តីថ្លែងការណ៍នេះបានអំពាវនាវឲ្យរដ្ឋជាសមាជិកនីមួយៗជំរុញការអនុវត្តសកម្មភាពជាក់ស្តែងទាំងឡាយសំដៅផ្តល់ការលើកទឹកចិត្តដល់មនុស្សចាស់ ដោយអនុលោមទៅតាមច្បាប់ គោលនយោបាយ និងកម្មវិធីជាតិរបស់ប្រទេសនីមួយៗ។ សកម្មភាពទាំងនេះរួមមានការបញ្ជ្រាបបញ្ហាវ័យចាស់ទៅក្នុងគោលនយោបាយ និងផែនការអភិវឌ្ឍន៍ និងការពង្រឹងគ្រួសារនិងសហគមន៍ឲ្យផ្តល់ការថែទាំដល់មនុស្សចាស់។

## ៥.២- គោលការណ៍ណែនាំ

**៦៥-** នៅក្នុងបរិការណ៍នៃឧបករណ៍ដែលមានលក្ខណៈជាការណែនាំនិងការផ្តួចផ្តើមគំនិតនៅថ្នាក់ជាតិ ថ្នាក់សកលនិងថ្នាក់តំបន់ទាំងអស់នេះ ការកែសម្រួលឡើងវិញនូវគោលនយោបាយសម្រាប់មនុស្សចាស់ឆ្នាំ២០០៣ ត្រូវបានតម្រង់ទិសតាមគោលការណ៍ដូចមានរៀបរាប់ខាងក្រោម។ គោលការណ៍ទាំងនេះ ក៏ត្រូវយកមកប្រើប្រាស់ផងដែរនៅក្នុងដំណាក់កាលនៃការអនុវត្តៈ

- ផ្តោតការយកចិត្តទុកដាក់ឲ្យបានសមស្របចំពោះស្ថានភាពរបស់មនុស្សចាស់ ដូចបានកំណត់នៅក្នុងវប្បធម៌និងប្រពៃណីខ្មែរ នៅពេលដែលធ្វើការដោះស្រាយបញ្ហាទាំងឡាយដែលមនុស្សចាស់កំពុងជួបប្រទះ។
- បញ្ជ្រាបបញ្ហាប្រជាជនវ័យចាស់ទៅក្នុងផែនការនិងកម្មវិធីអភិវឌ្ឍ ដោយមានការទទួលស្គាល់ពេញលេញនូវសិទ្ធិរបស់មនុស្សចាស់ ក្នុងការចូលរួមត្រៀមរៀបចំការសម្រេចចិត្តទាំងឡាយណាដែលប៉ះពាល់ចំពោះពួកគាត់។
- យកចិត្តទុកដាក់ចំពោះភាពខុសប្លែកគ្នានៃសេចក្តីត្រូវការរបស់មនុស្សចាស់ ដែលបណ្តាលមកពីភាពខុសគ្នាផ្នែកអាយុ ជាតិពន្ធុ សាសនា ស្ថានភាពសុខភាព កម្រិតការអប់រំ និងស្ថានភាពសេដ្ឋកិច្ច នៅពេលដែលធ្វើការដោះស្រាយបញ្ហាទាំងឡាយដែលពាក់ព័ន្ធនឹងមនុស្សចាស់។
- ផ្តោតការយកចិត្តទុកដាក់ជាពិសេសលើស្ត្រីវ័យចាស់ ព្រោះពួកគាត់មានចំនួនច្រើនជាងបុរសវ័យចាស់ ហើយងាយរងគ្រោះច្រើនជាងបុរស ដោយសារពួកគាត់អាចទទួលរងការរើសអើងច្រើនជាង ហើយអាចងាយក្លាយជា ជនក្រីក្រ ស្ត្រីមេម៉ាយ និងអ្នកដែលត្រូវគេបំភ្លេចច្រើនជាង។

- ការគិតគូររៀបចំនិងការអនុវត្តវិធានការនានា ដើម្បីដោះស្រាយដំណើរឈានចូលវ័យចាស់ ដោយត្រូវយកចិត្តទុកដាក់លើការផ្តួចផ្តើមគំនិតថ្នាក់អន្តរជាតិនិងថ្នាក់តំបន់ថ្មីៗដែលពាក់ព័ន្ធនឹងមនុស្សចាស់។

## ៦- ចក្ខុវិស័យនិងគោលដៅ

### ៦.១- ចក្ខុវិស័យ

- បន្តលើកកម្ពស់និងកែលម្អគុណភាពជីវិតរបស់មនុស្សចាស់ ដោយផ្តោតការយកចិត្តទុកដាក់លើការធានាឲ្យមនុស្សចាស់ទទួលបាននូវសិទ្ធិនិងឱកាសស្មើគ្នា។

### ៦.២- គោលដៅ

- ធានាថា មនុស្សចាស់ត្រូវបានជំរុញឲ្យចូលរួមយ៉ាងពេញលេញ ដោយសេរី និងដោយសេចក្តីថ្លៃថ្នូរ តាមដែលពួកគាត់ចង់នៅក្នុងសកម្មភាព គ្រួសារ សហគមន៍ សេដ្ឋកិច្ចសង្គម សាសនា និង នយោបាយ។
- ធានាថា មនុស្សវ័យក្មេងត្រូវបានបណ្តុះបណ្តាលឲ្យមានចំណេះដឹង កាន់តែល្អប្រសើរដែលនឹងអាចជួយឲ្យពួកគាត់គ្រប់គ្រងដំណើរជីវិតរស់នៅមួយ ដែលបង្កើតផលផ្លែប្រកបដោយសុខភាពល្អ សកម្ម និងប្រកបដោយសេចក្តីថ្លៃថ្នូរ ច្រើនជាងអ្នកជំនាន់មុន នៅពេលពួកគាត់ឈានដល់វ័យចាស់។

### ៦.៣- ទិសដៅនិងយុទ្ធសាស្ត្រ

**៦៦-** ដើម្បីសម្រេចបានតាមចក្ខុវិស័យនិងគោលដៅខាងលើ គោលនយោបាយនេះ នឹងឆ្លើយតបទៅនឹងបញ្ហាទាំងឡាយ ដែលត្រូវបានរំពឹងថានឹងកើតមានឡើងជាមួយនឹងដំណើរឈានទៅរកវ័យចាស់ ដូចមានកំណត់ក្នុងផ្នែកទី៤។ ទិសដៅនិងយុទ្ធសាស្ត្រដើម្បីឆ្លើយតបទៅនឹងបញ្ហានីមួយៗ ត្រូវបានគូសបញ្ជាក់នៅក្នុងផ្នែកនេះ។ លំដាប់លំដោយនៃការរៀបចំបញ្ហាអាទិភាពមិនបញ្ជាក់ថា អាទិភាពណាមួយមានសារៈសំខាន់ជាងអាទិភាពណាមួយទៀតនោះឡើយ។ ជាការពិត អាទិភាពជាច្រើនមានទំនាក់ទំនងជាមួយគ្នាទៅវិញទៅមក ហើយដូចនេះ អាទិភាពទាំងនោះមានសារៈសំខាន់ស្មើគ្នា។

#### ៦.៣.១- អាទិភាពទី១ : ការធានាឲ្យបាននូវសន្តិសុខហិរញ្ញវត្ថុ

ទិសដៅ ១.១ : **បង្កលក្ខណៈឲ្យមនុស្សចាស់អាចមានឱកាសបន្តធ្វើការងារដែលផ្តល់ផលផ្លែក្នុងករណីដែលពួកគាត់ចង់ និងមានលទ្ធភាពអាចធ្វើបាន។**

**យុទ្ធសាស្ត្រ៖**

(i) បង្កើនការយល់ដឹងអំពីការរើសអើងនៅក្នុងការងារ ដោយផ្អែកលើអាយុក្នុងចំណោមអ្នកមានចំណែកពាក់ព័ន្ធសំខាន់ៗ រួមមាន ក្រុមមនុស្សចាស់ សហជីពកម្មករ និងសមាគមនិយោជក។

(ii) ជំរុញការបង្កើតក្របខ័ណ្ឌគាំទ្រផ្នែកច្បាប់ សម្រាប់ករណីការរើសអើងផ្អែកអាយុ។

(iii) បញ្ជ្រាបការយល់ដឹងដល់និយោជកអំពីបទពិសោធនិងសក្តានុពលវិជ្ជមានរបស់កម្មករនិយោជិតវ័យចាស់។

(iv) ដាក់ឲ្យមានបទបញ្ញត្តិច្បាប់ដែលតម្រូវឲ្យនិយោជកផ្តល់នូវលក្ខខណ្ឌការងារ ដូចជា គ្រឿងបរិក្ខារដែលងាយប្រើប្រាស់ អាហារដែលផ្តល់សុខភាពល្អ សេវាសុខភាពមូលដ្ឋាន និងបរិស្ថានកន្លែងធ្វើការងារទូទៅដែលសមស្របសម្រាប់កម្មករនិយោជិតវ័យចាស់។

(v) សិក្សាពីលទ្ធភាពនៃការរៀបចំប្រព័ន្ធលើកទឹកចិត្តសម្រាប់សហគ្រាសដែលជួលបុគ្គលិក កម្មករ និយោជិតវ័យចាស់ ហើយនិងលើកទឹកចិត្តឲ្យសហគ្រាសទាំងនោះឲ្យផ្តល់ការសម្រួលនិងលក្ខខណ្ឌការងារសមស្រប។

(vi) លើកកម្ពស់លទ្ធភាពអាចធ្វើការងារបានរបស់មនុស្សចាស់ តាមរយៈសមត្ថភាពជំនាញដែលមានស្រាប់ឬការបណ្តុះបណ្តាលឡើងវិញនិងការអប់រំជាប្រចាំ។

(vii) ពិចារណាដាក់ចេញនូវវិធានការដើម្បីសម្រួលដល់ការធ្វើដំណើរទៅធ្វើការរបស់កម្មករនិយោជិតវ័យចាស់ ដោយគិតគូរឲ្យមានតម្លៃសមរម្យសម្រាប់ការប្រើប្រាស់មធ្យោបាយធ្វើដំណើរសាធារណៈ។

(viii) សិក្សាពីលទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុ សម្រាប់មនុស្សចាស់។

**និសដោ ១.២ : ពង្រីកដែនគ្របដណ្តប់នៃគម្រោងកិច្ចគាំពារសង្គមនិងសុខុមាលភាពសង្គមដែលមានលក្ខណៈទូលំទូលាយ**

**យុទ្ធសាស្ត្រ :**

(i) សិក្សាពីលទ្ធភាពក្នុងការដាក់ឲ្យដំណើរការកម្មវិធីគាំពារមនុស្សចាស់និងជនចាស់ជរាដែលជាសមាជិកនៃគ្រួសារដែលកាន់បណ្ណសមធម៌ ស្រមតាមក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម។

(ii) ពិនិត្យលទ្ធភាពក្នុងការដាក់ឲ្យអនុវត្តនូវកម្រាលគាំពារសង្គមដើម្បីធានាថា មនុស្សចាស់ដែលគ្មានប្រាក់សោធននិវត្តន៍ឬមានមិនគ្រប់គ្រាន់ ហើយដែលគ្មានសមាជិកគ្រួសារមើលថែ អាចទទួលបាននូវប្រាក់ចំណូលសមរម្យ ដើម្បីកុំឲ្យពួកគាត់ធ្លាក់ចូលទៅក្នុងភាពក្រីក្រ។

(iii) បង្កើនការយល់ដឹងនិងជំរុញកូនចៅជាមនុស្សពេញវ័យដែលមានលទ្ធភាពផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុដល់ឪពុកម្តាយឬជីដូនជីតាចាស់ជរានិងសាច់ញាតិជិតស្និទ្ធរបស់ខ្លួន ដើម្បីបំពេញករណីយកិច្ចរបស់ខ្លួនក្នុងនាមជាកូនចៅ។

### ៦.៣.២- អាទិភាពទី២ : សុខភាពនិងសុខុមាលភាព

**និសដៅ ២.១ : ជំរុញលើកទឹកចិត្តឲ្យដំណើរឈានចូលវ័យចាស់ប្រកបដោយសុខភាពល្អនិងពង្រីកការថែទាំសុខភាពតាមលក្ខណៈការការពារជាមុន**

**យុទ្ធសាស្ត្រ** :

(i) រៀបចំឲ្យមានដំណើរជីវិតមួយប្រកបដោយសុខភាពល្អពេលវ័យចាស់និងមានការការពារទប់ស្កាត់ជំងឺ តាមរយៈការដាក់ឲ្យដំណើរការនូវការផ្តល់ព័ត៌មានដែលមានលក្ខណៈជាការអប់រំសម្រាប់មនុស្សចាស់ អ្នកមើលថែទាំ និងអ្នកផ្តល់សេវាសុខភាព រួមទាំងព័ត៌មានអំពីសារៈសំខាន់នៃសកម្មភាពផ្នែករាងកាយ អនាម័យល្អ និងរបបអាហារមានតុល្យភាព។

(ii) រៀបចំឲ្យមានសេវាប្រឹក្សាយោបល់សម្រាប់មនុស្សចាស់នៅមណ្ឌលសុខភាព។

(iii) បង្កលក្ខណៈឲ្យមនុស្សចាស់ អាចទទួលបានសេវាត្រួតពិនិត្យសុខភាពជាប្រចាំសម្រាប់ការពិនិត្យតាមដាននិងព្យាបាល និងអាចមានលទ្ធភាពទទួលបានថ្នាំបង្ការសម្រាប់ការការពារទប់ស្កាត់ជំងឺនិងការលើកកម្ពស់សុខភាពនៅពេលវ័យចាស់។

(iv) បង្កើតប្រព័ន្ធតាមដាននៅទូទាំងប្រទេស ដើម្បីពិនិត្យតាមដានមើល មនុស្សចាស់ជរាដែលនៅឯកោ និងមនុស្សចាស់ដែលងាយរងគ្រោះ។

**និសដៅ ២.២៖ បង្កើតប្រព័ន្ធសុខាភិបាលមួយដែលមានលក្ខណៈឆ្លើយតប ដែលអាចទទួលបាននិងធានាបាននូវសេវាព្យាបាលប្រកបដោយគុណភាព។**

**យុទ្ធសាស្ត្រ** :

(i) ផ្តល់ឲ្យមូលដ្ឋានសុខាភិបាលដែលផ្តល់សេវាព្យាបាលសុខភាពនូវបុគ្គលិកគ្រប់គ្រាន់ប្រកបដោយវិជ្ជាជីវៈ មានក្រមសីលធម៌ និងនៅប្រចាំការ ដើម្បីផ្តល់សេវាសុខភាពមូលដ្ឋានដល់មនុស្សចាស់ រួមទាំងការបញ្ជូនទៅឲ្យសេវាសុខភាពឯកទេសនិងការតាមដានបន្តផងដែរ។

(ii) ត្រៀមលក្ខណៈឲ្យមន្ទីរពេទ្យថ្នាក់ជាតិ អាចផ្តល់នូវសេវាសុខភាពពេញលេញ សម្រាប់មនុស្សចាស់ ក្នុងនោះរួមទាំងការត្រួតពិនិត្យ ការធ្វើរោគវិនិច្ឆ័យ និងការព្យាបាលផ្សេងៗ។

(iii) ដាក់ឲ្យមានអ្នកវិជ្ជាជីវៈសុខាភិបាល ដែលបានទទួលការបណ្តុះបណ្តាលអំពីសុខភាពមនុស្សចាស់នៅគ្រប់មណ្ឌលសុខភាពទាំងអស់។

(iv) កសាងសមត្ថភាពឲ្យបានគ្រប់គ្រាន់នៅតាមមន្ទីរពេទ្យនានា ក្នុងការថែទាំអ្នកជំងឺសម្រាកក្នុងមន្ទីរពេទ្យ ដើម្បីអាចឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់មនុស្សចាស់ ក្នុងការចូលសម្រាកព្យាបាលនៅមន្ទីរពេទ្យ។

(v) ពង្រីកវិសាលភាពគ្របដណ្តប់សេវាថែទាំសុខភាពប្រកបដោយគុណភាពដោយឥតគិតថ្លៃ និងផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុដល់មនុស្សចាស់ក្រីក្រ ដែលមិនមានលទ្ធភាពបង់ថ្លៃសេវាវេជ្ជសាស្ត្រមួយចំនួន។

(vi) ធានាថាមន្ទីរពេទ្យរដ្ឋទាំងអស់ មានសេវាវេជ្ជសាស្ត្រសម្រាប់មនុស្សចាស់ប្រកបដោយគុណភាព។

(vii) ធានាឲ្យមានឱសថសំខាន់ៗដែលត្រូវការជាទូទៅសម្រាប់ការព្យាបាលជំងឺដែលប៉ះពាល់ដល់មនុស្សចាស់។

និសដៅ ២.៣ : **ឆ្លើយតបនឹងតម្រូវការរបស់មនុស្សចាស់សម្រាប់ការថែទាំរយៈពេលវែង**

**យុទ្ធសាស្ត្រ** :

(i) ពិចារណារៀបចំឲ្យមានសេវាថែទាំនិងការព្យាបាលតាមផ្ទះចំពោះមនុស្សចាស់ដែលត្រូវការការថែទាំរយៈពេលវែង ដោយសារពិការភាព ជំងឺវង្វេងវង្វាន់ ឬ ជំងឺដល់អាយុជីវិត។

(ii) ផ្តល់ការបណ្តុះបណ្តាលនិងការលើកទឹកចិត្តដល់សមាជិកគ្រួសារ ដែលត្រូវការមើលថែអ្នកជំងឺវ័យចាស់ទាំងឡាយណាដែលត្រូវការការថែទាំរយៈពេលវែង។

(iii) ពិចារណារៀបចំបង្កើតមជ្ឈមណ្ឌលថែទាំសម្រាប់មនុស្សចាស់ទាំងឡាយណា ដែលត្រូវការការថែទាំរយៈពេលយូរ។

(iv) កែលម្អលទ្ធភាពទទួលបានការប្រើប្រាស់សេវា តាមមូលដ្ឋានសុខាភិបាល សម្រាប់ការពិនិត្យនិងការព្យាបាលជំងឺរ៉ាំរ៉ៃនានាដូចជា ជំងឺលើសសម្ពាធឈាម ជំងឺទឹកនោមផ្អែម ជំងឺសរសៃឈាមក្នុងខួរក្បាល ជំងឺមហារីក ជំងឺវង្វេងវង្វាន់ និងជំងឺបាត់បង់ការចងចាំ។

និសដៅ ២.៤ : **បន្តគិតគូរដោះស្រាយឲ្យមានបុគ្គលិកសុខាភិបាលគ្រប់គ្រាន់ និងដែលមានការបណ្តុះបណ្តាល**

**យុទ្ធសាស្ត្រ** :

(i) វាយតម្លៃលើតម្រូវការអ្នកប្រកបវិជ្ជាជីវៈផ្នែកការថែទាំសុខភាពនិងសង្គមកិច្ច និងរៀបចំកម្មវិធីអប់រំឬបណ្តុះបណ្តាលបន្ថែមសម្រាប់បុគ្គលិកទាំងនេះ ទៅតាមសេចក្តីត្រូវការនាពេលបច្ចុប្បន្ន។

(ii) លើកកម្ពស់ការអប់រំនិងការបណ្តុះបណ្តាលផ្នែកការថែទាំសុខភាព និងការថែទាំមនុស្សចាស់ សម្រាប់អ្នកប្រកបវិជ្ជាជីវៈផ្នែកការថែទាំសុខភាពនិងសង្គមកិច្ច អ្នកស្ម័គ្រចិត្ត និងអ្នកថែទាំ។

(iii) បណ្តុះឲ្យមាននៅក្នុងគំនិតរបស់អ្នកផ្តល់សេវាសុខភាព អំពីទិដ្ឋភាពវិជ្ជមានរបស់មនុស្សចាស់ ព្រមទាំងការយកចិត្តទុកដាក់និងការគោរពដែលមនុស្សចាស់សមតែទទួលបាន។

(iv) បង្កើនចំនួនអ្នកជំនាញដែលបានទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈផ្នែករោគមនុស្សចាស់។

(v) ដាក់ឲ្យមានមុខវិជ្ជាសិក្សាស្តីពីការថែទាំសុខភាពមនុស្សចាស់ នៅគ្រប់កម្មវិធីសិក្សាវិជ្ជាជីវៈសុខាភិបាល។

## ៦.៣.៣- អាទិភាពទី៣ : របៀបរបបការរស់នៅ

### និសដៅ ៣.១ : លើកទឹកចិត្តឲ្យមានដំណើរឈានចូលវ័យចាស់នៅនឹងកន្លែងដែលមនុស្សចាស់កំពុងរស់នៅ

### យុទ្ធសាស្ត្រ៖

(i) ផ្តល់ការបណ្តុះបណ្តាលមូលដ្ឋានដល់អ្នកថែទាំតាមផ្ទះ ក្នុងការថែទាំមនុស្សចាស់ ចំណេះដឹង និងព័ត៌មានអំពីសេវាមានសារប្រយោជន៍និងការចាត់ចែងក្នុងស្ថានភាពមានអាសន្ន។

(ii) ផ្តល់ការប្រឹក្សាយោបល់ដល់អ្នកថែទាំតាមផ្ទះ ដើម្បីផ្តល់នូវភាពធូរស្រាលដល់ពួកគាត់ពីភាពតានតឹងផ្លូវចិត្ត ដែលជាលទ្ធផលកើតចេញពីការផ្តល់ការថែទាំ។

(iii) ធានាឲ្យមានការបង្កើននិងការកែលម្អការចុះទៅសួរសុខទុក្ខតាមផ្ទះដោយអ្នកបម្រើការសុខភាពនិងមន្ត្រីសុខុមាលភាពសង្គម។

(iv) លើកទឹកចិត្តឲ្យសហគ្រាសផ្តល់ការសម្រួលដល់និយោជិតទាំងឡាយណាដែលមានមនុស្សចាស់ជាសមាជិកគ្រួសារណាម្នាក់នៅផ្ទះដែលត្រូវការការថែទាំ។

(v) លើកទឹកចិត្តអ្នកស្ម័គ្រចិត្តតាមសហគមន៍ ឲ្យជួយជ្រោមជ្រែងដល់មនុស្សចាស់ជរា នៅក្នុងសកម្មភាពប្រចាំថ្ងៃរបស់ពួកគាត់។

(vi) ធ្វើឲ្យមនុស្សចាស់មានលទ្ធភាពកាន់តែងាយស្រួលក្នុងការទាក់ទងជាមួយនឹងសមាជិកគ្រួសារ និងសេវាគ្រាអាសន្ន ក្នុងករណីដែលត្រូវការ។

(vii) ដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្ត ដើម្បីការពារមនុស្សចាស់ ពីការរំលោភបំពានគ្រប់ទម្រង់លើមនុស្សចាស់(ការរំលោភបំពានលើផ្លូវកាយ ពាក្យសម្តី ហិរញ្ញវត្ថុ និងផ្លូវចិត្ត)។

និសដៅ ៣.២ : **ផ្ដល់ការរៀបចំការរស់នៅសមស្របសម្រាប់មនុស្សចាស់ដែលពុំមានការគាំទ្រពីគ្រួសារ**

**យុទ្ធសាស្ត្រ** :

(i) ពិចារណារៀបចំបង្កើតមជ្ឈមណ្ឌលមនុស្សចាស់នៅតាមសហគមន៍សម្រាប់ផ្ដល់ជម្រកដល់មនុស្សចាស់ដែលគ្មានទីពឹង។

(ii) ជួយជ្រោមជ្រែងនិងផ្ដល់ប្រឹក្សាដល់វត្តអារាម ឲ្យពង្រីកនិងកែលម្អមូលដ្ឋានវត្តអារាមសម្រាប់ជាជម្រកដល់មនុស្សចាស់ងាយរងគ្រោះ។

(iii) ពិចារណារៀបចំឲ្យមានបទដ្ឋានដែលមានលក្ខណៈសមស្រប សម្រាប់មជ្ឈមណ្ឌលមនុស្សចាស់នៅតាមសហគមន៍។

(iv) បង្កើតឲ្យមានកញ្ចប់សង្គ្រោះបឋមសម្រាប់មនុស្សចាស់នៅក្នុងមណ្ឌលសុខភាពនិងមន្ទីរពេទ្យបង្អែក។

### ៦.៣.៤- អាទិភាពទី៤ : បរិស្ថានអំណោយផល

និសដៅ ៤.១ : **បង្កលក្ខណៈឲ្យមនុស្សចាស់អាចរស់នៅដោយឯករាជ្យបាន ប្រសិនបើពួកគាត់អាចនិងមានបំណងរស់នៅបែបនេះ**

**យុទ្ធសាស្ត្រ៖**

(i) ផ្ដល់ព័ត៌មានដល់មនុស្សចាស់អំពីការបន្សាំដែលនឹងត្រូវធ្វើឡើង ដើម្បីបង្កលក្ខណៈឲ្យពួកគាត់អាចរស់នៅដោយមានសុវត្ថិភាព និងកាត់បន្ថយហានិភ័យនៃការជួបគ្រោះថ្នាក់នានាដូចជា ការដួល ការរអិល ជាដើម។

(ii) គិតគូរពិចារណាជំរុញឲ្យមានសេវាមូលដ្ឋានសំខាន់ៗសម្រាប់មនុស្សចាស់នៅតាមតំបន់ដែលមានមជ្ឈមណ្ឌលមនុស្សចាស់នៅតាមសហគមន៍។

(iii) ផ្ដល់ដល់មនុស្សចាស់នូវលទ្ធភាពក្នុងការទាក់ទងរកជំនួយដែលអាចទុកចិត្តបានឬលទ្ធភាពក្នុងការទាក់ទាញចំណាប់អារម្មណ៍របស់មនុស្សដទៃទៀត ក្នុងករណីពួកគាត់ត្រូវការ។

និសដៅ ៤.២ : **ការជួយសម្រួលដល់ការផ្លាស់ទីរបស់មនុស្សចាស់**

**យុទ្ធសាស្ត្រ** :

(i) កែលម្អមធ្យោបាយធ្វើដំណើរសាធារណៈ ដោយបញ្ចូលការគិតគូរដោះស្រាយ សេចក្ដីត្រូវការរបស់មនុស្សចាស់។

(ii) ផ្តល់ការយកចិត្តទុកដាក់លើទិដ្ឋភាពមនុស្សចាស់នៅតាមសំណង់ហេដ្ឋារចនាសម្ព័ន្ធសាធារណៈទាំងអស់ រួមមាន ផ្លូវថ្នល់ ផ្លូវថ្មើរជើង និង បង្គន់អនាម័យ ដើម្បីអាចផ្តល់លទ្ធភាពចេញចូលដោយងាយស្រួលនិងច្រកឆ្លងកាត់ប្រកបដោយសុវត្ថិភាព សម្រាប់មនុស្សចាស់។

(iii) ផ្តល់គន្លងផ្លូវពិសេសនិងមូលដ្ឋានសម្ភារៈនិងគ្រឿងបរិក្ខារដែលមិនបង្កឧបសគ្គដល់មនុស្សចាស់នៅកន្លែងសាធារណៈដូចជា ទីផ្សារ ធនាគារ ជាដើម។

(iv) ដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្ត ដែលតម្រូវឲ្យអគារសាធារណៈទាំងអស់អាចចេញចូលបានដោយងាយស្រួលនិងដោយសុវត្ថិភាពសម្រាប់មនុស្សចាស់និងជនពិការ។

(v) លើកកម្ពស់ការយល់ដឹងអំពីមនុស្សចាស់តាមរយៈប្រព័ន្ធផ្សព្វផ្សាយសាធារណៈនានា។

### ៦.៣.៥- អាទិភាពទី៥ : សមាគមមនុស្សចាស់និងវ័យចាស់សកម្ម

និសដោ ៥.១ : **គាំទ្រដល់ការបង្កើតសមាគមមនុស្សចាស់នៅទូទាំងប្រទេស**

**យុទ្ធសាស្ត្រ** :

(i) ពង្រឹងសមាគមមនុស្សចាស់ដែលមានស្រាប់និងពង្រីកបណ្តាញឲ្យទៅដល់កម្រិតថ្នាក់ក្រោមជាតិ។

(ii) ផ្តល់មូលនិធិនិងផ្តល់ការសម្រួលដល់ការបង្កើតសមាគមមនុស្សចាស់នៅគ្រប់ឃុំសង្កាត់។

(iii) ផ្តល់ការបណ្តុះបណ្តាលដល់សមាជិកសមាគមមនុស្សចាស់ស្តីពីការបង្កើតនិងដំណើរការសមាគមមនុស្សចាស់។

(iv) លើកទឹកចិត្តឲ្យមានទំនាក់ទំនងរវាងអង្គការមិនមែនរដ្ឋាភិបាលនិងរាជរដ្ឋាភិបាលដើម្បីបង្កើតបណ្តាញប្រជាជនវ័យចាស់ នៅក្នុងគ្រប់វិស័យ។

(v) លើកទឹកចិត្តដល់អង្គការមិនមែនរដ្ឋាភិបាលដែលពាក់ព័ន្ធ ក្នុងការផ្តល់ប្រឹក្សាដល់គណៈកម្មាធិការគ្រប់គ្រងសមាគមមនុស្សចាស់និងក្នុងការចាត់ចែងសកម្មភាពរបស់ខ្លួន។

(vi) បង្កើតយន្តការមួយដែលតាមរយៈនេះ សមាគមមនុស្សចាស់អាចមានការប្រាស្រ័យទាក់ទងនិងផ្លាស់ប្តូរបទពិសោធជាមួយគ្នាជាប្រចាំ។

និសដោ ៥.២ : **ពង្រឹងតួនាទីរបស់សមាគមមនុស្សចាស់**

**យុទ្ធសាស្ត្រ** :

(i) គាំទ្រដល់សមាគមមនុស្សចាស់ក្នុងការបង្កើតឡើងនូវសន្តិសុខនៃមូលដ្ឋានទ្រទ្រង់ជីវភាពរស់នៅ តាមរយៈការបណ្តុះបណ្តាលពួកគាត់ពីសកម្មភាពបង្កើតប្រាក់ចំណូល។

(ii) ផ្តល់ការបណ្តុះបណ្តាលដល់សមាគមមនុស្សចាស់ពីការថែទាំសុខភាពមូលដ្ឋាននិងបង្កលក្ខណៈឲ្យពួកគាត់អាចបង្កើតនិងដំណើរការនូវគម្រោងការថែទាំតាមផ្ទះ ហើយតាមរយៈនេះ ពួកគាត់អាចចូលរួមវិភាគទានក្នុងការលើកកម្ពស់ការថែទាំសុខភាព។

(iii) លើកកម្ពស់ស្មារតី "មនុស្សចាស់ជួយមនុស្សចាស់" ជាមូលដ្ឋានគ្រឹះរបស់សមាគមមនុស្សចាស់ ដើម្បីលើកទឹកចិត្តដល់មនុស្សចាស់ដែលសកម្មនិងមានសុខភាពល្អជាងឲ្យជួយមនុស្សចាស់រួមជំនាន់ដែលមានស្ថានភាពមិនសូវល្អដូចពួកគាត់។

## ៦.៣.៦- អាទិភាពទី៦ : ទំនាក់ទំនងអន្តរជំនាន់

### និសដៅ ៦.១ : **ពង្រីកឱកាសសម្រាប់ការចូលរួមរបស់មនុស្សចាស់នៅក្នុងជីវភាពសាធារណៈ**

**យុទ្ធសាស្ត្រ** :

(i) បង្កើតក្រុមមនុស្សចាស់នៅក្នុងអាជ្ញាធរមូលដ្ឋាននីមួយៗដើម្បីធានាបានថា មនុស្សចាស់មានសំឡេងនៅក្នុងដំណើរការការសម្រេចចិត្ត ហើយសេចក្តីត្រូវការរបស់ពួកគាត់ត្រូវបានលើកយកមកពិចារណា។

(ii) ធានាថា មនុស្សចាស់ត្រូវបានធ្វើឲ្យមានការពាក់ព័ន្ធ នៅក្នុងការរៀបចំនិងការអនុវត្តគោលនយោបាយទាំងឡាយដែលជះឥទ្ធិពលដល់ពួកគាត់ ទាំងនៅថ្នាក់ជាតិ ទាំងនៅថ្នាក់មូលដ្ឋាន។

(iii) បង្កើតមូលដ្ឋានទិន្នន័យស្តីពីជំនាញរបស់អ្នកឯកទេសដែលបានចូលនិវត្តន៍ ធ្វើជាឧបករណ៍ប្រឹក្សាសម្រាប់សហគមន៍ និងរដ្ឋបាលគ្រប់កម្រិត។

(iv) ផ្តល់ការសម្រួលដល់ការចូលរួមរបស់មនុស្សចាស់ នៅក្នុងព្រឹត្តិការណ៍សាធារណៈនានា ដូចជា ការចូលរួមនៅក្នុង ការបោះឆ្នោត សកម្មភាពផ្នែកវប្បធម៌និងសាសនា ជាដើម។

### និសដៅ ៦.២ : **ជំរុញឲ្យមានឥរិយាបថវិជ្ជមានចំពោះដំណើរឈានចូលដល់វ័យចាស់និងមនុស្សចាស់**

**យុទ្ធសាស្ត្រ** :

(i) លើកកម្ពស់ការយល់ដឹងថា មនុស្សចាស់មិនមែនជាបន្ទុកលើសហគមន៍ទេ ប៉ុន្តែ ពួកគាត់នាំអត្ថប្រយោជន៍មកដល់សង្គមវិញ។

(ii) កែប្រែទស្សនៈខុសឆ្គងដែលថាមនុស្សចាស់ពុំមានគោលដៅប្រកបដោយអត្ថន័យសម្រាប់ពេលវេលាដែលនៅសេសសល់ក្នុងជីវិតរបស់ខ្លួនឡើយ ក្រៅពីរង់ចាំសេចក្តីស្លាប់។

(iii) លើកទឹកចិត្តឲ្យមានការបង្កើតកម្មវិធីទូរទស្សន៍ វិទ្យុ និងប្រព័ន្ធផ្សព្វផ្សាយទាំងឡាយ ដែលផ្តោតការយកចិត្តទុកដាក់លើការចូលរួមវិភាគទានរបស់មនុស្សចាស់និងតួនាទីដែលមនុស្សចាស់បានធ្វើនៅក្នុងសហគមន៍។

និសដោ ៦.៣ : **ពង្រឹងទំនាក់ទំនងអន្តរជំនាន់**

**យុទ្ធសាស្ត្រ** :

(i) លើកទឹកចិត្តមនុស្សវ័យក្មេងឲ្យស្ម័គ្រចិត្តជួយដល់មនុស្សចាស់។

(ii) ជំរុញឲ្យមានការរៀបចំសកម្មភាពនានា ដែលមនុស្សគ្រប់វ័យទាំងអស់អាចចូលរួមបាន។

(iii) រៀបចំធ្វើបទបង្ហាញ អមដោយការពិភាក្សាអំពីការបំពេញបន្ថែមគ្នាទៅវិញទៅមករបស់មនុស្សជំនាន់ខុសគ្នា សម្រាប់មនុស្សពេញវ័យនៅក្មេងនិងមនុស្សចាស់។

(iv) រៀបចំបណ្តុះបណ្តាលនិងគាំទ្រដល់មនុស្សចាស់ លើបញ្ហាការប្រើប្រាស់មធ្យោបាយប្រាស្រ័យទាក់ទងគ្នាដូចជាទូរសព្ទដៃ ប្រព័ន្ធផ្សព្វផ្សាយសង្គម ជាដើម ដើម្បីឲ្យពួកគាត់រក្សានូវទំនាក់ទំនងជាមួយនឹងកូនចៅ ជាមួយមនុស្សពេញវ័យនិងសាច់ញាតិក្មេងៗដទៃទៀតរបស់ពួកគាត់។

(v) ដាក់បញ្ចូលវគ្គសិក្សាពីសារៈសំខាន់នៃការគោរពនិងការធ្វើទំនាក់ទំនងជាមួយនឹងមនុស្សចាស់ នៅក្នុងកម្មវិធីសិក្សា ស្ថាប័នបណ្តុះបណ្តាល និងសាលារៀននានា។

(vi) បង្ហាញជាសាធារណៈនូវសមិទ្ធផលរបស់មនុស្សចាស់ តាមរយៈប្រព័ន្ធផ្សព្វផ្សាយ។

(vii) ផ្តល់កិត្តិយសដល់ស្នាដៃមានលក្ខណៈជាគំរូដែលមនុស្សចាស់សម្រេចបានដូចជាការងារស្ម័គ្រចិត្តឬការងារច្នៃប្រឌិតដោយផ្តល់ពានរង្វាន់និង/ឬវិញ្ញាបនបត្រទទួលស្គាល់ស្នាដៃ។

### ៦.៣.៧- អាទិភាពទី៧ : ការរំលោភបំពាននិងអំពើហិង្សាលើមនុស្សចាស់

និសដោ ៧.១ : **កាត់បន្ថយនិងទប់ស្កាត់ករណីការរំលោភបំពានលើមនុស្សចាស់**

**យុទ្ធសាស្ត្រ** :

(i) ដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្ត ដើម្បីការពារមនុស្សចាស់ពីការរំលោភបំពាន។

(ii) បំពាក់បំប៉នចំណេះដឹងដល់មនុស្សចាស់ អំពីសណ្ឋាននៃការរំលោភបំពានលើមនុស្សចាស់និងសិទ្ធិរបស់ពួកគាត់ក្នុងការការពារខ្លួនពីការរំលោភបំពាននេះ។

(iii) លើកទឹកចិត្តមនុស្សចាស់ឲ្យរាយការណ៍ពីការរំលោភបំពានលើមនុស្សចាស់ឬពិភាក្សាលើករណីរំលោភបំពានលើមនុស្សចាស់ជាមួយនឹងសាច់ញាតិជិតស្និទ្ធ មិត្តភក្តិ ឬវេជ្ជបណ្ឌិតរបស់ពួកគាត់។

(iv) បញ្ជ្រាបការយល់ដឹងដល់សហគមន៍ពីសារៈសំខាន់នៃការរាយការណ៍ពីករណីជាក់ស្តែងដែលបានកើតមានឬសូម្បីតែករណីសង្ស័យពីការរំលោភបំពានលើមនុស្សចាស់ដែលពួកគាត់បានដឹង។

(v) ផ្តល់សិទ្ធិឲ្យបុគ្គលិកសុខាភិបាលអាចស្រាវជ្រាវស្វែងយល់ ហើយក្នុងករណីចាំបាច់អាចរាយការណ៍ជូនអាជ្ញាធរដែលពាក់ព័ន្ធពីករណីការរំលោភបំពានលើមនុស្សចាស់ដែលអ្នកជំងឺជាមនុស្សចាស់របស់ពួកគេបានឆ្លងកាត់។

និសដោ ៧.២ : **ការពារមនុស្សចាស់កុំឲ្យធ្លាក់ជាជនរងគ្រោះនៃអំពើហិង្សានិងបទឧក្រិដ្ឋ**

**យុទ្ធសាស្ត្រ** :

(i) ពង្រឹងសមត្ថភាពអង្គភាពនគរបាលជំនាញដើម្បីការពារមនុស្សចាស់និងទប់ស្កាត់អំពើហិង្សាលើមនុស្សចាស់។

(ii) ជំរុញឲ្យសហគមន៍មានការយល់ដឹងអំពីបញ្ហាសុវត្ថិភាពរបស់មនុស្សចាស់ដែលរស់នៅតែម្នាក់ឯង ក្នុងតំបន់របស់ពួកគាត់។

## ៦.៣.៨- អាទិភាពទី៨ : ស្ថានភាពមានអាសន្ន

និសដោ ៨.១ : **ធានាឲ្យមាននូវកិច្ចខិតខំប្រឹងប្រែងក្នុងការសង្គ្រោះឬការស្តារសម្បទា ដោយផ្តល់ការយកចិត្តទុកដាក់សមស្របចំពោះមនុស្សចាស់**

**យុទ្ធសាស្ត្រ** :

(i) ផ្តល់អាទិភាពដល់មនុស្សចាស់ កុមារ និងជនពិការ នៅក្នុងផែនការកាត់បន្ថយហានិភ័យ ក្នុងនោះមាន ការប្រកាសភាពអាសន្នពីគ្រោះមហន្តរាយ ការជួយសង្គ្រោះ ការផ្តល់ទីជម្រក ក៏ដូចជានៅក្នុងការផ្តួចផ្តើមគំនិតអំពីការស្តារសម្បទាក្រោយពេលគ្រោះមហន្តរាយ។

(ii) លើកទឹកចិត្តឲ្យមានការចូលរួមពីមនុស្សចាស់នៅក្នុងការរៀបចំផែនការកាត់បន្ថយគ្រោះមហន្តរាយ នៅគ្រប់កម្រិតទាំងអស់ ដើម្បីឲ្យបានគំនិតយោបល់ទៅលើបញ្ហានានាទាក់ទងនឹងបញ្ហាមនុស្សចាស់។

(iii) បណ្តុះបណ្តាលអ្នកបម្រើការងារជួយសង្គ្រោះឬស្តារសម្បទាឲ្យអាចកំណត់ទីតាំងដែលមនុស្សចាស់កំពុងស្ថិតនៅក្នុងកំលុងពេលមានគ្រោះអាសន្ន និងឲ្យអាចវាយតម្លៃអំពីភាពងាយរងគ្រោះរបស់មនុស្សចាស់ ទាក់ទងនឹងស្ថានភាពផ្នែករាងកាយនិងផ្លូវចិត្តរបស់ពួកគាត់។

(iv) បញ្ជ្រាបការយល់ដឹងដល់អ្នកបម្រើការងារជួយសង្គ្រោះឬស្តារសម្បទាអំពីបញ្ហានានាដែលជួបប្រទះដោយមនុស្សចាស់។

(v) ផ្តល់ការការពារបន្ថែមដល់ស្ត្រីវ័យចាស់ពីការកេងប្រវ័ញ្ចនិងការរំលោភបំពានផ្នែករាងកាយ ផ្លូវចិត្ត ផ្លូវភេទ និង ហិរញ្ញវត្ថុ នៅក្នុងស្ថានភាពមានអាសន្ន។

(vi) រៀបចំកម្មវិធីជួយសង្គ្រោះឬស្តារសម្បទាឲ្យមានលក្ខណៈអំណោយផលចំពោះមនុស្សចាស់។

(vii) ជានាថាមជ្ឈមណ្ឌលសម្រាប់ការជម្លៀសមានការរៀបចំពិសេសដែលសមស្របទៅនឹងសេចក្តីត្រូវការរបស់មនុស្សចាស់។

(viii) បង្កើនចំនួនអ្នកមានវិជ្ជាជីវៈផ្នែកមនុស្សចាស់ នៅក្នុងក្រុមវេជ្ជសាស្ត្រដែលបានបញ្ជូនចេញទៅកាន់ទីកន្លែងជួបគ្រោះមហន្តរាយ។

(ix) លើកកម្ពស់ការយល់ដឹងជាសាធារណៈដើម្បីពង្រីកការជួយជ្រោមជ្រែងទៅដល់មនុស្សចាស់ដែលជួបការលំបាកក្នុងកំលុងពេលមានអាសន្ន។

**និសដោ ៨.២ : បញ្ជ្រាបការយល់ដឹងដល់មនុស្សចាស់ពីវិធីដើម្បីរៀបចំខ្លួនឆ្លើយតបទៅនឹងករណីមានអាសន្ន**

**យុទ្ធសាស្ត្រ** :

(i) ផ្តល់ការណែនាំនិងការបណ្តុះបណ្តាលដល់មនុស្សវ័យចាស់អំពីរបៀបដោះស្រាយនៅពេលមានគ្រោះមហន្តរាយធម្មជាតិនិងករណីអាសន្នផ្សេងៗទៀត ដូចជាការផ្លាស់ទីកន្លែងរស់នៅរបស់ប្រជាជនជាដើម។

(ii) ផលិតនិងចែកចាយសៀវភៅណែនាំសម្រាប់មនុស្សចាស់ ដោយគូសបញ្ជាក់ពីការ ប្រុងប្រយ័ត្នជាមុននិងសកម្មភាពទាំងឡាយដែលត្រូវធ្វើ ក្នុងករណីមានអាសន្នតាមប្រភេទផ្សេងៗពីគ្នា។

(iii) ដាក់ឲ្យដំណើរការនូវប្រព័ន្ធមួយដែលមនុស្សចាស់អាចចុះបញ្ជីអាសយដ្ឋានរបស់ពួកគាត់និងព័ត៌មានលម្អិតដែលពាក់ព័ន្ធដទៃទៀត ដើម្បីជួយឲ្យក្រុមអ្នកសង្គ្រោះអាចកំណត់ទីតាំងរបស់ពួកគាត់បានទាន់ពេល នៅពេលមានអាសន្ន ជាពិសេស នៅតាម ទីតាំងដែលជួបគ្រោះមហន្តរាយញឹកញាប់។

(iv) ផ្តល់ការណែនាំដល់មនុស្សចាស់ពីរបៀបទាក់ទាញចំណាប់អារម្មណ៍របស់មនុស្សដទៃនៅពេលជួបនឹងគ្រោះថ្នាក់ខ្លាំងហួសប្រមាណ ក្នុងស្ថានភាពមានអាសន្ន។

## ៦.៣.៩- អាទិភាពទី៩ : ការត្រៀមខ្លួនរបស់ប្រជាជនវ័យក្មេង

និសដៅ ៩.១ : **ផ្តល់បរិស្ថានមួយដែលប្រជាជនវ័យក្មេងអាចត្រៀមខ្លួនបានកាន់តែប្រសើរ សម្រាប់ពេលឈានដល់វ័យចាស់**

**យុទ្ធសាស្ត្រ** :

(i) ពង្រីកវិសាលភាពគ្របដណ្តប់នៃយន្តការការពារផ្នែកហិរញ្ញវត្ថុសម្រាប់ការត្រៀមរៀបចំនៅពេលចូលដល់វ័យចាស់ តាមយៈការអនុវត្តផែនការប្រាក់សោធននិវត្តន៍ និងគម្រោងសន្សំប្រាក់ ដើម្បីធានាឲ្យមានប្រាក់ចំណូលសមរម្យ សម្រាប់ប្រជាជនដែលចូលរួមក្នុងរបបសោធនកាតព្វកិច្ច និងស្ម័គ្រចិត្ត និងការកាត់បន្ថយជាអតិបរមានូវការធ្លាក់ទៅក្នុងភាពក្រីក្រនៅពេលឈានដល់វ័យចាស់។

(ii) ផ្សព្វផ្សាយព័ត៌មានស្តីពីរបៀបរស់នៅដែលមានសុខភាពល្អដូចជា ទម្លាប់ទទួលទានអាហារធ្វើឲ្យមានសុខភាពល្អនិងការហាត់ប្រាណទៀងទាត់ ជាដើម ដើម្បីជួយឲ្យមនុស្សចាស់នាពេលអនាគត អាចរក្សាបាននូវបទដ្ឋានសុខភាពកាន់តែខ្ពស់ថែមទៀត។

(iii) ផ្តល់គម្រោងធានារ៉ាប់រងសុខភាពជូនដល់មនុស្សក្នុងវ័យធ្វើការងារ ដែលផ្តល់ការគ្របដណ្តប់សម្រាប់ពេលគាត់ឈានចូលដល់វ័យចាស់ផងដែរ។

(iv) បណ្តុះឲ្យមាននៅក្នុងផ្នត់គំនិតរបស់ប្រជាជនវ័យក្មេងនូវការឲ្យតម្លៃដល់មនុស្សវ័យចាស់ ដើម្បីលុបបំបាត់នូវការភ័យខ្លាចរបស់ពួកគាត់ចំពោះការក្លាយជាមនុស្សចាស់និងអារម្មណ៍អវិជ្ជមានទាំងឡាយដែលពួកគាត់អាចមានចំពោះជីវិតវ័យចាស់។

(v) ផ្តល់ឱកាសឲ្យមនុស្សវ័យក្មេងធ្វើការងារស្ម័គ្រចិត្តសម្រាប់មនុស្សចាស់ នៅតាមផ្ទះនិងអង្គការសម្រាប់មនុស្សចាស់ ដើម្បីឲ្យពួកគាត់មានព័ត៌មានផ្ទាល់ពីរបៀបដោះស្រាយបញ្ហាទាំងឡាយដែលអាចនឹងកើតមានឡើងក្នុងវ័យចាស់។

(vi) បង្កើនការយល់ដឹងជាសាធារណៈពីសារៈសំខាន់នៃដំណើរឈានចូលវ័យចាស់ប្រកប ដោយភាពថ្លៃថ្នូរ តាមរយៈការអប់រំក្នុងប្រព័ន្ធនិងក្រៅប្រព័ន្ធ ដែលត្រូវធ្វើឡើងជាប្រចាំ។

និសដៅ ៩.២ : **ជំរុញលើកទឹកចិត្តដល់មនុស្សវ័យក្មេងឲ្យត្រៀមខ្លួន សម្រាប់ការឈានចូលវ័យចាស់ប្រកបដោយសុខភាពល្អនិងសកម្ម**

**យុទ្ធសាស្ត្រ** :

(i) ដាក់បញ្ចូលមុខវិជ្ជាស្តីពីរបៀបរៀបចំការរស់នៅប្រកបដោយសុខភាពល្អនិងអាកប្បកិរិយា និងឥរិយាបថចេះស្វែងរកសុខភាពល្អ នៅក្នុងកម្មវិធីសិក្សារបស់សាលា។

(ii) បង្ហាញពីការគោរពនិងការថែទាំឪពុកម្តាយនិងសាច់ញាតិចាស់ជរា ដើម្បីបង្ហាញជាគំរូល្អដល់កូនៗរបស់ខ្លួនពីសារៈសំខាន់នៃករណីយកិច្ចទាំងអស់នេះ។

(iii) លើកទឹកចិត្តឲ្យមានការពិនិត្យសុខភាពជាប្រចាំ។

(iv) បញ្ជ្រាបការយល់ដឹងពីផលប៉ះពាល់នៃការផ្លាស់ប្តូរដែលមិនអាចជៀសបាន ដែលកើតចេញមកពីការចូលនិវត្តន៍និងដំណើរឈានចូលវ័យចាស់។

## ៧- ការរៀបចំស្ថាប័នដើម្បីអនុវត្តគោលនយោបាយ

**៦៧-** ការបង្កើតឡើងនិងការដាក់ឲ្យដំណើរការនូវយន្តការស្ថាប័នមួយសមស្រប សម្រាប់ការអនុវត្តគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ប្រកបដោយប្រសិទ្ធភាព គឺជាការងារចាំបាច់សំដៅប្រែក្លាយទិសដៅជាយុទ្ធសាស្ត្រទាំងនេះឲ្យទៅជាសកម្មភាពជាក់ស្តែង រួមជាមួយនឹងលទ្ធផលដែលត្រូវបង្កើតឡើងតាមការរំពឹងទុក។ ដើម្បីសម្រេចបានគោលបំណងដូចបានលើកឡើងខាងលើ គោលនយោបាយនេះត្រូវអនុវត្តរួមគ្នា ដោយក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ ទាំងនៅថ្នាក់ជាតិ ទាំងនៅថ្នាក់ក្រោមជាតិ រួមជាមួយនឹងការរួមចំណែកយ៉ាងទូលំទូលាយពីដៃគូអភិវឌ្ឍនានា អង្គការសង្គមស៊ីវិល និងវិស័យឯកជន នៅក្នុងភារកិច្ចដ៏សំខាន់នេះ។ ការចូលរួមដោយផ្ទាល់ពីមនុស្សចាស់ តាមរយៈសមាគមមនុស្សចាស់ គឺជាកត្តាគន្លឹះសម្រាប់ការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់។ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា មានតួនាទីស្នូលក្នុងការសម្របសម្រួលការអនុវត្តគោលនយោបាយ ជាមួយនឹងក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ តាមរយៈយន្តការរបស់ **គណៈកម្មាធិការជាតិកម្ពុជាដើម្បីមនុស្សចាស់**។

## ៧.១- គណៈកម្មាធិការជាតិកម្ពុជាដើម្បីមនុស្សចាស់

**៦៨-** ដោយផ្អែកទៅលើចំណងទាក់ទងទៅវិញទៅមកនៃបញ្ហាទាំងឡាយដែលពាក់ព័ន្ធនឹងមនុស្សវ័យចាស់ ការអនុវត្តគោលនយោបាយនេះត្រូវស្ថិតក្រោមការគ្រប់គ្រងរបស់ **គណៈកម្មាធិការជាតិកម្ពុជាដើម្បីមនុស្សចាស់** ដែលជាយន្តការអន្តរស្ថាប័នកម្រិតខ្ពស់របស់រាជរដ្ឋាភិបាល ដែលត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ១៥៨ អនក្រ.បក ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០១១។ គណៈកម្មាធិការនេះមានសមាជិកមកពីក្រសួង ស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាលនិងស្ថិតក្រោមការដឹកនាំរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ជាប្រធានកិត្តិយស ហើយ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ជាប្រធាន។ គណៈកម្មាធិការជាតិនេះស្ថិតនៅក្នុងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ហើយមានលេខាធិការដ្ឋានមួយជាសេនាធិការដែលដើរតួនាទីស្នូលក្នុងការសម្របសម្រួលការអនុវត្ត ការតាមដានត្រួតពិនិត្យ និងការវាយតម្លៃអំពីវឌ្ឍនភាពនៃគោលនយោបាយនេះ។ **គណៈកម្មាធិការជាតិកម្ពុជាដើម្បីមនុស្សចាស់** មានតំណាងពីក្រសួង ស្ថាប័ន ចំនួន១៥ រួមមាន (១)- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (២)- ក្រសួងកិច្ចការនារី (៣)- ក្រសួងមហាផ្ទៃ (៤)- ទីស្តីការគណៈរដ្ឋមន្ត្រី (៥)- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (៦)- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ (៧)- ក្រសួងសុខាភិបាល (៨)- ក្រសួងធម្មការនិងសាសនា (៩)- ក្រសួងអភិវឌ្ឍន៍ជនបទ (១០)- ក្រសួងអប់រំ យុវជន និងកីឡា (១១)- ក្រសួងផែនការ (១២) ក្រសួងព័ត៌មាន (១៣)- ក្រសួងមុខងារសាធារណៈ (១៤)- កាកបាទក្រហមកម្ពុជា (១៥)- គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិនិងអន្តរជាតិ។

**៦៩-** ក្រសួង ស្ថាប័នដទៃទៀតដែលមិនមែនជាសមាជិកនៃគណៈកម្មាធិការនេះ ក៏ត្រូវមានតួនាទីសំខាន់ក្នុងការរួមចំណែកអនុវត្តគោលនយោបាយនេះផងដែរ។

## ៧.២- តួនាទីនិងភារកិច្ចទទួលខុសត្រូវរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងភ្នាក់ងារដទៃទៀត

**៧០-** តួនាទីនិងភារកិច្ចរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធនិងភ្នាក់ងារពាក់ព័ន្ធដទៃទៀតត្រូវបានកំណត់ដូចខាងក្រោម។

### ៧.២.១- ក្រសួងកិច្ចការនារី

- សហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្នុងការតាមដានត្រួតពិនិត្យនិងវាយតម្លៃពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់។
- កំណត់ច្បាប់ប្រឆាំងការរើសអើងនិងការតស៊ូមតិ ដើម្បីបំបាត់ការរើសអើង។
- ធានាថាមន្ត្រីអភិវឌ្ឍសហគមន៍មានសមត្ថភាពជំនាញដែលពាក់ព័ន្ធ។

### ៧.២.២- ក្រសួងមហាផ្ទៃ

- សហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្នុងការតាមដានត្រួតពិនិត្យនិងវាយតម្លៃពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់។
- បង្កើនប្រសិទ្ធភាពលើការគ្រប់គ្រងអត្តសញ្ញាណប្រជាពលរដ្ឋនិងការស្នាក់នៅ។

### ៧.២.៣- ទីស្តីការគណៈរដ្ឋមន្ត្រី

- គាំទ្រវាល់សកម្មភាពអាទិភាពពាក់ព័ន្ធនឹងមនុស្សចាស់ ដែលស្នើឡើងដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងគណៈកម្មាធិការជាតិកម្ពុជាដើម្បីមនុស្សចាស់។

### ៧.២.៤- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- សហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្នុងការតាមដានត្រួតពិនិត្យនិងវាយតម្លៃពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់។
- កៀរគរធនធានក្នុងស្រុកនិងក្រៅស្រុកដើម្បីធ្វើពិពិធកម្មសេដ្ឋកិច្ច ក្នុងគោលបំណងធានាឲ្យបាននូវជីវភាពរស់នៅល្អប្រសើរសម្រាប់មនុស្សចាស់។
- សម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីជំរុញការអនុវត្តក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម។

### ៧.២.៥- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

- សហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្នុងការតាមដានត្រួតពិនិត្យនិងវាយតម្លៃពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់។
- លើកកម្ពស់សុខុមាលភាពមនុស្សចាស់និងក្រុមអ្នកជួបការលំបាក និងធានាប្រាក់កម្រៃអប្បបរមា។
- ជំរុញការអនុវត្តរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតក្រោមបទប្បញ្ញត្តិច្បាប់ស្តីពីការងារ។

### ៧.២.៦- ក្រសួងសុខាភិបាល

- សហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្នុងការតាមដានត្រួតពិនិត្យនិងវាយតម្លៃពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់។
- ផ្តួចផ្តើមការថែទាំសុខភាពមនុស្សចាស់ តាមរយៈការបណ្តុះបណ្តាលបុគ្គលិកអំពីការថែទាំមនុស្សចាស់។
- លើកកម្ពស់ការយល់ដឹងរបស់សហគមន៍ស្តីពីសិទ្ធិទទួលសេវានិងការបង្កើតតម្រូវការសេវា។
- ពិចារណាជាមួយក្រសួងពាក់ព័ន្ធនិងក្រសួងផែនការពីលទ្ធភាពបង្កើតសេវាធានារ៉ាប់រងសុខភាពសម្រាប់ជនក្រីក្រ និងសម្រាប់មនុស្សចាស់។

### ៧.២.៧- ក្រសួងធម្មការនិងសាសនា

- សហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្នុងការតាមដានត្រួតពិនិត្យនិងវាយតម្លៃពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់។
- លើកទឹកចិត្តឲ្យសាសនាទាំងអស់ ចូលរួមអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម ជំរុញវត្តអារាម និងវិហារសាសនានានាឲ្យក្លាយជាមជ្ឈមណ្ឌលអប់រំខាងផ្នែកស្មារតី សីលធម៌ ចរិយាធម៌ សាសនា វប្បធម៌ និងជាកន្លែងសម្រាប់ជួយដល់កុមារកំព្រា យុវជន និងមនុស្សចាស់ជរា។

### ៧.២.៨- ក្រសួងអភិវឌ្ឍន៍ជនបទ

- សហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្នុងការតាមដានត្រួតពិនិត្យនិងវាយតម្លៃពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់។
- សម្រេចឲ្យបាន១០០%នូវការផ្តល់សេវាទឹកស្អាត និងអនាម័យជនបទ និងកែលម្អផ្លូវជនបទឲ្យបានប្រសើរឡើងនៅឆ្នាំ២០២៥ឬយ៉ាងយូរឆ្នាំ២០៣០។

- រៀបចំកម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ សម្រាប់ជនងាយរងគ្រោះនិងយុវជនដែលបានបញ្ចប់ការសិក្សាឲ្យមានជំនាញវិជ្ជាជីវៈច្បាស់លាស់ ដើម្បីកាត់បន្ថយទេសន្តរប្រវេសន៍របស់ប្រជាពលរដ្ឋជនបទ។

### ៧.២.៩- ក្រសួងអប់រំ យុវជន និងកីឡា

- សហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្នុងការតាមដានត្រួតពិនិត្យនិងវាយតម្លៃពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់។
- រួមបញ្ចូលនូវការអប់រំបំណិនជីវិតនិងការអប់រំបរិស្ថាន ឲ្យទៅជាផ្នែកមួយនៃកម្មវិធីសិក្សា ឬកម្មវិធីសិក្សាបន្ថែម នៅកម្រិតមធ្យមសិក្សាឬកម្រិតឧត្តមសិក្សា ដើម្បីកសាងចំណេះដឹងរបស់ពួកគេ។

### ៧.២.១០- ក្រសួងផែនការ

- សហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្នុងការតាមដានត្រួតពិនិត្យនិងវាយតម្លៃពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់។
- ចូលរួមក្នុងការផ្សព្វផ្សាយនិងលើកកម្ពស់ការយល់ដឹងពីគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ និងបញ្ហាទាំងឡាយដែលពាក់ព័ន្ធនឹងមនុស្សចាស់។

### ៧.២.១១- ក្រសួងព័ត៌មាន

- សហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្នុងការតាមដានត្រួតពិនិត្យនិងវាយតម្លៃពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់។
- លើកកម្ពស់ការយល់ដឹងពីបញ្ហាប្រជាជន គោលនយោបាយ និងកម្មវិធីទាក់ទងនឹងការអភិវឌ្ឍ តាមរយៈ បណ្តាញទំនាក់ទំនងនានា។
- ប្រើប្រាស់វិទ្យុនិងទូរទស្សន៍ ដែលជាប្រព័ន្ធផ្សព្វផ្សាយពេញនិយម ដើម្បីផ្សព្វផ្សាយសារដែលពាក់ព័ន្ធនឹងសង្គមប្រជាសាស្ត្រ។

### ៧.២.១២- ក្រសួងមុខងារសាធារណៈ

- សហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្នុងការតាមដានត្រួតពិនិត្យនិងវាយតម្លៃពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់។
- ផ្សព្វផ្សាយព័ត៌មានអំពីទំនាក់ទំនងរវាងកំណើនប្រជាជនចាប់រហ័ស និងការងារក្នុងវិស័យមុខងារសាធារណៈដល់មន្ត្រីសាធារណៈក្នុងក្រសួង និងពង្រឹងការបណ្តុះបណ្តាលនៅនឹងកន្លែងការងារដោយបញ្ចូលទំនាក់ទំនងបញ្ហាប្រជាជននិងការអភិវឌ្ឍ។

### ៧.២.១៣- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

- សហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្នុងការតាមដាន ត្រួតពិនិត្យនិងវាយតម្លៃពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់។
- បន្តតាមដាននិន្នាការនៃការផ្លាស់ប្តូរតម្រូវការលំនៅឋាន និងធ្វើសុខដុមនីយកម្មតម្រូវការនេះជាមួយនឹងនិន្នាការប្រជាជន។

### ៧.២.១៤- ក្រសួងឧស្សាហកម្មនិងសិប្បកម្ម

- សហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្នុងការតាមដាន ត្រួតពិនិត្យនិងវាយតម្លៃពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់។
- ពង្រីកវិសាលភាពនៃការផ្គត់ផ្គង់ទឹកស្អាតនៅតំបន់ទីប្រជុំជន។

### ៧.២.១៥- ក្រសួងរ៉ែនិងថាមពល

- សហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្នុងការតាមដាន ត្រួតពិនិត្យនិងវាយតម្លៃពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់។
- បង្កើនការយល់ដឹងក្នុងសហគមន៍ពីផលប៉ះពាល់បរិស្ថានដែលពាក់ព័ន្ធនិងការផ្គត់ផ្គង់ថាមពលដូចជាអគ្គិសនី និងថាមពលសម្រាប់ចម្អិនអាហារ។

### ៧.២.១៦- ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ

- សហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្នុងការតាមដាន ត្រួតពិនិត្យនិងវាយតម្លៃពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់។
- បង្កើតទំនាក់ទំនងជាមួយនឹងក្រសួង ស្ថាប័នដទៃទៀតពីបញ្ហាប្រជាជនដែលមានលក្ខណៈជាអន្តរជាតិ និងជួយសម្រួលការកៀរគរធនធានពីប្រភពខាងក្រៅ។

### ៧.២.១៧- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- សហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្នុងការតាមដាន ត្រួតពិនិត្យនិងវាយតម្លៃពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់។
- លើកទឹកចិត្តដល់កសិករក្នុងការធ្វើពិពិធកម្មសកម្មភាពពាក់ព័ន្ធវិស័យកសិកម្ម ដោយផ្អែកលើធនធានធម្មជាតិដែលមាននៅមូលដ្ឋានដូចជា ការកែច្នៃម្ហូបអាហារ សាកវប្បកម្ម វារីវប្បកម្ម បសុបក្សីវប្បកម្ម ការចិញ្ចឹមជ្រូក ការចិញ្ចឹមគោយកទឹកដោះ ការចិញ្ចឹមដង្កូវនាងយកសូត្រ ជាដើម ដើម្បីបង្កើនប្រាក់ចំណូលរបស់កសិករ។

- បង្កើតតំបន់ដាំដុះកសិផលដើម្បីលក់និងលើកទឹកចិត្តកសិករក្នុងការដាំដុះកសិផលដើម្បីលក់។
- ជានាការប្រើប្រាស់ ការការពារ និងកែលម្អគុណភាព ពិសេស ធនធានដីកសិកម្ម ឲ្យមាននិរន្តរភាពដើម្បីប្រសិទ្ធភាពផលិតកម្មនិងនិរន្តរភាពនៃការអភិវឌ្ឍវិស័យកសិកម្ម។

### ៧.២.១៨- ក្រសួងធនធានទឹកនិងឧតុនិយម

- សហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្នុងការតាមដានត្រួតពិនិត្យនិងវាយតម្លៃពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់។
- ជានាឲ្យមានទឹកស្អាតនិងមានសុវត្ថិភាពសម្រាប់មនុស្សទាំងអស់តាមរយៈការស្តុកនិងច្នៃទឹកភ្លៀង និងការបំពេញធនធានទឹកក្រោមដី។
- អប់រំកសិករប្រើប្រាស់ទឹកពីសារៈសំខាន់នៃការគ្រប់គ្រងនិងការប្រើប្រាស់ទឹក ហើយនិងការអភិរក្សធនធានទឹក។
- ពង្រីកវិសាលភាពប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធការពារនិងគ្រប់គ្រងទឹកជំនន់ និងហានិភ័យដែលកើតចេញពីទឹក។

### ៧.២.១៩- ក្រសួងបរិស្ថាន

- សហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្នុងការតាមដានត្រួតពិនិត្យនិងវាយតម្លៃពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់។
- បង្កើតកម្មវិធីអប់រំប្រជាជនអំពីការខូចបរិស្ថាន និងការថយចុះនៃធនធានធម្មជាតិ(ដូចជាធនធានព្រៃឈើ) ដែលរងផលប៉ះពាល់ផ្ទាល់ពីទេសន្តរប្រវេសន៍ដ៏ច្រើនលើសលប់។

### ៧.២.២០- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

- សហការជាមួយក្រសួងនិងស្ថាប័នពាក់ព័ន្ធនានា ក្នុងការតាមដានត្រួតពិនិត្យនិងវាយតម្លៃពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់។
- បញ្ជ្រាប បណ្តុះបណ្តាល និងបំពាក់បរិក្ខារតាមមណ្ឌលសុខភាពនិងមន្ទីរពេទ្យនៅទីជនបទ និងតំបន់ទីប្រជុំជន អំពីការផ្តល់សេវាថែទាំសុខភាពមនុស្សចាស់។
- លើកទឹកចិត្តដល់អង្គការមិនមែនរដ្ឋាភិបាលនិងអង្គការស្ម័គ្រចិត្តនានា ដើម្បីបង្កើតនិងពង្រឹងឱកាសផ្សេងៗទាំងផ្លូវការ ទាំងមិនមែនផ្លូវការ ដែលធ្វើឲ្យមនុស្សចាស់អាចពឹងផ្អែកខ្លួនឯងបានផ្នែកសេដ្ឋកិច្ច។
- ស្វែងយល់ពីលទ្ធភាពផ្តល់អត្ថប្រយោជន៍ពន្ធ ជាការលើកទឹកចិត្តដល់បុត្រធីតា ដែលមើលថែទាំឪពុកម្តាយរបស់ពួកគេ។

- គិតគូរពិចារណាពីលទ្ធភាពនៃការផ្តល់របបសន្តិសុខសង្គម ដល់ជនក្រីក្រជាមនុស្សចាស់ និងប្រាក់សោធននិវត្តដល់អ្នកមេម៉ាយ ពោះម៉ាយ។

### ៧.២.២១- ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

- សហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្នុងការតាមដាន ត្រួតពិនិត្យនិងវាយតម្លៃពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់។
- ជួយជំរុញ និងលើកទឹកចិត្តការនិពន្ធឬការសម្តែងនានា ដែលឆ្លុះបញ្ចាំងពីការពិតក្នុងសង្គមសព្វថ្ងៃ ពិសេស រឿងទាក់ទងនឹងគ្រួសារ យុវជន និងមនុស្សចាស់។

### ៧.២.២២- ក្រសួងយុត្តិធម៌

- សហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្នុងការតាមដាន ត្រួតពិនិត្យនិងវាយតម្លៃពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់។
- សម្របសម្រួលដល់ការពិនិត្យឡើងវិញនូវច្បាប់ដែលមានស្រាប់ពីបញ្ហាពាក់ព័ន្ធទៅនឹង ប្រជាជន សុខភាពបន្តពូជ បរិស្ថាន ការរើសអើងយេនឌ័រ និងមនុស្សចាស់។

### ៧.២.២៣- ក្រសួងសាធារណៈការនិងដឹកជញ្ជូន

- សហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្នុងការតាមដាន ត្រួតពិនិត្យនិងវាយតម្លៃពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់។
- បន្តស្តារនិងសាងសង់ផ្លូវជាតិនិងផ្លូវខេត្ត ដែលភ្ជាប់ពីតំបន់ដាច់ស្រយាលមកកាន់រាជធានីភ្នំពេញ ដែលអាចចរាចរបានគ្រប់រដូវ។

### ៧.២.២៤- ក្រសួងពាណិជ្ជកម្ម

- សហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្នុងការតាមដាន ត្រួតពិនិត្យនិងវាយតម្លៃពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់។
- បង្កើតទីផ្សារដែលអាចគ្រប់គ្រងបានដើម្បីធានាថ្លៃមុខទំនិញនានា។
- កាត់បន្ថយតួនាទីអន្តរការីទីផ្សារ ដើម្បកាត់បន្ថយថ្លៃផលិតកម្ម។

### ៧.២.២៥- ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍

- សហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្នុងការតាមដាន ត្រួតពិនិត្យនិងវាយតម្លៃពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់។

- ពង្រឹងនិងពង្រីកសេវាប្រៃណីយ៍ឲ្យកាន់តែមានគុណភាព ប្រសិទ្ធភាព ដើម្បីជួយសម្រួលដល់សេចក្តីត្រូវការរបស់ប្រជាជន ក្នុងការរក្សាទំនាក់ទំនង តាមរយៈការផ្ញើនិងទទួលបញ្ញើនៅក្នុងស្រុក ក៏ដូចជាក្រៅស្រុក។
- ពង្រឹងនិងពង្រីកសេវាទូរគមនាគមន៍ឲ្យកាន់តែមានគុណភាពខ្ពស់ និងមានប្រសិទ្ធភាពសម្រាប់បម្រើសេចក្តីត្រូវការរបស់ប្រជាជន ក្នុងជីវភាពរស់នៅប្រចាំថ្ងៃ ក៏ដូចជាក្នុងការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ សិក្សាអប់រំ ជាដើម ឲ្យស្របតាមការរីកចម្រើនឥតឈប់ឈរនៃវិស័យទូរគមនាគមន៍ បច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន ហើយមានតម្លៃសមរម្យ។
- បង្កើតជាកម្មវិធីផ្សេងៗ សម្រាប់ជួយអប់រំពីបញ្ហាអេដស៍ គ្រឿងញៀន គ្រោះថ្នាក់ចរាចរណ៍ពីបំណិនជីវិត ឬការថែរក្សាសុខភាពដើម្បីឲ្យប្រជាជនអាចជៀសវាងបានពីហានិភ័យដែលបណ្តាលមកពីបញ្ហាទាំងនេះ។
- សហការនិងសម្របសម្រួលការប្រើប្រាស់លេខគ្រាអាសន្នរបស់ជាតិ ក្នុងការជួយសង្គ្រោះប្រជាជនប្រកបដោយនិរន្តរភាពនិងប្រសិទ្ធភាព។

### ៧.២.២៦- **ក្រសួងទេសចរណ៍**

- សហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្នុងការតាមដានត្រួតពិនិត្យនិងវាយតម្លៃពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់។
- ជំរុញការអភិវឌ្ឍទេសចរណ៍ដែលជាវិស័យទំនាក់ទំនងរវាងប្រជាជននិងប្រជាជន តាមរយៈការបង្កើតផលិតផលទេសចរណ៍ ទីក្រុងទេសចរណ៍ តំបន់រមណីយដ្ឋានទេសចរណ៍ សេវាកម្មទេសចរណ៍នានា សំដៅបង្កើតមុខរបរ ឱកាសការងារ និងប្រាក់ចំណូល។

### ៧.២.២៧- **ធនាគារជាតិនៃកម្ពុជា**

- សហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្នុងការតាមដានត្រួតពិនិត្យនិងវាយតម្លៃពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់។
- សម្របសម្រួលជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីជំរុញការផ្តល់សេវាហិរញ្ញវត្ថុដែលពាក់ព័ន្ធនឹងគម្រោង ឬកម្មវិធីមនុស្សចាស់។

### ៧.២.២៨- **ក្រុមប្រឹក្សាជាតិគាំពារសង្គម**

- សហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្នុងការតាមដានត្រួតពិនិត្យនិងវាយតម្លៃពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់។

- សម្របសម្រួលនិងជំរុញការអនុវត្តផែនការយុទ្ធសាស្ត្រ ដើម្បីអភិវឌ្ឍប្រព័ន្ធសន្តិសុខសង្គមមួយ ប្រកបដោយលក្ខណៈប្រមូលផ្តុំ សង្គតិភាព ប្រសិទ្ធភាព ចីរភាព និងស្ថិរភាពហិរញ្ញវត្ថុ។

**៧.២.២៩- គណៈកម្មាធិការជាតិរៀបចំបុណ្យជាតិនិងអន្តរជាតិ**

- សហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្នុងការតាមដានត្រួតពិនិត្យនិងវាយតម្លៃពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់។

**៧.២.៣០- គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ**

- សហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្នុងការតាមដានត្រួតពិនិត្យនិងវាយតម្លៃពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់។

**៧.២.៣១- កាកបាទក្រហមកម្ពុជា**

- សហការជាមួយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្នុងការតាមដានត្រួតពិនិត្យនិងវាយតម្លៃពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់។

**៧.២.៣២- ដៃគូអភិវឌ្ឍន៍នានានិងអង្គការសង្គមស៊ីវិល**

- ផ្តល់សេវាប្រឹក្សាយោបល់ពិសេសដល់យុវជន មនុស្សចាស់ ជនពិការ និងជនដែលមានតម្រូវការពិសេសពីសិទ្ធិទទួលបានសេវាកម្ម។
- ជួយបំពេញបន្ថែមកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការធ្វើផែនការ ការផ្តល់ហិរញ្ញប្បទាន ការអនុវត្ត ការតាមដានត្រួតពិនិត្យនិងការវាយតម្លៃ កម្មវិធីពាក់ព័ន្ធនឹងបញ្ហាមនុស្សចាស់។
- ផ្តល់ការគាំទ្រផ្នែកបច្ចេកទេសនិងហិរញ្ញវត្ថុក្នុងការរៀបចំកម្មវិធីនិងគម្រោងអភិវឌ្ឍន៍ប្រជាជនវ័យចាស់នៅថ្នាក់មូលដ្ឋាន។

## ៧.៣- ការរៀបចំស្ថាប័ននៅថ្នាក់ក្រោមជាតិ

**៧១-** ដើម្បីឲ្យមានការអនុវត្តបែបវិមជ្ឈការប្រកបដោយប្រសិទ្ធភាព ការរៀបចំស្ថាប័ននៅថ្នាក់ជាតិអាចមានដូចគ្នានឹងនៅថ្នាក់ក្រោមជាតិដែរ។ មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទារាជធានី ខេត្ត ត្រូវដើរតួនាទីក្នុងការសម្របសម្រួលការអនុវត្តគោលនយោបាយនេះ ដោយអ្នកមានចំណែកពាក់ព័ន្ធទាំងអស់ រួមមាន មន្ទីរជំនាញរាជធានី ខេត្ត សង្គមស៊ីវិល វិស័យឯកជន និងសហគមន៍មនុស្សចាស់ក្នុងការអនុវត្តគោលនយោបាយនេះ។ ការិយាល័យជំនាញនៅថ្នាក់ស្រុកនិងក្រុមប្រឹក្សាឃុំ សង្កាត់

មានតួនាទីក្នុងការសម្របសម្រួលការអនុវត្តសកម្មភាពនៅថ្នាក់ស្រុកនិងថ្នាក់ឃុំ ដោយធ្វើឲ្យមានការចូលរួមពីអ្នកមានចំណែកពាក់ព័ន្ធដទៃទៀត ក្នុងការអនុវត្តគោលនយោបាយនេះ។

## ៧.៤- ការតាមដានត្រួតពិនិត្យនិងការវាយតម្លៃ

**៧២-** ការអនុវត្តដែលមានលក្ខណៈជាប្រព័ន្ធ និងពហុវិស័យ ដែលជាកត្តាចាំបាច់សម្រាប់ការធ្វើឲ្យសម្រេចបានគោលដៅនៃគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់នេះ ទាមទារឲ្យមានការចូលរួម និងកិច្ចសហការគ្នាពីគ្រប់ក្រសួងស្ថាប័ននិងភាគីពាក់ព័ន្ធនៅគ្រប់កម្រិត។ ក្នុងន័យនេះការតាមដានត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តគោលនយោបាយនេះ ដែលជាឧបករណ៍មួយដ៏សំខាន់សម្រាប់ការផ្តល់នូវព័ត៌មាន អំពីវឌ្ឍនភាពដែលសម្រេចបានកន្លងមក និងអំពីការតម្រង់ទិសសម្រាប់ដំណាក់កាលបន្ទាប់ នឹងត្រូវរៀបចំឡើង ដោយផ្តោតទៅលើ៖

- លទ្ធផល(Outcomes) និងផលប៉ះពាល់(Impact)ដែលត្រូវបានបង្កើតឡើងតាមរយៈការអនុវត្ត កម្មវិធីនិងគម្រោងពាក់ព័ន្ធ
- ដំណើរការនិងសកម្មភាពនៃការអនុវត្តគោលនយោបាយ
- ការចូលរួមរបស់គ្រប់ភាគីពាក់ព័ន្ធនៅគ្រប់កម្រិត
- ការកសាងនិងពង្រឹងសមត្ថភាពរបស់ក្រសួងស្ថាប័ននិងភាគីពាក់ព័ន្ធ
- ប្រសិទ្ធភាពនៃការប្រើប្រាស់ធាតុចូល ពិសេស គឺថវិកានិងពេលវេលា។

**៧៣-** ការតាមដានត្រួតពិនិត្យនិងវាយតម្លៃអំពីការអនុវត្តគោលនយោបាយនេះ ដែលនឹងត្រូវកំណត់នៅក្នុងផែនការសកម្មភាព និងត្រូវធ្វើឡើងដោយទៀងទាត់តាមពេលវេលា និងដោយប្រើប្រាស់យន្តការ និងរចនាសម្ព័ន្ធសមស្របសម្រាប់ការងារនេះ។ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងផែនការ មានភារកិច្ចក្នុងការតាមដានត្រួតពិនិត្យនិងវាយតម្លៃពីវឌ្ឍនភាពនៃការអនុវត្តគោលនយោបាយនេះ។

## ៧.៥- ជំហានបន្ទាប់

### ៧.៥.១- ការប្រមូលទិន្នន័យ

**៧៤-** មូលដ្ឋានទិន្នន័យសម្រាប់ការសិក្សាពីប្រជាជនវ័យចាស់និងផលប៉ះពាល់របស់ស្ថានភាពប្រជាសាស្ត្រនេះ ត្រូវបានធ្វើឲ្យប្រសើរឡើងគួរជាទីកត់សម្គាល់ ក្នុងកំលុងរយៈពេលមួយទសវត្សរ៍ចុងក្រោយនេះ។ ទោះជាយ៉ាងណាក្តី ការងារចាំបាច់ដែលត្រូវធ្វើបន្តនោះគឺ ការកំណត់នូវភាពខ្វះចន្លោះផ្នែកទិន្នន័យនិងការចាត់វិធានការជាជំហានៗដើម្បីបំពេញភាពខ្វះចន្លោះទាំងនោះ។ ទិន្នន័យប្រជាជនអាយុលើសពី៧៥ឆ្នាំ នៅពុំទាន់មានគ្រប់គ្រាន់នៅឡើយ។ ថ្វីបើមកទល់ពេលបច្ចុប្បន្ន តម្រូវការទិន្នន័យនេះ ប្រហែលជានៅពុំទាន់មាននៅឡើយ អាស្រ័យដោយចំនួនប្រជាជនក្នុងវ័យនេះនៅមាន

ចំនួនតិចក៏ដោយ ក៏យើងនឹងត្រូវការទិន្នន័យនេះនៅពេលដែលចំនួនប្រជាជនវ័យចាស់មានការកើនឡើង ដើម្បីដោះស្រាយបញ្ហានានាដែលនឹងលេចចេញពីដំណើរឈានចូលវ័យចាស់របស់ប្រជាជន។ ជាមួយគ្នានេះដែរ ព័ត៌មានជាច្រើនទៀត អាចមានសារៈសំខាន់សម្រាប់ការយល់បានឲ្យកាន់តែច្បាស់ជាងមុនអំពីបញ្ហាជាក់លាក់មួយចំនួន។ ព័ត៌មានទាំងនោះមានសារៈសំខាន់ សម្រាប់ការជួយបំភ្លឺបញ្ហារំលោភបំពានលើមនុស្សចាស់ក្នុងគ្រួសារ ដោយហេតុថាបញ្ហារំលោភបំពាននេះអាចកំពុងកើនឡើងដោយពុំមានការកត់សម្គាល់ ដែលអាចលេចចេញមកពីសម្ពាធនៃការផ្ដល់ការថែទាំដែលកាន់តែកើនឡើងទៅលើមនុស្សដែលមានវ័យក្មេងជាង។ តម្រូវការព័ត៌មាននិងទិន្នន័យត្រូវតែតាមដានត្រួតពិនិត្យជាប្រចាំ ហើយកិច្ចខិតខំប្រឹងប្រែងត្រូវតែធ្វើឡើងដើម្បីបំពេញភាពខ្វះចន្លោះផ្នែកទិន្នន័យ។ ផ្នែកឬអង្គភាពជំនាញទទួលបន្ទុកស្ថិតិមនុស្សចាស់ ត្រូវបង្កើតឡើងនិងពង្រឹងនៅក្នុងវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ សម្រាប់គោលបំណងនេះ។

## ៧.៥.២- ការសិក្សាស្រាវជ្រាវ

**៧៥-** ការសិក្សាស្រាវជ្រាវផ្អែកលើភស្តុតាងស្ដីពីប្រជាជនវ័យចាស់និងបញ្ហាកើតចេញពីស្ថានភាពប្រជាសាស្ត្រនេះ ត្រូវជំរុញលើកទឹកចិត្តឲ្យធ្វើឡើង ដើម្បីធ្វើឲ្យមានការយល់ដឹងឲ្យកាន់តែស៊ីជម្រៅបន្ថែមទៀតពីបញ្ហាទាក់ទងនឹងមនុស្សវ័យចាស់។ មជ្ឈោបាយផ្នែកស្រាវជ្រាវទាំងឡាយនៃស្ថាប័នឧត្តមសិក្សា ត្រូវជំរុញលើកម្ពស់និងទទួលបានការគាំទ្រ ដើម្បីអាចធ្វើការសិក្សាស្រាវជ្រាវផ្នែកគោលនយោបាយដែលមានគុណភាពស្ដីពីប្រជាជនវ័យចាស់។

## ៧.៥.៣- ការកសាងសមត្ថភាព

**៧៦-** គួបផ្សំជាមួយនឹងការបណ្ដុះបណ្ដាល អ្នកធ្វើការងារផ្នែកសង្គមកិច្ច អ្នកជំនាញផ្នែកមនុស្សចាស់ និងអ្នកថែទាំមនុស្សចាស់ ដែលត្រូវគិតគូរដោះស្រាយ នៅក្នុងការអនុវត្តវិធានការពាក់ព័ន្ធដែលមានចែងក្នុងគោលនយោបាយនេះ ការកសាងសមត្ថភាពក្នុងការបង្កើតកម្មវិធី ការត្រួតពិនិត្យតាមដានកម្មវិធី និងការធ្វើផែនការសម្រាប់ការអនុវត្តគោលនយោបាយនេះ គឺជាការងារចាំបាច់។ ទន្ទឹមនឹងនេះ ការងារចាំបាច់ដែលត្រូវយកចិត្តទុកដាក់ផងដែរនោះគឺការពង្រឹងសមត្ថភាពនៅក្នុង ក្រសួងផែនការ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងក្រសួងជំនាញ សម្រាប់ការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពនូវទិន្នន័យនិងភស្តុតាងផ្អែកលើការអនុវត្តជាក់ស្ដែងដទៃទៀតដើម្បី គាំទ្រដល់ការបង្កើត ការពិនិត្យឡើងវិញ និងការអនុវត្តគោលនយោបាយនានា។ ត្រូវស្វែងរកការគាំទ្រពីដៃគូអភិវឌ្ឍ ដើម្បីផ្ដល់ការបណ្ដុះបណ្ដាលដល់ជំនាញការថ្នាក់ជាតិ នៅតាមស្ថាប័នសិក្សានានា ទាំងនៅក្នុងប្រទេស ទាំងនៅក្រៅប្រទេសដូចជា សាកលវិទ្យាល័យជាតិអូស្ត្រាលីនិងវិទ្យាស្ថានអន្តរជាតិស្ដីមនុស្សចាស់ នៅប្រទេសម៉ាល់តា ជាដើម។

### ៧.៥.៤- ច្បាប់ស្តីពីមនុស្សចាស់

**៧៧-** ច្បាប់ស្តីពីការការពារសិទ្ធិមនុស្សចាស់នឹងត្រូវបង្កើតឡើង ដើម្បីធានាដល់មនុស្សចាស់នូវសិទ្ធិទទួលបានសន្តិសុខផ្នែកហិរញ្ញវត្ថុ លទ្ធភាពទទួលបានសេវាសុខភាព ការការពារពីការរំលោភបំពាន និងអំពើហិង្សា ការលុបបំបាត់ការរើសអើងចំពោះមនុស្សចាស់ និងសិទ្ធិដទៃទៀត។ ច្បាប់ស្តីពីបញ្ហាមនុស្សចាស់នេះ ត្រូវបានអនុម័តរួចមកហើយ នៅក្នុងបណ្តាប្រទេសអាស៊ានដទៃទៀត ដូចជាប្រទេសមីយ៉ាន់ម៉ា ប្រទេសថៃ និងប្រទេសវៀតណាម ជាដើម។

### ៧.៥.៥- ផែនការសកម្មភាព

**៧៨-** សម្រាប់ការអនុវត្តគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវធ្វើការសម្របសម្រួលជាមួយនឹងក្រសួងផែនការនិងក្រសួង ស្ថាប័នពាក់ព័ន្ធដទៃទៀត ក្នុងការរៀបចំផែនការសកម្មភាពលម្អិត។

**៧៩-** ផែនការសកម្មភាពនឹងចាប់ផ្តើមជាមួយនឹងការគិតគូរអនុវត្តនូវយុទ្ធសាស្ត្រទាំងឡាយដែលបានកំណត់ក្នុងគោលនយោបាយនេះ។ មិនមែនយុទ្ធសាស្ត្រទាំងអស់អាចឬចាំបាច់ត្រូវដាក់បញ្ចូលទៅក្នុងផែនការសកម្មភាពដំបូងនោះទេ។ ក្នុងន័យនេះ ក្រសួង ស្ថាប័នពាក់ព័ន្ធនឹងត្រូវផ្តល់ចំណាត់ថ្នាក់អាទិភាពដល់យុទ្ធសាស្ត្រដែលពាក់ព័ន្ធ និងជ្រើសរើសយកយុទ្ធសាស្ត្រទាំងឡាយណា ដែលត្រូវដាក់បញ្ចូលនៅក្នុងផែនការសកម្មភាពទី១។ សម្រាប់យុទ្ធសាស្ត្រនីមួយៗ ផែនការសកម្មភាពនឹងកំណត់នូវ៖

(i) សកម្មភាពជាក់លាក់ដែលត្រូវអនុវត្ត

(ii) ភាគីដែលមានការទទួលខុសត្រូវ

(iii) ចំណុចដៅដែលត្រូវសម្រេចបាន

(iv) ក្របខ័ណ្ឌពេលវេលា

(v) ការចំណាយលើការអនុវត្ត និង

(vi) ប្រភពនៃទុនដែលត្រូវការ

## ៧.៥.៦- យន្តការតាមដានត្រួតពិនិត្យនិងវាយតម្លៃ

**៨០-** ការតាមដានត្រួតពិនិត្យនិងការវាយតម្លៃការអនុវត្តគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ត្រូវបានធ្វើឡើងស្របតាមយន្តការដែលមានស្រាប់ ដូចមានបង្ហាញក្នុងរូបភាពខាងក្រោម។

**តារាងទី៥ : រចនាសម្ព័ន្ធ**



## ឧបសម្ព័ន្ធ : ម៉ាទ្រីសនៃការទទួលខុសត្រូវតាមវិស័យរបស់ក្រសួង ស្ថាប័នពាក់ព័ន្ធ

| ទិសដៅ | យុទ្ធសាស្ត្រ | ស្ថាប័នទទួលខុសត្រូវ |
|---|---|---|
| **អាទិភាពទី១ : ការធានាឲ្យបាននូវសន្តិសុខហិរញ្ញវត្ថុ** | | |
| **ទិសដៅ ១.១ :** បង្កលក្ខណៈឲ្យមនុស្សចាស់អាចមានឱកាសបន្តធ្វើការងារដែលផ្តល់ផលផ្លែ ក្នុងករណីដែលពួកគាត់ចង់និងមានលទ្ធភាពអាចធ្វើបាន។ | ១. បង្កើនការយល់ដឹងអំពីការរើសអើងនៅក្នុងការងារដោយផ្អែកលើអាយុក្នុងចំណោមអ្នកមានចំណែកពាក់ព័ន្ធសំខាន់ៗ រួមមាន ក្រុមមនុស្សចាស់ សហជីពកម្មករ និងសមាគមនិយោជក។ | • ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| | ២. ជំរុញការបង្កើតក្របខ័ណ្ឌគាំទ្រផ្នែកច្បាប់ សម្រាប់ករណីការរើសអើងផ្នែកអាយុ។ | • ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងមហាផ្ទៃ ក្រសួងយុត្តិធម៌ ក្រសួងកិច្ចការនារី |
| | ៣. បញ្ជ្រាបការយល់ដឹងដល់និយោជកពីបទពិសោធ និងសក្តានុពលវិជ្ជមានរបស់កម្មករនិយោជិតវ័យចាស់។ | • ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| | ៤. ដាក់ឲ្យមានបទបញ្ញត្តិច្បាប់ដែលតម្រូវឲ្យនិយោជកផ្តល់នូវលក្ខខណ្ឌការងារ ដូចជាគ្រឿងបរិក្ខារដែលងាយប្រើប្រាស់ អាហារដែលផ្តល់សុខភាពល្អ សេវាសុខភាពមូលដ្ឋាន និងបរិស្ថានកន្លែងធ្វើការងារទូទៅដែលសមស្របសម្រាប់កម្មករនិយោជិតវ័យចាស់។ | • ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងសុខាភិបាល ក្រសួងបរិស្ថាន |
| | ៥. សិក្សាអំពីលទ្ធភាពនៃការរៀបចំប្រព័ន្ធលើកទឹកចិត្តសម្រាប់សហគ្រាសដែលជួលបុគ្គលិក កម្មករ និយោជិតវ័យចាស់ ហើយនិងលើកទឹកចិត្តឲ្យសហគ្រាសទាំងនោះឲ្យផ្តល់ការសម្រួលនិង | • ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |

| ទិសដៅ | យុទ្ធសាស្ត្រ | ស្ថាប័នទទួលខុសត្រូវ |
|---|---|---|
| | លក្ខខណ្ឌការងារសមស្រប ។ | |
| | ៦. លើកកម្ពស់លទ្ធភាពអាចធ្វើការងារបានរបស់មនុស្សចាស់ តាមរយៈសមត្ថភាពជំនាញដែលមានស្រាប់ ឬការបណ្តុះបណ្តាលឡើងវិញ និងការអប់រំជាប្រចាំ។ | ◆ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| | ៧. ពិចារណាដាក់ចេញនូវវិធានការដើម្បីសម្រួលដល់ការធ្វើដំណើរទៅធ្វើការរបស់កម្មករនិយោជិតវ័យចាស់ ដោយគិតគូរឲ្យមានតម្លៃសមរម្យសម្រាប់ការប្រើប្រាស់មធ្យោបាយធ្វើដំណើរសាធារណៈ។ | ◆ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងសាធារណៈការនិងដឹកជញ្ជូន អាជ្ញាធរ រាជធានី ខេត្ត |
| | ៨. សិក្សាអំពីលទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុ សម្រាប់មនុស្សចាស់។ | ◆ ក្រសួងអភិវឌ្ឍន៍ជនបទ ធនាគារជាតិនៃកម្ពុជា ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| **ទិសដៅ ១.២** :<br>ពង្រីកដែនគ្របដណ្តប់នៃគម្រោងកិច្ចគាំពារសង្គម និងសុខុមាលភាពសង្គមដែលមានលក្ខណៈទូលំទូលាយ | ១. សិក្សាអំពីលទ្ធភាពក្នុងការដាក់ឲ្យដំណើរការកម្មវិធីគាំពារមនុស្សចាស់និងជនចាស់ជរា ដែលជាសមាជិកនៃគ្រួសារដែលកាន់បណ្ណសមធម៌ ស្រមតាមក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម។ | ◆ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ធនាគារជាតិនៃកម្ពុជា |
| | ២. ពិនិត្យលទ្ធភាពក្នុងការដាក់ឲ្យអនុវត្តនូវកម្រាលគាំពារសង្គមដើម្បីធានាថា មនុស្សចាស់ដែលគ្មានប្រាក់សោធននិវត្តឬមានមិនគ្រប់គ្រាន់ ហើយដែលគ្មានសមាជិកគ្រួសារមើលថែអាចទទួលបាន | ◆ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម ក្រសួងឧស្សាហកម្មនិងសិប្បកម្ម |

| ទិសដៅ | យុទ្ធសាស្ត្រ | ស្ថាប័នទទួលខុសត្រូវ |
|---|---|---|
| | ប្រាក់ ចំណូលសមរម្យ ដើម្បីកុំឲ្យពួកគាត់ធ្លាក់ចូលទៅក្នុងភាពក្រីក្រ។ | |
| | ៣. បង្កើនការយល់ដឹងនិងជំរុញកូនចៅជាមនុស្សពេញវ័យ ដែលមានលទ្ធភាពផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុដល់ឳពុកម្តាយ ឬជីដូនជីតាចាស់ជរា និងសាច់ញាតិជិតស្និទ្ធរបស់ខ្លួន ដើម្បីបំពេញកាតព្វកិច្ចរបស់ខ្លួន ក្នុងនាមជាកូនចៅ។ | • ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្មនិងជនបទ ក្រសួងផែនការ |
| **អាទិភាពទី២ : សុខភាពនិងសុខុមាលភាព** | | |
| **ទិសដៅ ២.១ :** ជំរុញលើកទឹកចិត្តឲ្យដំណើរឈានចូលវ័យចាស់ប្រកបដោយសុខភាពល្អនិងពង្រីកការថែទាំសុខភាពតាមលក្ខណៈការការពារជាមុន | ១. រៀបចំឲ្យមានដំណើរជីវិតមួយប្រកបដោយសុខភាពល្អពេលវ័យចាស់និងមានការការពារទប់ស្កាត់ជំងឺ តាមរយៈការដាក់ឲ្យដំណើរការនូវការផ្តល់ព័ត៌មានដែលមានលក្ខណៈជាការអប់រំសម្រាប់មនុស្សចាស់ អ្នកមើលថែទាំ និងអ្នកផ្តល់សេវាសុខភាព រួមទាំងព័ត៌មានអំពីសារៈសំខាន់នៃសកម្មភាពផ្នែករាងកាយ អនាម័យ ល្អ និងរបបអាហារមានតុល្យភាព។ | • ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងសុខាភិបាល ក្រសួងអប់រំ យុវជន និងកីឡា |
| | ២. រៀបចំឲ្យមានសេវាប្រឹក្សាយោបល់សម្រាប់មនុស្សចាស់នៅមណ្ឌលសុខភាព។ | • ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងសុខាភិបាល |
| | ៣. បង្កលក្ខណៈឲ្យមនុស្សចាស់អាចទទួលបានសេវាត្រួតពិនិត្យសុខភាពជាប្រចាំសម្រាប់ ការពិនិត្យតាមដាននិងព្យាបាល និងអាចមានលទ្ធភាពទទួលបានថ្នាំបង្ការសម្រាប់ការការពារទប់ស្កាត់ជំងឺនិងការ | • ក្រសួងសុខាភិបាល |

| ទិសដៅ | យុទ្ធសាស្ត្រ | ស្ថាប័នទទួលខុសត្រូវ |
|---|---|---|
| | លើកកម្ពស់សុខភាពនៅពេលវ័យចាស់។ | |
| | ៤. បង្កើតប្រព័ន្ធតាមដាននៅទូទាំងប្រទេស ដើម្បីពិនិត្យតាមដានមើលមនុស្សចាស់ជរាដែលនៅឯកោនិងមនុស្សចាស់ដែលងាយរងគ្រោះ។ | ◆ ក្រសួងសុខាភិបាល |
| **ទិសដៅ ២.២** : បង្កើតប្រព័ន្ធសុខាភិបាលមួយដែលមានលក្ខណៈឆ្លើយតប ដែលអាចទទួលបាននិងធានាបាននូវសេវាព្យាបាលប្រកបដោយគុណភាព។ | ១. ផ្តល់ឲ្យមូលដ្ឋានសុខាភិបាលដែលផ្តល់សេវាព្យាបាលសុខភាពនូវបុគ្គលិកគ្រប់គ្រាន់ ប្រកបដោយវិជ្ជាជីវៈ មានក្រមសីលធម៌ និងនៅប្រចាំការ ដើម្បីផ្តល់សេវាសុខភាពមូលដ្ឋានដល់មនុស្សចាស់ រួមទាំងការបញ្ជូនទៅឲ្យសេវាសុខភាពឯកទេសនិងការតាមដានបន្តផងដែរ។ | ◆ ក្រសួងសុខាភិបាល |
| | ២. ត្រៀមលក្ខណៈឲ្យមន្ទីរពេទ្យថ្នាក់ជាតិ អាចផ្តល់នូវសេវាសុខភាពពេញលេញ សម្រាប់មនុស្សចាស់ ក្នុងនោះរួមទាំង ការត្រួតពិនិត្យ ការធ្វើរោគវិនិច្ឆ័យ និងការព្យាបាលផ្សេងៗ។ | ◆ ក្រសួងសុខាភិបាល |
| | ៣. ដាក់ឲ្យមានអ្នកវិជ្ជាជីវៈសុខាភិបាល ដែលបានទទួលការបណ្តុះបណ្តាលអំពីសុខភាពមនុស្សចាស់នៅគ្រប់មណ្ឌលសុខភាពទាំងអស់។ | ◆ ក្រសួងសុខាភិបាល |

| ទិសដៅ | យុទ្ធសាស្ត្រ | ស្ថាប័នទទួលខុសត្រូវ |
|---|---|---|
| | ៤. កសាងសមត្ថភាពឲ្យបានគ្រប់គ្រាន់នៅតាមមន្ទីរពេទ្យនានា ក្នុងការថែទាំអ្នកជំងឺសម្រាកក្នុងមន្ទីរពេទ្យ ដើម្បីអាចឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់មនុស្សចាស់ក្នុងការចូលសម្រាកព្យាបាលនៅមន្ទីរពេទ្យ។ | • ក្រសួងសុខាភិបាល |
| | ៥. ពង្រីកវិសាលភាពគ្របដណ្តប់សេវាថែទាំសុខភាពប្រកបដោយគុណភាពដោយឥតគិតថ្លៃ និងផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុដល់មនុស្សចាស់ក្រីក្រដែលមិនមានលទ្ធភាពបង់ថ្លៃសេវាវេជ្ជសាស្ត្រមួយចំនួន។ | • ក្រសួងសុខាភិបាល |
| | ៦. ធានាថាមន្ទីរពេទ្យ រដ្ឋទាំងអស់ មានសេវាវេជ្ជសាស្ត្រសម្រាប់មនុស្សចាស់ប្រកបដោយគុណភាព។ | • ក្រសួងសុខាភិបាល |
| | ៧. ធានាឲ្យមានឱសថសំខាន់ៗដែលត្រូវការជាទូទៅសម្រាប់ការព្យាបាលជំងឺដែលប៉ះពាល់ ដល់មនុស្សចាស់។ | • ក្រសួងសុខាភិបាល |
| **ទិសដៅ ២.៣** : ឆ្លើយតបនឹងតម្រូវការរបស់មនុស្សចាស់សម្រាប់ការថែទាំរយៈពេលវែង | ១. ពង្រឹងនិងសម្របសម្រួលដល់ការថែទាំនិងការព្យាបាលតាមផ្ទះចំពោះ មនុស្សចាស់ដែលត្រូវការការថែទាំរយៈពេលវែង ដោយសារពិការភាព ជំងឺរង្វេងវង្វាន់ ឬជំងឺដល់អាយុជីវិត។ | • ក្រសួងសុខាភិបាល, ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| | ២. ផ្តល់ការបណ្តុះបណ្តាលនិងការលើកទឹកចិត្តដល់សមាជិកគ្រួសារដែលត្រូវការ មើលថែអ្នកជំងឺវ័យចាស់ទាំងឡាយណាដែលត្រូវការ | • ក្រសួងសុខាភិបាល ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |

| ទិសដៅ | យុទ្ធសាស្ត្រ | ស្ថាប័នទទួលខុសត្រូវ |
|---|---|---|
| | ការថែទាំរយៈពេលវែង។ | |
| | ៣. ពិចារណារៀបចំបង្កើតមជ្ឈមណ្ឌលថែទាំសម្រាប់មនុស្សចាស់ទាំងឡាយណាដែលត្រូវការការថែទាំរយៈពេលយូរ។ | • ក្រសួងសុខាភិបាល ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| | ៤. កែលម្អលទ្ធភាពទទួលបានការប្រើប្រាស់សេវាតាមមូលដ្ឋានសុខាភិបាល សម្រាប់ការពិនិត្យនិងការព្យាបាលជំងឺរ៉ាំរ៉ៃនានាដូចជា ជំងឺលើសសម្ពាធឈាម ជំងឺទឹកនោមផ្អែម ជំងឺសរសៃឈាមក្នុងខួរក្បាល ជំងឺមហារីក ជំងឺវង្វេងវង្វាន់ និងជំងឺបាត់បង់ការចងចាំ។ | • ក្រសួងសុខាភិបាល |
| **ទិសដៅ ២.៤** : បន្តគិតគូរដោះស្រាយឲ្យមានបុគ្គលិកសុខាភិបាលគ្រប់គ្រាន់ និងដែលមានការបណ្តុះបណ្តាល | ១. វាយតម្លៃអំពីតម្រូវការអ្នកប្រកបវិជ្ជាជីវៈផ្នែកការថែទាំសុខភាពនិងសង្គមកិច្ច និងរៀបចំកម្មវិធីអប់រំឬបណ្តុះបណ្តាលបន្ថែមសម្រាប់បុគ្គលិកទាំងនេះ ទៅតាមសេចក្តីត្រូវការនាពេលបច្ចុប្បន្ន។ | • ក្រសួងសុខាភិបាល ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងផែនការ |
| | ២. លើកកម្ពស់ការអប់រំនិងការបណ្តុះបណ្តាលផ្នែកការថែទាំសុខភាព និងការថែទាំ មនុស្សចាស់ សម្រាប់អ្នកប្រកបវិជ្ជាជីវៈផ្នែកការថែទាំសុខភាពនិងសង្គមកិច្ច អ្នកស្ម័គ្រចិត្ត និងអ្នកថែទាំ។ | • ក្រសួងសុខាភិបាល ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងផែនការ |
| | ៣. បណ្តុះឲ្យមាននៅក្នុងគំនិតរបស់អ្នកផ្តល់សេវាសុខភាពពីទិដ្ឋភាពវិជ្ជមាន របស់មនុស្សចាស់ ព្រមទាំងការយកចិត្តទុកដាក់និងការគោរពដែលមនុស្សចាស់សមតែទទួលបាន។ | • ក្រសួងសុខាភិបាល ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងអប់រំ យុវជន និងកីឡា |

| ទិសដៅ | យុទ្ធសាស្ត្រ | ស្ថាប័នទទួលខុសត្រូវ |
|---|---|---|
| | ៤. បង្កើនចំនួនអ្នកជំនាញ ដែលបានទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈផ្នែកពេគមនុស្សចាស់។ | • ក្រសួងសុខាភិបាល ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងកិច្ចនារី |
| | ៥. ដាក់ឲ្យមានមុខវិជ្ជាសិក្សាស្តីពីការថែទាំសុខភាពមនុស្សចាស់នៅគ្រប់កម្មវិធីសិក្សាវិជ្ជាជីវៈសុខាភិបាល។ | • ក្រសួងសុខាភិបាល ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| **អាទិភាពទី៣** : របៀបរបបការរស់នៅ | | |
| **ទិសដៅ ៣.១** :<br>លើកទឹកចិត្តឲ្យមានដំណើរឈានចូលវ័យចាស់នៅនឹងកន្លែងដែលមនុស្សចាស់កំពុងរស់នៅ | ១. ផ្តល់ការបណ្តុះបណ្តាលមូលដ្ឋានដល់អ្នកថែទាំតាមផ្ទះក្នុងការថែទាំមនុស្សចាស់ ចំណេះដឹងនិងព័ត៌មានអំពីសេវាមានសារប្រយោជន៍ និងការចាត់ចែងក្នុងស្ថានភាពមានអាសន្ន។ | • ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងផែនការ |
| | ២. ផ្តល់ការប្រឹក្សាយោបល់ដល់អ្នកថែទាំតាមផ្ទះ ដើម្បីផ្តល់នូវភាពធូរស្រាលដល់ពួកគាត់ពីភាពតានតឹងផ្លូវចិត្ត ដែលជាលទ្ធផលកើតចេញពីការផ្តល់ការថែទាំ។ | • ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងផែនការ ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ៣. ធានាឲ្យមានការបង្កើននិងការកែលម្អការចុះទៅសួរសុខទុក្ខតាមផ្ទះដោយអ្នកបម្រើការសុខភាពនិងមន្ត្រីសុខុមាលភាពសង្គម។ | • ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងសុខាភិបាល |
| | ៤. លើកទឹកចិត្តឲ្យសហគ្រាសផ្តល់ការសម្រួលដល់និយោជិតទាំងឡាយណាដែលមានមនុស្សចាស់ជាសមាជិកគ្រួសារណាម្នាក់នៅ | • ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងផែនការ |

| ទិសដៅ | យុទ្ធសាស្ត្រ | ស្ថាប័នទទួលខុសត្រូវ |
|---|---|---|
| | ផ្ទះដែលត្រូវការការថែទាំ។ | |
| | ៥. លើកទឹកចិត្តអ្នកស្ម័គ្រចិត្តតាមសហគមន៍ ឲ្យជួយជ្រោមជ្រែងដល់មនុស្សចាស់ជរា នៅក្នុងសកម្មភាពប្រចាំថ្ងៃរបស់ពួកគាត់។ | • ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងផែនការ ក្រសួងអប់រំ យុវជន និងកីឡា |
| | ៦. ធ្វើឲ្យមនុស្សចាស់មានលទ្ធភាពកាន់តែងាយស្រួលក្នុងការទាក់ទងជាមួយនឹងសមាជិកគ្រួសារនិងសេវាគ្រាអាសន្នក្នុងករណីដែលត្រូវការ។ | • ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ |
| | ៧. ដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្ត ដើម្បីការពារមនុស្សចាស់ ពីការរំលោភបំពានគ្រប់ទម្រង់លើមនុស្សចាស់(ការរំលោភបំពានលើផ្លូវកាយ ពាក្យសម្ដី ហិរញ្ញវត្ថុ និងផ្លូវចិត្ត)។ | • ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងយុត្តិធម៌ ក្រសួងផែនការ |
| **ទិសដៅ ៣.២** : ផ្ដល់ការរៀបចំការរស់នៅសមស្របសម្រាប់មនុស្សចាស់ដែលពុំមានការគាំទ្រពីគ្រួសារ | ១. ពិចារណារៀបចំបង្កើតមជ្ឈមណ្ឌលមនុស្សចាស់នៅតាមសហគមន៍សម្រាប់ផ្ដល់ជម្រកដល់មនុស្សចាស់ដែលគ្មានទីពឹង។ | • ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងផែនការ |
| | ២. ជួយជ្រោមជ្រែងនិងផ្ដល់ប្រឹក្សាដល់វត្តអារាម ឲ្យពង្រីកនិងកែលម្អមូលដ្ឋានវត្តអារាមសម្រាប់ជាជម្រកដល់មនុស្សចាស់ងាយរងគ្រោះ។ | • ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងផែនការ |
| | ៣. ពិចារណារៀបចំឲ្យមានបទដ្ឋានដែលមានលក្ខណៈសមស្របសម្រាប់មជ្ឈមណ្ឌលមនុស្សចាស់នៅតាមសហគមន៍។ | • ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងការងារនិងបណ្ដុះបណ្ដាលវិជ្ជាជីវៈ |

| ទិសដៅ | យុទ្ធសាស្ត្រ | ស្ថាប័នទទួលខុសត្រូវ |
|---|---|---|
| | ៤. បង្កើតឲ្យមានកញ្ចប់សង្គ្រោះបឋមសម្រាប់មនុស្សចាស់នៅក្នុងមណ្ឌលសុខភាពនិងមន្ទីរពេទ្យបង្អែក។ | ◆ ក្រសួងសុខាភិបាល ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងផែនការ |
| **អាទិភាពទី៤ : បរិស្ថានអំណោយផល** | | |
| **ទិសដៅ ៤.១** : បង្កលក្ខណៈឲ្យមនុស្សចាស់អាចរស់នៅដោយឯករាជ្យបានប្រសិនបើពួកគាត់អាចនិងមានបំណងរស់នៅបែបនេះ | ១. ផ្តល់ព័ត៌មានដល់មនុស្សចាស់អំពីការបន្សាំដែលនឹងត្រូវធ្វើឡើងដើម្បីបង្កលក្ខណៈឲ្យពួកគាត់អាចរស់នៅដោយមានសុវត្ថិភាពនិងកាត់បន្ថយហានិភ័យនៃការជួបគ្រោះថ្នាក់នានា ដូចជា ការដួល ការរអិល ជាដើម។ | ◆ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងផែនការ ក្រសួងព័ត៌មាន |
| | ២. គិតគូរពិចារណាជំរុញឲ្យមានសេវាមូលដ្ឋានសំខាន់ៗសម្រាប់មនុស្សចាស់នៅតាមតំបន់ដែលមានមជ្ឈមណ្ឌលមនុស្សចាស់នៅតាមសហគមន៍។ | ◆ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងផែនការ ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ៣. ផ្តល់ដល់មនុស្សចាស់នូវលទ្ធភាពក្នុងការទាក់ទងរកជំនួយដែលអាចទុកចិត្តបានឬលទ្ធភាពក្នុងការទាក់ទាញចំណាប់អារម្មណ៍របស់មនុស្សដទៃទៀត ក្នុងករណីពួកគាត់ត្រូវការ។ | ◆ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងផែនការ |
| **ទិសដៅ ៤.២** : ការជួយសម្រួលដល់ការផ្លាស់ទី | ១. កែលម្អមធ្យោបាយធ្វើដំណើរសាធារណៈ ដោយបញ្ចូលការគិតគូរដោះស្រាយ សេចក្តីត្រូវការរបស់មនុស្សចាស់។ | ◆ ក្រសួងសាធារណការនិងដឹកជញ្ជូន ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងផែនការ |

| ទិសដៅ | យុទ្ធសាស្ត្រ | ស្ថាប័នទទួលខុសត្រូវ |
|---|---|---|
| របស់មនុស្សចាស់ | ២. ផ្តល់ការយកចិត្តទុកដាក់លើទិដ្ឋភាពមនុស្សចាស់នៅតាមសំណង់ ហេដ្ឋារចនាសម្ព័ន្ធសាធារណៈទាំងអស់ រួមមាន ផ្លូវថ្នល់ ផ្លូវថ្មើរជើង និងបង្គន់អនាម័យដើម្បីអាចផ្តល់លទ្ធភាពចេញចូលដោយងាយស្រួល និងប្រកឆ្លងកាត់ប្រកបដោយសុវត្ថិភាពសម្រាប់មនុស្សចាស់។ | • ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងផែនការ ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ៣. ផ្តល់គន្លងផ្លូវពិសេសនិងមូលដ្ឋានសម្ភារៈនិងគ្រឿងបរិក្ខារដែលមិនបង្កឧបសគ្គដល់មនុស្សចាស់ នៅកន្លែងសាធារណៈដូចជា ទីផ្សារ ធនាគារ ជាដើម។ | • ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងសារណៈការនិងដឹកជញ្ជូន |
| | ៤. ដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្តដែលតម្រូវឲ្យអាគារសាធារណៈទាំងអស់អាចចេញចូលបានដោយងាយស្រួលនិងដោយសុវត្ថិភាព សម្រាប់មនុស្សចាស់និងជនពិការ។ | • ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងយុត្តិធម៌ |
| | ៥. លើកកម្ពស់ការយល់ដឹងអំពីមនុស្សចាស់តាមរយៈប្រព័ន្ធផ្សព្វផ្សាយសាធារណៈនានា។ | • ក្រសួងព័ត៌មាន ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |
| **អាទិភាពទី៥ : សមាគមមនុស្សចាស់និងវ័យចាស់សកម្ម** | | |
| **ទិសដៅ ៥.១ :** គាំទ្រដល់ការបង្កើតសមាគមមនុស្សចាស់នៅទូទាំងប្រទេស | ១. ពង្រឹងសមាគមមនុស្សចាស់ដែលមានស្រាប់និងពង្រីកបណ្តាញឲ្យទៅដល់កម្រិតថ្នាក់ក្រោមជាតិ។ | • ក្រសួងមហាផ្ទៃ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងផែនការ |
| | ២. ផ្តល់មូលនិធិនិងផ្តល់ការសម្រួលដល់ការបង្កើតសមាគមមនុស្ស | • ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងសង្គមកិច្ច |

| ទិសដៅ | យុទ្ធសាស្ត្រ | ស្ថាប័នទទួលខុសត្រូវ |
|---|---|---|
| | ចាស់នៅគ្រប់ឃុំ សង្កាត់។ | អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងផែនការ |
| | ៣. ផ្ដល់ការបណ្ដុះបណ្ដាលដល់សមាជិកសមាគមមនុស្សចាស់ស្ដីពីការបង្កើតនិងការដំណើរការសមាគមមនុស្សចាស់។ | • ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងផែនការ |
| | ៤. លើកទឹកចិត្តឲ្យមានទំនាក់ទំនងរវាងអង្គការមិនមែនរដ្ឋាភិបាល និងរាជរដ្ឋាភិបាល ដើម្បីបង្កើតបណ្ដាញប្រជាជនវ័យចាស់ នៅក្នុងគ្រប់វិស័យ។ | • ក្រសួងមហាផ្ទៃ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងផែនការ |
| | ៥. លើកទឹកចិត្តដល់អង្គការមិនមែនរដ្ឋាភិបាលដែលពាក់ព័ន្ធក្នុងការផ្ដល់ប្រឹក្សាដល់គណៈកម្មាធិការគ្រប់គ្រងសមាគមមនុស្សចាស់និងក្នុងការចាត់ចែងសកម្មភាពរបស់ខ្លួន។ | • ក្រសួងមហាផ្ទៃ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងផែនការ |
| | ៦. បង្កើតយន្តការមួយដែលតាមរយៈនេះ សមាគមមនុស្សចាស់អាចមានការប្រាស្រ័យទាក់ទងនិងផ្លាស់ប្ដូរបទពិសោធជាមួយគ្នាជាប្រចាំ។ | • ក្រសួងមហាផ្ទៃ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងផែនការ ក្រសួងព័ត៌មាន |
| **ទិសដៅ ៥.២** : ពង្រឹងតួនាទីរបស់សមាគមមនុស្សចាស់ | ១. គាំទ្រដល់សមាគមមនុស្សចាស់ ក្នុងការបង្កើតឡើងនូវសន្តិសុខនៃមូលដ្ឋានទ្រទ្រង់ជីវភាពរស់នៅ តាមរយៈការបណ្ដុះបណ្ដាលពួកគាត់អំពីសកម្មភាពបង្កើតប្រាក់ចំណូល។ | • ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ |
| | ២. ផ្ដល់ការបណ្ដុះបណ្ដាលដល់សមាគមមនុស្សចាស់អំពីការថែទាំសុខភាពមូលដ្ឋាននិងបង្កលក្ខណៈឲ្យពួកគាត់អាចបង្កើតនិង | • ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងផែនការ ក្រសួងការងារនិងបណ្ដុះបណ្ដាល |

| ទិសដៅ | យុទ្ធសាស្ត្រ | ស្ថាប័នទទួលខុសត្រូវ |
|---|---|---|
| | ដំណើរការនូវគម្រោងការថែទាំតាមផ្ទះ ហើយតាមរយៈនេះ ពួកគាត់អាចចូលរួមវិភាគទានក្នុងការលើកកម្ពស់ការថែទាំសុខភាព។ | វិជ្ជាជីវៈ |
| | ៣. លើកកម្ពស់ស្មារតី "មនុស្សចាស់ជួយមនុស្សចាស់" ជាមូលដ្ឋានគ្រឹះរបស់សមាគមមនុស្សចាស់ ដើម្បីលើកទឹកចិត្តដល់មនុស្សចាស់ដែលសកម្មនិងមានសុខភាពល្អជាងឲ្យជួយមនុស្សចាស់រួមជំនាន់ដែលមានស្ថានភាពមិនសូវល្អដូចពួកគាត់។ | • ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងផែនការ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| **អាទិភាពទី៦** : **ទំនាក់ទំនងអន្តរជំនាន់** | | |
| **ទិសដៅ ៦.១** : ពង្រីកឱកាសសម្រាប់ការចូលរួមរបស់មនុស្សចាស់នៅក្នុងជីវភាពសាធារណៈ | ១. បង្កើតក្រុមមនុស្សចាស់នៅក្នុងអាជ្ញាធរមូលដ្ឋាននីមួយៗ ដើម្បីធានាបានថា មនុស្សចាស់មានសំឡេងនៅក្នុងដំណើរការការសម្រេចចិត្ត ហើយ សេចក្តីត្រូវការរបស់ពួកគាត់ត្រូវបានលើកយកមកពិចារណា។ | • ក្រសួងមហាផ្ទៃ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ២. ធានាថា មនុស្សចាស់ត្រូវបានធ្វើឲ្យមានពាក់ព័ន្ធ នៅក្នុងការរៀបចំ និងការអនុវត្តគោលនយោបាយទាំងឡាយដែលជះឥទ្ធិពលដល់ពួកគាត់ ទាំងនៅថ្នាក់ជាតិ ទាំងនៅថ្នាក់មូលដ្ឋាន។ | • ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ៣. បង្កើតមូលដ្ឋានទិន្នន័យស្តីពីជំនាញរបស់អ្នកឯកទេសដែលបានចូលនិវត្តន៍ ធ្វើជាឧបករណ៍ប្រឹក្សាសម្រាប់សហគមន៍និងរដ្ឋបាលគ្រប់កម្រិត។ | • ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងមុខងារសាធារណៈ |

| ទិសដៅ | យុទ្ធសាស្ត្រ | ស្ថាប័នទទួលខុសត្រូវ |
| --- | --- | --- |
| | ៤. ផ្តល់ការសម្រួលដល់ការចូលរួមរបស់មនុស្សចាស់ នៅក្នុងព្រឹត្តិការណ៍សាធារណៈនានាដូចជា ការចូលរួមនៅក្នុងការបោះឆ្នោត សកម្មភាពផ្នែកវប្បធម៌និងសាសនា ជាដើម។ | • ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ក្រសួងធម្មការ និងសាសនា |
| **ទិសដៅ ៦.២** :<br>ជំរុញឲ្យមានឥរិយាបទវិជ្ជមានចំពោះដំណើរឈានចូលដល់វ័យចាស់និងមនុស្សចាស់ | ១. លើកកម្ពស់ការយល់ដឹងថា មនុស្សចាស់មិនមែនជាបន្ទុកលើសហគមន៍ទេ ប៉ុន្តែ ពួកគាត់នាំអត្ថប្រយោជន៍មកដល់សង្គមវិញ។ | • ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងផែនការ ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ២. កែប្រែទស្សនៈខុសឆ្គងដែលថាមនុស្សចាស់ពុំមានគោលដៅប្រកបដោយអត្ថន័យ សម្រាប់ពេលវេលាដែលនៅសេសសល់ក្នុងជីវិតរបស់ខ្លួនឡើយ ក្រៅពីរង់ចាំសេចក្តីស្លាប់។ | • ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងផែនការ ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ៣. លើកទឹកចិត្តឲ្យមានការបង្កើតកម្មវិធីទូរទស្សន៍ វិទ្យុ និងប្រព័ន្ធផ្សព្វផ្សាយទាំងឡាយ ដែលផ្តោតការយកចិត្តទុកដាក់លើការចូលរួមវិភាគទានរបស់មនុស្សចាស់និងតួនាទីដែលមនុស្សចាស់បានធ្វើនៅក្នុងសហគមន៍។ | • ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងព័ត៌មាន ក្រសួងអប់រំ យុវជន និងកីឡា ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| **ទិសដៅ ៦.៣** :<br>ពង្រឹងទំនាក់ទំនងអន្តរជំនាន់ | ១. លើកទឹកចិត្តមនុស្សវ័យក្មេងឲ្យស្ម័គ្រចិត្តជួយដល់មនុស្សចាស់។ | • ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងផែនការ ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ២. ជំរុញឲ្យមានការរៀបចំសកម្មភាពនានាដែលមនុស្សគ្រប់វ័យទាំងអស់អាចចូលរួមបាន។ | • ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងផែនការ ក្រសួងអប់រំ យុវជន និងកីឡា |

| ទិសដៅ | យុទ្ធសាស្ត្រ | ស្ថាប័នទទួលខុសត្រូវ |
|---|---|---|
| | ៣. រៀបចំធ្វើបទបង្ហាញ អមដោយការពិភាក្សាអំពីការបំពេញបន្ថែមគ្នាទៅវិញទៅមករបស់មនុស្សជំនាន់ខុសគ្នា សម្រាប់មនុស្សពេញវ័យ នៅក្មេង និងមនុស្សចាស់។ | • ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងផែនការ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ៤. រៀបចំបណ្តុះបណ្តាលនិងគាំទ្រដល់មនុស្សចាស់លើបញ្ហាការប្រើប្រាស់មធ្យោបាយប្រាស្រ័យទាក់ទងគ្នា(ដូចជាទូរសព្ទដៃ ប្រព័ន្ធផ្សព្វផ្សាយសង្គម ជាដើម) ដើម្បីឲ្យពួកគាត់រក្សានូវទំនាក់ទំនងជាមួយនឹងកូនចៅ ជាមនុស្សពេញវ័យនិងសាច់ញាតិក្មេងៗដទៃទៀតរបស់ពួកគាត់។ | • ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្រសួងព័ត៌មាន ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ៥. ដាក់បញ្ចូលវគ្គសិក្សាអំពីសារៈសំខាន់នៃការគោរពនិងការធ្វើទំនាក់ទំនងជាមួយនឹងមនុស្សចាស់ នៅក្នុងកម្មវិធីសិក្សាស្ថាប័នបណ្តុះបណ្តាល និងសាលារៀននានា។ | • ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងអប់រំ យុវជន និងកីឡា ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ៦. បង្ហាញជាសាធារណៈនូវសមិទ្ធផលរបស់មនុស្សចាស់ តាមរយៈប្រព័ន្ធផ្សព្វផ្សាយ។ | • ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងព័ត៌មាន ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ៧. ផ្តល់កិត្តិយសដល់ស្នាដៃមានលក្ខណៈជាគំរូដែលមនុស្សចាស់សម្រេចបាន ដូចជា ការងារស្ម័គ្រចិត្ត ឬការងារច្នៃប្រឌិត ដោយផ្តល់ពានរង្វាន់និង/ឬវិញ្ញាបនបត្រទទួលស្គាល់ស្នាដៃ។ | • ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងផែនការ ក្រសួងព័ត៌មាន |
| **អាទិភាពទី៧ : ការរំលោភបំពាននិងអំពើហិង្សាលើមនុស្សចាស់** | | |

| ទិសដៅ | យុទ្ធសាស្ត្រ | ស្ថាប័នទទួលខុសត្រូវ |
|---|---|---|
| **ទិសដៅ ៧.១** : កាត់បន្ថយនិងទប់ស្កាត់ករណីការរំលោភបំពានលើមនុស្សចាស់ | ១. ដាក់ចេញនូវលិខិតបទដ្ឋានគតិយុត្ត ដើម្បីការពារមនុស្សចាស់ពីការរំលោភបំពាន។ | ◆ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ |
| | ២. បំពាក់បំប៉នចំណេះដឹងដល់មនុស្សចាស់ពីសណ្ឋាននៃការរំលោភបំពានលើមនុស្សចាស់និងសិទ្ធិរបស់ពួកគាត់ក្នុងការការពារខ្លួនពីការរំលោភបំពាននេះ។ | ◆ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងយុត្តិធម៌ |
| | ៣. លើកទឹកចិត្តមនុស្សចាស់ឲ្យរាយការណ៍អំពីការរំលោភបំពានលើមនុស្សចាស់ ឬពិភាក្សាពីករណីការរំលោភបំពានលើមនុស្សចាស់ជាមួយនឹងសាច់ញាតិជិតស្និទ្ធ មិត្តភក្តិ ឬវេជ្ជបណ្ឌិតរបស់ពួកគាត់។ | ◆ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងយុត្តិធម៌ ក្រសួងមហាផ្ទៃ |
| | ៤. បញ្ជ្រាបការយល់ដឹងដល់សហគមន៍ពីសារៈសំខាន់នៃការរាយការណ៍អំពីករណីជាក់ស្តែងដែលបានកើតមាន ឬសូម្បីតែករណីសង្ស័យអំពីការរំលោភបំពានលើមនុស្សចាស់ដែលពួកគាត់បានដឹង។ | ◆ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងយុត្តិធម៌ |
| | ៥. ផ្តល់សិទ្ធិឲ្យបុគ្គលិកសុខាភិបាលអាចស្រាវជ្រាវស្វែងយល់ ហើយក្នុងករណីចាំបាច់ អាចរាយការណ៍ជូនអាជ្ញាធរដែលពាក់ព័ន្ធ អំពីករណីរំលោភបំពានលើមនុស្សចាស់ដែលអ្នកជំងឺជាមនុស្សចាស់របស់ពួកគេបានឆ្លងកាត់។ | ◆ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងសុខាភិបាល ក្រសួងផែនការ |

| ទិសដៅ | យុទ្ធសាស្ត្រ | ស្ថាប័នទទួលខុសត្រូវ |
|---|---|---|
| **ទិសដៅ ៧.២** :<br>ការពារមនុស្សចាស់កុំឲ្យធ្លាក់ជាជនរងគ្រោះនៃអំពើហិង្សានិងបទឧក្រិដ្ឋ | ១. ពង្រឹងសមត្ថភាពអង្គភាពនគរបាលជំនាញ ដើម្បីការពារមនុស្សចាស់ និងទប់ស្កាត់អំពើហិង្សាលើមនុស្សចាស់។ | • ក្រសួងមហាផ្ទៃ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ២. ជំរុញឲ្យមានសហគមន៍មានការយល់ដឹងអំពីបញ្ហាសុវត្ថិភាពរបស់មនុស្សចាស់ដែលរស់នៅតែម្នាក់ឯង ក្នុងតំបន់របស់ពួកគាត់។ | • ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងផែនការ |
| **អាទិភាពទី៨ : ស្ថានភាពមានអាសន្ន** | | |
| **ទិសដៅ ៨.១** :<br>ធានាឲ្យមាននូវកិច្ចខិតខំប្រឹងប្រែងក្នុងការសង្គ្រោះឬការស្តារសម្បទា ដោយផ្តល់ការយកចិត្តទុកដាក់សមស្របចំពោះមនុស្សចាស់ | ១. ផ្តល់អាទិភាពដល់មនុស្សចាស់ កុមារ និងជនពិការ នៅក្នុងផែនការកាត់បន្ថយហានិភ័យ ក្នុងនោះមាន ការប្រកាសភាពអាសន្នអំពីគ្រោះមហន្តរាយ ការជួយសង្គ្រោះ ការផ្តល់ទីជម្រក ក៏ដូចជា នៅក្នុងការផ្តួចផ្តើមគំនិតអំពីការស្តារសម្បទាក្រោយពេលគ្រោះមហន្តរាយ។ | • ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងផែនការ ក្រសួងព័ត៌មាន ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ២. លើកទឹកចិត្តឲ្យមានការចូលរួមពីមនុស្សចាស់ នៅក្នុងការរៀបចំផែនការកាត់បន្ថយគ្រោះមហន្តរាយ នៅគ្រប់កម្រិតទាំងអស់ ដើម្បីឲ្យបានគំនិតយោបល់ទៅលើបញ្ហានានាទាក់ទងនឹងបញ្ហាមនុស្សចាស់។ | • ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងផែនការ ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ៣. បណ្តុះបណ្តាលអ្នកបម្រើការងារជួយសង្គ្រោះឬស្តារសម្បទា ឲ្យអាចកំណត់ទីតាំងដែលមនុស្សចាស់កំពុងស្ថិតនៅក្នុងកំលុងពេលមានគ្រោះអាសន្ន និងឲ្យអាចវាយតម្លៃពីភាពងាយរងគ្រោះរបស់ | • ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងផែនការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |

| ទិសដៅ | យុទ្ធសាស្ត្រ | ស្ថាប័នទទួលខុសត្រូវ |
|---|---|---|
| | មនុស្សចាស់ ទាក់ទងនឹងស្ថានភាពផ្នែករាងកាយនិងផ្លូវចិត្តរបស់ពួកគាត់។ | |
| | ៤. បញ្ជ្រាបការយល់ដឹងដល់អ្នកបម្រើការងារជួយសង្គ្រោះឬស្តារសម្បទាអំពីបញ្ហានានាដែលជួបប្រទះដោយមនុស្សចាស់។ | • ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងផែនការ ក្រសួងព័ត៌មាន ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ៥. ផ្តល់ការការពារបន្ថែមដល់ស្ត្រីវ័យចាស់ពីការកេងប្រវ័ញ្ចនិងការរំលោភបំពានផ្នែករាងកាយ ផ្លូវចិត្ត ផ្លូវភេទ និងហិរញ្ញវត្ថុ នៅក្នុងស្ថានភាពមានអាសន្ន។ | • ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងផែនការ ក្រសួងព័ត៌មាន ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ៦. រៀបចំកម្មវិធីជួយសង្គ្រោះឬស្តារសម្បទាឲ្យមានលក្ខណៈអំណោយផលចំពោះមនុស្សចាស់។ | • ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងផែនការ ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ៧. ធានាថា មជ្ឈមណ្ឌលសម្រាប់ការជម្លៀសមានការរៀបចំពិសេសដែលសមស្របទៅនឹងសេចក្តីត្រូវការរបស់មនុស្សចាស់។ | • ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងផែនការ ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ៨. បង្កើនចំនួនអ្នកមានវិជ្ជាជីវៈផ្នែកមនុស្សចាស់ នៅក្នុងក្រុមវេជ្ជសាស្ត្រដែលបានបញ្ជូនចេញទៅកាន់ទីកន្លែងជួបគ្រោះមហន្តរាយ។ | • ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងផែនការ ក្រសួងសុខាភិបាល |
| | ៩. លើកកម្ពស់ការយល់ដឹងជាសាធារណៈ ដើម្បីពង្រីកការជួយជ្រោមជ្រែងទៅដល់មនុស្សចាស់ដែលជួបការលំបាក ក្នុងកំលុងពេលមានអាសន្ន។ | • ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងផែនការ ក្រសួងព័ត៌មាន ក្រសួង ស្ថាប័ន ពាក់ព័ន្ធ |

| ទិសដៅ | យុទ្ធសាស្ត្រ | ស្ថាប័នទទួលខុសត្រូវ |
|---|---|---|
| **ទិសដៅ ៨.២** : បញ្ជ្រាបការយល់ដឹងដល់មនុស្សចាស់ពីវិធីដើម្បីរៀបចំខ្លួនឆ្លើយតបទៅនឹងករណីមានអាសន្ន | ១. ផ្តល់ការណែនាំនិងការបណ្តុះបណ្តាលដល់មនុស្សវ័យចាស់ពីរបៀបដោះស្រាយនៅពេលមានគ្រោះមហន្តរាយធម្មជាតិនិងករណីអាសន្នផ្សេងៗទៀត ដូចជាការផ្លាស់ទីកន្លែងរស់នៅរបស់ប្រជាជនជាដើម។ | • ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងផែនការ ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ២. ផលិតនិងចែកចាយសៀវភៅណែនាំសម្រាប់មនុស្សចាស់ ដោយគូសបញ្ជាក់ពីការប្រុងប្រយ័ត្នជាមុន និងសកម្មភាពទាំងឡាយដែលត្រូវធ្វើ ក្នុងករណីមានអាសន្នតាមប្រភេទផ្សេងៗពីគ្នា។ | • ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងផែនការ ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ៣. ដាក់ឲ្យដំណើរការនូវប្រព័ន្ធមួយដែលមនុស្សចាស់អាចចុះបញ្ជីអាស័យដ្ឋានរបស់ពួកគាត់និងព័ត៌មានលម្អិតដែលពាក់ព័ន្ធដទៃទៀត ដើម្បីជួយឲ្យក្រុមអ្នកសង្គ្រោះអាចកំណត់ទីតាំងរបស់ពួកគាត់បានទាន់ពេល នៅពេលមានអាសន្ន ជាពិសេស នៅតាមទីតាំងដែលជួបគ្រោះមហន្តរាយញឹកញាប់ ។ | • ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងផែនការ ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ៤. ផ្តល់ការណែនាំដល់មនុស្សចាស់អំពីរបៀបទាក់ទាញចំណាប់អារម្មណ៍របស់មនុស្សដទៃ នៅពេលជួបនឹងគ្រោះថ្នាក់ខ្លាំងហួសប្រមាណ ក្នុងស្ថានភាពមានអាសន្ន។ | • ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងផែនការ ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| **អាទិភាពទី៩** : **ការត្រៀមខ្លួនរបស់ប្រជាជនវ័យក្មេង** | | |
| **ទិសដៅ ៩.១** : | ១. ពង្រីកវិសាលភាពគ្របដណ្តប់នៃយន្តការការពារផ្នែកហិរញ្ញវត្ថុ | • ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |

| ទិសដៅ | យុទ្ធសាស្ត្រ | ស្ថាប័នទទួលខុសត្រូវ |
|---|---|---|
| ផ្តល់នូវបរិស្ថានមួយដែលប្រជាជនវ័យក្មេងអាចត្រៀមខ្លួនបានកាន់តែប្រសើរសម្រាប់ពេលឈានដល់វ័យចាស់ | សម្រាប់ការត្រៀមរៀបចំពេលចូលដល់វ័យចាស់ តាមយៈការអនុវត្តផែនការប្រាក់សោធននិវត្ត និងគម្រោងសន្សំប្រាក់ ដើម្បីធានាឲ្យមានប្រាក់ចំណូលសមរម្យ សម្រាប់ប្រជាជនដែលចូលរួមក្នុងរបបសោធនកាតព្វកិច្ចនិងស្ម័គ្រចិត្ត និងការកាត់បន្ថយជាអតិបរមានូវការធ្លាក់ចុះទៅក្នុងភាពក្រីក្រនៅពេលឈានដល់វ័យចាស់។ | ក្រសួងផែនការ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ |
| | ២. ផ្សព្វផ្សាយព័ត៌មានស្តីពីរបៀបរស់នៅដែលមានសុខភាពល្អ ដូចជា ទម្លាប់ហូបអាហារធ្វើឲ្យមានសុខភាពល្អ និង ការហាត់ប្រាណទៀងទាត់ ជាដើម ដើម្បីជួយឲ្យមនុស្សចាស់នាពេលអនាគត អាចរក្សាបាននូវបទដ្ឋានសុខភាពកាន់តែខ្ពស់ថែមទៀត។ | • ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងផែនការ ក្រសួងព័ត៌មាន ក្រសួងអប់រំ យុវជន និងកីឡា ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ៣. ផ្តល់គម្រោងធានារ៉ាប់រងសុខភាពជូនដល់មនុស្សក្នុងវ័យធ្វើការងារ ដែលផ្តល់ការគ្របដណ្តប់សម្រាប់ពេលគាត់ឈានចូលដល់វ័យចាស់ផងដែរ។ | • ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងផែនការ ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ៤. បណ្តុះឲ្យមាននៅក្នុងផ្នត់គំនិតរបស់ប្រជាជនវ័យក្មេងនូវការឲ្យតម្លៃដល់មនុស្សវ័យចាស់ ដើម្បីលុបបំបាត់នូវការភ័យខ្លាចរបស់ពួកគាត់ចំពោះការក្លាយជាមនុស្សចាស់និងអារម្មណ៍អវិជ្ជមានទាំងឡាយដែលពួកគាត់អាចមានចំពោះជីវិតវ័យចាស់។ | • ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងផែនការ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| | ៥. ផ្តល់ឱកាសឲ្យមនុស្សវ័យក្មេងធ្វើការងារស្ម័គ្រចិត្ត សម្រាប់មនុស្សចាស់និងនៅផ្ទះនិងអង្គការសម្រាប់មនុស្សចាស់ ដើម្បីឲ្យពួកគាត់ | • ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងផែនការ ក្រសួង ស្ថាប័នពាក់ព័ន្ធ |

| ទិសដៅ | យុទ្ធសាស្ត្រ | ស្ថាប័នទទួលខុសត្រូវ |
|---|---|---|
| | មានព័ត៌មានផ្ទាល់អំពីរបៀបដោះស្រាយបញ្ហាទាំងឡាយដែលអាចនឹងកើតមានឡើងក្នុងវ័យចាស់។ | |
| | ៦. បង្កើនការយល់ដឹងជាសាធារណៈពីសារៈសំខាន់នៃដំណើរឈានចូលវ័យចាស់ប្រកបដោយភាពថ្លៃថ្នូរ តាមរយៈការអប់រំក្នុងប្រព័ន្ធនិងក្រៅប្រព័ន្ធ ដែលត្រូវធ្វើឡើងជាប្រចាំ។ | • ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងផែនការ ក្រសួង ស្ថាប័នពាក់ព័ន្ធ |
| **ទិសដៅ ៩.២** : ជំរុញលើកទឹកចិត្តដល់មនុស្សវ័យក្មេងឲ្យត្រៀមខ្លួន សម្រាប់ការឈានចូលដល់វ័យចាស់ប្រកបដោយសុខភាពល្អនិងសកម្ម | ១. ដាក់បញ្ចូលមុខវិជ្ជាស្តីពីរបៀបរៀបចំការរស់នៅប្រកបដោយសុខភាពល្អនិងអាកប្បកិរិយានិងឥរិយាបថចេះស្វែងរកសុខភាពល្អ នៅក្នុងកម្មវិធីសិក្សារបស់សាលា។ | • ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងផែនការ ក្រសួងអប់រំ យុវជន និងកីឡា |
| | ២. បង្ហាញពីការគោរពនិងការថែទាំឪពុកម្តាយនិងសាច់ញាតិចាស់ជរាដើម្បីបង្ហាញជាគំរូល្អដល់កូនៗរបស់ខ្លួនពីសារៈសំខាន់នៃករណីយកិច្ចទាំងអស់នេះ។ | • ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងផែនការ ក្រសួងអប់រំ យុវជន និងកីឡា |
| | ៣. លើកទឹកចិត្តឲ្យមានការពិនិត្យសុខភាពជាប្រចាំ។ | • ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងផែនការ ក្រសួងអប់រំ យុវជន និងកីឡា |
| | ៤. បញ្ជ្រាបការយល់ដឹងពីផលប៉ះពាល់នៃការផ្លាស់ប្តូរដែលមិនអាចជៀសបាន ដែលកើតចេញមកពីការចូលនិវត្តន៍និងដំណើរឈានចូលវ័យចាស់។ | • ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងផែនការ ក្រសួងអប់រំ យុវជន និងកីឡា |

# សទ្ទានុក្រម

**ចំហាកប្រជាសាស្ត្រ** ( Demographic Scenario )

សំដៅដល់ *ស្ថានភាពប្រជាសាស្ត្រ* ឬ *ព្រឹត្តិការណ៍ប្រជាសាស្ត្រ* ឬ *ការវិវត្តផ្នែកប្រជាសាស្ត្រ* ដែលពាក់ព័ន្ធនឹងការកើត ការស្លាប់ និងទេសន្តរប្រវេសន៍របស់ប្រជាជន។

**ផលធៀបគាំទ្រសក្តានុពល** ( Potential Support Ratio )

សំដៅដល់ចំនួនប្រជាជនក្នុងវ័យធ្វើការអាយុពី១៥ដល់៦៤ឆ្នាំ ក្នុងមនុស្សចាស់១០០នាក់អាយុ៦៥ឆ្នាំឡើង។ ផលធៀបគាំទ្រសក្តានុពល ផ្តល់នូវការវាស់វែងមួយអំពីទំនាក់ទំនងរវាងអ្នកដែលមានលទ្ធភាពផ្នែកសេដ្ឋកិច្ចនិងអ្នកដែលអាចផ្តល់ការគាំទ្រនិងការថែទាំដល់មនុស្សចាស់ដែលជាអ្នកនៅក្នុងបន្ទុក និងជាអ្នកត្រូវការ គាំទ្រនិងការថែទាំនេះ។

**ផលធៀបគាំទ្រឪពុកម្តាយ** (Parent Support Ratio)

សំដៅដល់ចំនួនប្រជាជនវ័យចាស់ជរាអាយុ៨០ឆ្នាំឡើង ក្នុងចំណោមប្រជាជនអាយុពី៥០ដល់៥៩ឆ្នាំ ចំនួន១០០នាក់ ហើយនេះគឺជាសូចនាករអំពីការគាំទ្ររបស់គ្រួសារដែលមានសម្រាប់ឪពុកម្តាយវ័យចាស់ជរា។ ដោយអាស្រ័យលើការប្រើប្រាស់និងស្ថានភាពខុសៗគ្នាជួនកាលផលធៀបនេះ សំដៅលើប្រជាជនវ័យចាស់ជរាអាយុ៨៥ឆ្នាំឡើង ក្នុងចំណោមប្រជាជនអាយុពី៥០ដល់៦៤ឆ្នាំ ចំនួន១០០នាក់។

**ភាគលាភប្រជាសាស្ត្រ** ( Demographic Dividend )

សំដៅដល់សក្តានុពលកំណើនសេដ្ឋកិច្ចដែលអាចកើតមាន ដោយសារតែការផ្លាស់ប្តូរក្នុងរចនាសម្ព័ន្ធអាយុរបស់ប្រជាជន ពីកំណើនមនុស្សក្នុងបន្ទុកខ្ពស់ទៅរកកំណើនប្រជាជនក្នុងវ័យធ្វើការងារខ្ពស់។នៅពេលដែលចំនួនប្រជាជនក្នុងវ័យធ្វើការអាយុពី១៥ដល់៦៤ឆ្នាំមានទំហំធំជាងចំនួនប្រជាជនក្នុងបន្ទុក(អាយុក្រោម១៤ឆ្នាំនិងអាយុ៦៥ឆ្នាំឡើង )នោះមនុស្សក្នុងវ័យធ្វើការច្រើនចិញ្ចឹមមនុស្សនៅក្នុងបន្ទុកតិច ដែលជាឱកាសមួយសម្រាប់សន្សំប្រាក់ដើម្បីវិនិយោគឬធ្វើជំនួញផ្សេងៗ ដែលនាំឲ្យមានការអភិវឌ្ឍសេដ្ឋកិច្ច។

**អាយុកណ្តាល** ( Median Age )

សំដៅដល់អាយុមួយនៃរបាយប្រជាជន ដែលចែករបាយប្រជាជនជាពីរចំណែកស្មើៗគ្នា។ តាមទិន្នន័យឆ្នាំ២០១៣ អាយុកណ្តាលរបស់ប្រជាជនកម្ពុជា ស្មើនឹង២៤ឆ្នាំ ដែលមានន័យថា៥០%នៃប្រជាជនកម្ពុជាមានអាយុ២៤ឆ្នាំចុះក្រោម និង៥០%ទៀតមានអាយុ២៤ឆ្នាំឡើង។

**វ័យចាស់សកម្ម** ( Active Ageing )

សំដៅដល់ដំណើរនៃការធ្វើឲ្យប្រសើរបំផុតនូវឱកាសដើម្បីសុខភាព ការចូលរួម និងសុវត្ថិភាព ក្នុងគោលបំណងបង្កើនគុណភាពនៃជីវិត នៅពេលដែលមនុស្សឈានទៅរកវ័យចាស់។

**របៀបរបបការរស់នៅ** ( Living Arrangement )

សំដៅដល់ការមានឬគ្មានមនុស្សរស់នៅជាមួយ។ របៀបរបបការរស់នៅរបស់មនុស្សចាស់ មានដូចជា មនុស្សរស់នៅឯកា រស់នៅតែជាមួយប្តីឬប្រពន្ធ រស់នៅជាមួយកូនបង្កើត រស់នៅតែជាមួយចៅ ឬរស់នៅជាមួយអ្នកដទៃ ជាដើម។